រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្ម ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




ឆ្នាំ ២០២៥

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ
ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# បុព្វកថា

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយថាមពលរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបន្តផ្តល់អាទិភាពលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាកម្មវិធីកែទម្រង់ស្នូល នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ឆ្ពោះទៅពង្រឹងអភិបាលកិច្ច ដែលជាបរិយាកាសចាំបាច់សម្រាប់កិច្ចអភិវឌ្ឍជាតិ។ ចក្ខុវិស័យប្រាកដនិយមរបស់កម្មវិធីកែទម្រង់មួយនេះ បាននិងកំពុងនាំប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅរកស្តង់ដា និងឧត្តមានុវត្តន៍ជាអន្តរជាតិ និយាយម្យ៉ាងទៀត ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា នឹងត្រូវផ្លាស់ប្តូរទាំងស្រុងពីប្រព័ន្ធដែលផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការ ទៅជាប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬលទ្ធផល និងមានលក្ខណៈវិមជ្ឈការ។ ក្នុងគោលបំណងដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យនេះ, រាជរដ្ឋាភិបាលបានកំណត់យកយុទ្ធសាស្ត្របោះជំហានតាមដំណាក់កាល ឬ អភិក្រមជាខឿន តាមរយៈការដាក់ចេញនូវក្របខ័ណ្ឌផែនការសកម្មភាពរួមដ៏លម្អិតមួយ ដែលផ្សំឡើងពីបណ្តាសកម្មភាពចាំបាច់សម្រាប់ការកសាងមូលដ្ឋានគ្រឹះនៅតាមដំណាក់កាលនីមួយៗ និងសកម្មភាពចាំបាច់នានា ដែលត្រូវចាប់ផ្តើមសាកល្បងដកពិសោធជាបណ្តើរៗ មុនឈានចូលទៅដល់ដំណាក់កាលបន្ទាប់។

៣ ដំណាក់កាលដែលមានរយៈពេល ២០ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មុននឹងឈានចូលដំណាក់កាលទី៤ «**គណនេយ្យភាពសមិទ្ធកម្ម**», រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលជាច្រើន, ទាំងសមិទ្ធផលក្នុងការកែលម្អអភិបាលកិច្ច នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទាំងសមិទ្ធផលក្នុងទិដ្ឋភាពនៃការរីកចម្រើនផ្នែកសង្គម-សេដ្ឋកិច្ចកម្ពុជា។ ជាក់ស្តែង នៅឆ្នាំ២០០៣, មុនការចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់នេះ, ចំណូល ថវិកាជាតិសរុប មានប្រមាណតែ ១ ៨២១ ប៊ីលានរៀល ប៉ុណ្ណោះ; រីឯចំណាយថវិកាជាតិ មានប្រមាណ ២ ៩៩៤ ប៊ីលានរៀល។ រយៈពេលជាង ២០ឆ្នាំក្រោយ, ចំណូលថវិកាជាតិ ក្នុងឆ្នាំ២០២៤ កើនឡើងជាង ២០ដង ខណៈចំណាយថវិកាជាតិសរុបកើនឡើងជាង ១៥ដង។ សូចនាករសមិទ្ធកម្មទាំងនេះ បង្កើតបានជាឃ្នាស់សេដ្ឋកិច្ចដ៏ចាំបាច់ដែលធ្វើឱ្យកម្ពុជាទទួលបានកំណើន និងបន្តស្ថិរភាពនៃកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ រហូតដល់សម្រេចបាននូវចំណាត់ថ្នាក់ជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ និងកំពុងបន្តបោះជំហានយ៉ាងមានទំនុកចិត្ត ទៅកាន់ឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ជាការពិតមិនអាចប្រកែកបាន សុខភាពដ៏ល្អប្រសើរនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា បានធ្វើឱ្យរាជរដ្ឋាភិបាលមានថវិកាសន្សំគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាជាយថាហេតុទាំងឡាយនាពេលកន្លងទៅ ជាអាទិ៍ ការឆ្លើយតបនឹងស្ថានភាពមិនអំណោយផលបង្កឡើងដោយវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកលលោក ក៏ដូចជាការឆ្លើយតបនឹងគ្រោះមហន្តរាយ និងគ្រោះធម្មជាតិនានាដែលមិនអាចស្មានទុកជាមុនបាន។ ជាក់ស្តែង, រាជរដ្ឋាភិបាលកម្ពុជា មានលទ្ធភាពគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់នូវវិបត្តិសុខុមាលភាព, សង្គម និងសេដ្ឋកិច្ច ដែលបណ្តាលមកពីការរីករាលដាលជាសកល នៃជំងឺកូវីដ-១៩ រហូតកម្ពុជាត្រូវបានទទួលស្គាល់នៅក្នុងកម្រិតសកលលោកថា ជាប្រទេសគ្រប់គ្រងជំងឺកូវីដ-១៩ បានយ៉ាងល្អ និងជាប្រទេសស្ទុះងើបឡើងវិញពីវិបត្តិនៃជំងឺកូវីដ-១៩ បានយ៉ាងឆាប់រហ័ស។ បន្ថែមពីនេះ ជោគជ័យនៃការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈក្នុងរយៈពេលជាង ២០ឆ្នាំមកនេះ បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលគ្រប់នីតិកាល នៃរដ្ឋសភា បាននិងបន្តលើកកម្ពស់កម្រិតជីវភាពរស់នៅ និងបម្រើសេវាសាធារណៈជូនប្រជាជនបានកាន់តែប្រសើរឡើង តាមរយៈការអភិវឌ្ឍធនធានមនុស្សឱ្យកាន់តែមានគុណភាព; ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តចាំបាច់នានា ដូចជា ប្រព័ន្ធគមនាគមន៍, ប្រព័ន្ធធារាសាស្ត្រ និងប្រព័ន្ធអគ្គិសនី; ការកសាងសាលារៀន និងមន្ទីរពេទ្យ បានកាន់តែច្រើន និងមានគុណភាពកាន់តែប្រសើរឡើងឥតឈប់ឈរ ។ល។

ទោះជាយ៉ាងនេះក្តី យើងមិនអាចស្កប់ស្កល់នូវសមិទ្ធផលដែលបានកសាងឡើងក្នុង ៣ ដំណាក់កាល នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈពីខាងដើមនោះទេ ដោយយើងនៅសល់ ១ ដំណាក់កាលទៀត ដែលជាដំណាក់កាលកែទម្រង់កាន់តែសំខាន់នោះគឺ ដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**"។ ដំណាក់កាលចុងក្រោយនេះ ត្រូវការកម្លាំងជំរុញយ៉ាងខ្លាំងក្លា ទាំងផ្នែកនយោបាយ និងបច្ចេកទេស ជាពិសេស ការតាមដាននិងវាយតម្លៃយ៉ាងហ្មត់ចត់ ទៅលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមត្រីមាស និងឆ្នាំនីមួយៗ។ ក្នុងន័យនេះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) បានដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្ម ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានគិតគូរទៅតាមលំដាប់លំដោយ នៃវដ្តគ្រប់គ្រងសមិទ្ធកម្ម ក្នុងនោះ រួមបញ្ចូលទាំងការរៀបចំយន្តការស្ថាប័ន, ការរៀបចំផែនការ, ការតាមដាននិងវាយតម្លៃ, ការលើកទឹកចិត្ត, និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគាំទ្រដល់ការគ្រប់គ្រងសមិទ្ធកម្ម។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដោយដកពិសោធពីការអនុវត្តការងារកែទម្រង់ជាច្រើនឆ្នាំកន្លងទៅ និងសិក្សាអំពីការតាមដាន និងវាយតម្លៃសមិទ្ធកម្ម ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍដែលនឹងក្លាយជាឧបករណ៍ដ៏មានសារៈសំខាន់ និងជាជំនួយដ៏មានប្រសិទ្ធភាព សម្រាប់ទាំងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដែលជាសេនាធិការឱ្យ **គ.ហ.ស.** ក្នុងតួនាទីជាតួអង្គតាមដាន និងវាយតម្លៃ និងទាំងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ដែលជាតួអង្គអនុវត្ត នឹងរួមគ្នាជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចបានតាមគោលដៅរំពឹងទុក។

ជាចុងក្រោយ ក្នុងនាម **គ.ហ.ស.** ខ្ញុំសូមយកឱកាសនេះ វាយតម្លៃខ្ពស់ចំពោះក្រសួង ស្ថាប័ន អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត និងរដ្ឋបាលរាជធានី ខេត្តទាំងអស់ ក្នុងក្របខ័ណ្ឌនៃកិច្ចខិតខំប្រឹងប្រែងអនុវត្តសកម្មភាពទាំងឡាយ និងបណ្តាដៃគូអភិវឌ្ឍក្នុងក្របខ័ណ្ឌនៃការពង្រឹងកិច្ចសហប្រតិបត្តិការ រហូតធ្វើឱ្យប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់យើងកាន់តែមានភាពរឹងមាំជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំសូមកោតសរសើរ និងផ្តល់មូលវិចារដ៏ថ្លៃថ្លាចំពោះ **អ.គ.ហ.** ក្នុងនាមជាសេនាធិការ នៃ **គ.ហ.ស.** ដែលបានរៀបចំគោលការណ៍ណែនាំនេះឡើង ដើម្បីជាឧត្តមប្រយោជន៍សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។ ខ្ញុំសូមជូនពរ**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធាន អនុប្រធាន និងសមាជិក សមាជិកា** នៃក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបណ្តាដៃគូអភិវឌ្ឍទាំងអស់ សូមទទួលបានសុខភាពល្អបរិបូណ៌ សុភមង្គលក្នុងគ្រួសារ និងជោគជ័យគ្រប់ភារកិច្ចការងារ៕

ថ្ងៃពុធ ១១ កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែឧសភា គ.ស. ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

ការកែប្រែប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាពី «**ប្រព័ន្ធដែលផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬ លទ្ធផល និងមានលក្ខណៈវិមជ្ឈការ**» គឺជាចក្ខុវិស័យជាក់ស្តែងនិយម និងមានលក្ខណៈមហិច្ឆតារបស់រាជរដ្ឋាភិបាលកម្ពុជា ទាំងក្នុងអាណត្តិនៃរាជរដ្ឋាភិបាលកន្លងទៅ និងអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ ក្នុងទិសដៅនេះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ក្នុងនាមជាសេនាធិការរាជរដ្ឋាភិបាល បានរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការសកម្មភាពដែលជាធាតុរួមមួយសម្រាប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) រួមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត និង ក្រសួង ស្ថាប័ន រៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិតដែលកំណត់សូចនាករសមិទ្ធកម្មគន្លឹះសម្រាប់វាស់វែង និងលក្ខខណ្ឌវាយតម្លៃច្បាស់លាស់ ដោយអនុលោមតាមសារាចររបស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ដើម្បីជានាប្រសិទ្ធភាពនៃការអនុវត្ត និងស្របតាមគោលបំណងរួម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដែលជាសេនាធិការជូន **គ.ហ.ស.** មានតួនាទីភារកិច្ចត្រួតពិនិត្យតាមដាន និងវាយតម្លៃប្រចាំត្រីមាស និងប្រចាំឆ្នាំទាំងកម្រិតនៃការអនុវត្តផែនការសកម្មភាព របស់អង្គភាព/ស្ថាប័នអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្រិតផែនការសកម្មភាពរួម។ ក្នុងគោលដៅពង្រឹងប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃ ស្របតាមបរិបទនៃការដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាគោលដៅចម្បងនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**", **គ.ហ.ស.** បានផ្តល់អនុសាសន៍ឱ្យ **អ.គ.ហ.** សិក្សា និងពិនិត្យមើលជារួមលើក្របខ័ណ្ឌគ្រប់គ្រងសមិទ្ធកម្ម ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្អែកលើក្របខ័ណ្ឌគតិយុត្តដែលមានជាធរមាន គម្លាតនៃការអនុវត្តជាក់ស្តែង និងទិសដៅកែលម្អ សំដៅពង្រឹងការផ្សារភ្ជាប់គ្នាឱ្យបានរឹងមាំរវាងទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពសមិទ្ធកម្ម។ ជាលទ្ធផល **អ.គ.ហ.** បានរៀបចំឡើងនូវក្របខ័ណ្ឌគ្រប់គ្រងសមិទ្ធកម្មថ្មីមួយ ឬអាចនិយាយម្យ៉ាងទៀតថា ជាប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃថ្មីមួយ ដែលមានលក្ខណៈច្បាស់លាស់ជាងមុន រឹងមាំជាងមុន ហើយរំពឹងថានឹងកៀរគរការចូលរួមអនុវត្តកាន់តែខ្លាំងឡើងពីតួអង្គអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងអស់។

គោលការណ៍ណែនាំដែល**ឯកឧត្តម លោកជំទាវ លោក លោកស្រី** កំពុងតែកាន់ក្នុងដៃនេះ គឺបានបកស្រាយលម្អិតអំពីក្របខ័ណ្ឌគ្រប់គ្រងសមិទ្ធកម្មថ្មីក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទៅតាមលំដាប់លំដោយនៃវដ្តគ្រប់គ្រងសមិទ្ធកម្ម ក្នុងនោះរួមបញ្ចូលទាំង (១) ការរៀបចំយន្តការស្ថាប័ន ដែលជាការបង្កើតក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត, (២) ការរៀបចំផែនការ ជាអាទិ៍ ផែនការសកម្មភាពរួម លទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពលម្អិត ផែនការថវិកា ផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ ព្រមទាំងការចុះកិច្ចព្រមព្រៀងសមិទ្ធកម្ម, (៣) ការតាមដាននិងវាយតម្លៃ ជាអាទិ៍ ការរៀបចំរបាយការណ៍សមិទ្ធកម្ម របបកិច្ចប្រជុំទាំងកម្រិតអង្គភាពនិងស្ថាប័ន និងកម្រិតគោលនយោបាយ ព្រមទាំងការវាយតម្លៃផែនការសកម្មភាពរួម និងផែនការសកម្មភាពលម្អិតរបស់អង្គភាព និងស្ថាប័ន, (៤) ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដែលបានបែងចែកជា ២ លក្ខខណ្ឌ គឺលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌសមិទ្ធកម្ម, និងចុងក្រោយ (៥) គឺការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគាំទ្រដល់ការគ្រប់គ្រងសមិទ្ធកម្មទាំងមូល។ ខ្ញុំជឿជាក់ថា គោលការណ៍ណែនាំនេះ នឹងក្លាយជាឧបករណ៍ថ្មីមួយជួយជំរុញ

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលទី៤នេះ ឱ្យសម្រេចបានដល់កម្ពស់នៃវឌ្ឍនភាពតាមគោលដៅរំពឹងទុក។

ជាចុងក្រោយ, ក្នុងនាម **អ.គ.ហ.** និងរូបខ្ញុំផ្ទាល់ សូមសម្តែងការដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.** ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ និងផ្តល់អនុសាសន៍ណែនាំដ៏មានតម្លៃ និងតម្រង់ទិសលើការរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្ម ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រហូតទទួលបានជោគជ័យ និងបានដាក់ឱ្យអនុវត្តនាពេលនេះ។ ទន្ទឹមនេះ, ខ្ញុំសូមថ្លែងអំណរគុណ ជូនចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត ក្រសួង ស្ថាប័ន ដែលបានចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដៃគូអភិវឌ្ឍក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការ ដើម្បីរួមចំណែកទាំងជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីដំណាក់កាលទី១ រហូតមកដល់ដំណាក់កាលទី៤ នាពេលនេះ៕

ថ្ងៃព្រហស្បតិ៍ ១២កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែឧសភា គ.ស. ២០២៥

**រដ្ឋលេខាធិការ**
**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកានុក្រម


**បុព្វកថា** ..... i
**អារម្ភកថា** ..... iii
**មាតិកានុក្រម** ..... v
**ជំពូក ១. សេចក្តីផ្តើម** ..... **១**
១.១. សាវតារ ..... ១
១.២. គោលបំណង និងវិសាលភាព ..... ២
១.៣. រចនាសម្ព័ន្ធនៃគោលការណ៍ណែនាំ ..... ៣
**ជំពូក ២. ក្របខ័ណ្ឌស្ថាប័ន និងរចនាសម្ព័ន្ធគ្រប់គ្រង** ..... **៤**
២.១. ក្របខ័ណ្ឌស្ថាប័ន ..... ៤
២.២. រចនាសម្ព័ន្ធគ្រប់គ្រង ..... ៦
**ជំពូក ៣. ទស្សនទាន និងគោលការណ៍នៃការគ្រប់គ្រងសមិទ្ធកម្ម** ..... **៩**
៣.១. ទស្សនទាន និងសារសំខាន់នៃការគ្រប់គ្រងសមិទ្ធកម្ម ..... ៩
៣.២. រចនាសម្ព័ន្ធសមិទ្ធកម្ម ..... ១០
៣.៣. ទិដ្ឋភាពទូទៅ និងវដ្តនៃការគ្រប់គ្រងសមិទ្ធកម្ម ..... ១៣
**ជំពូក ៤. ការរៀបចំផែនការសមិទ្ធកម្ម** ..... **១៥**
៤.១. ផែនការសកម្មភាពរួម ..... ១៥
៤.២. លទ្ធផលគន្លឹះក្នុងឆ្នាំ ..... ១៩
៤.៣. ផែនការសកម្មភាពលម្អិត ..... ២១
៤.៤. ផែនការថវិកា ..... ២៣
៤.៥. ផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ ..... ២៦
៤.៦. កិច្ចព្រមព្រៀងសមិទ្ធកម្ម ..... ២៧
**ជំពូក ៥. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្ម** ..... **២៩**
៥.១. វិធីសាស្ត្រត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្ម ..... ២៩
៥.២. ការរៀបចំរបាយការណ៍សមិទ្ធកម្ម ..... ៣៦
៥.៣. ការរៀបចំកិច្ចប្រជុំត្រួតពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់ ..... ៣៦
**ជំពូក ៦. ការលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម** ..... **៣៨**
៦.១. លក្ខខណ្ឌទូទៅ ..... ៣៨
៦.២. លក្ខខណ្ឌសមិទ្ធកម្ម ..... ៣៨
**ជំពូក ៧. ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងសមិទ្ធកម្ម** ..... **៤០**
៧.១. ទិដ្ឋភាពទូទៅ ..... ៤០
៧.២. មុខងារសំខាន់ៗនៃប្រព័ន្ធ PMIS ..... ៤១
៧.៣. គោលការណ៍ណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធ PMIS ..... ៤២
**ជំពូក ៨. សេចក្តីសន្និដ្ឋាន** ..... **៤៣**
**សទ្ទានុក្រម** ..... **៤៤**
**ឧបសម្ព័ន្ធ** ..... **៤៦**

# បញ្ជីអក្សរកាត់

| | |
|---|---|
| ក.ប.ហ. | ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ក.ហ.ស. | ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| គ.ក.ច. | គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ |
| គ.ក.ប.យ. | គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ |
| គ.ក.រ | គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ |
| គ.ក.ហ. | គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ |
| គ.ហ.ស. | គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| ស.គ | សូចនាករគោលបំណង |
| ស.ច | សូចនាករចង្កោមសកម្មភាព |
| អ.គ.ហ. | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| BSP | Budget Strategic Plan - ផែនការយុទ្ធសាស្ត្រថវិកា |
| CAP4 | Consolidated Action Plan Stage 4 - ផែនការសកម្មភាពរួម ដំណាក់កាលទី ៤ |
| DPC | Development Partner Committee |
| GDAP | General Departments Action Plan - ផែនការសកម្មភាពរបស់អគ្គនាយកដ្ឋាន |
| FMIS | Financial Management Information System - ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| KPI | Key Performance Indicator - សូចនាករសមិទ្ធកម្មគន្លឹះ |
| MAP | Ministries Action Plan - ផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន |
| NRMIS | Non-tax Revenue Management Information System |
| PDAP | Provincial Department of Economy and Finance Action Plan |
| PEFA | Public Expenditure and Financial Accountability |
| PFM-TWG | Public Financial Management Technical Working Group |
| PMIS | Performance Management Information System - ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងសមិទ្ធកម្ម |
| SARMIS | State Asset Register Management Information System |
| CPAP | Capital/Provincial Action Plan - ផែនការសកម្មភាពរបស់រដ្ឋបាលរាជធានី ខេត្ត |
| VAT | Value Added Tax - អាករលើតម្លៃបន្ថែម |

# បញ្ជីដ្យាក្រាម

ដ្យាក្រាម ១ ៖ ក្របខ័ណ្ឌស្ថាប័ន និងរចនាសម្ព័ន្ធគ្រប់គ្រង
ដ្យាក្រាម ២ ៖ ខ្សែសង្វាក់លទ្ធផល
ដ្យាក្រាម ៣ ៖ រចនាសម្ព័ន្ធ និងខ្សែសង្វាក់លទ្ធផលនៃការគ្រប់គ្រងផ្អែកលើលទ្ធផល
ដ្យាក្រាម ៤ ៖ វដ្តនៃការគ្រប់គ្រងសមិទ្ធកម្ម
ដ្យាក្រាម ៥ ៖ រចនាសម្ព័ន្ធក្របខ័ណ្ឌផែនការសកម្មភាពរួម
ដ្យាក្រាម ៦ ៖ យន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់

# បញ្ជីតារាង

តារាងទី ១ ៖ ទម្រង់ផែនការសកម្មភាពរួម ដំណាក់កាលទី៤
តារាងទី ២ ៖ ទម្រង់លទ្ធផលគន្លឹះក្នុងឆ្នាំ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
តារាងទី ៣ ៖ ទម្រង់ផែនការសកម្មភាពលម្អិត នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
តារាងទី ៤ ៖ ទម្រង់ផែនការថវិកា នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
តារាងទី ៥ ៖ ក្របខ័ណ្ឌពេលវេលានៃការរៀបចំផែនការ
តារាងទី ៦ ៖ ទម្រង់របាយការណ៍ផែនការសកម្មភាពរួម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
តារាងទី ៧ ៖ ទម្រង់របាយការណ៍អនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
តារាងទី ៨ ៖ ទម្រង់របាយការណ៍អនុវត្តផែនការសកម្មភាពលម្អិតប្រចាំត្រីមាស/ឆ្នាំ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# ជំពូក ១. សេចក្តីផ្តើម

## ១.១. សាវតារ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តដោយប្រមុខរាជរដ្ឋាភិបាល ចាប់តាំងពីឆ្នាំ២០០៤ ដោយបានកំណត់ចក្ខុវិស័យច្បាស់លាស់ គឺ "**ការប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ពីប្រព័ន្ធផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការ ទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដា និងឧត្តមានុវត្តន៍ជាអន្តរជាតិ**"។ ឈរលើមាគ៌ាដ៏ត្រឹមត្រូវ និងប្រកបដោយក្តីសង្ឃឹម ក្នុងរយៈពេលជាង ២០ ឆ្នាំកន្លងមកនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបង្កើតសមិទ្ធផលជាប្រវត្តិសាស្ត្រជាច្រើនជូនរាជរដ្ឋាភិបាល ទាំងសមិទ្ធផលក្នុងការកែលម្អអភិបាលកិច្ចនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទាំងសមិទ្ធផលក្នុងទិដ្ឋភាពនៃការរីកចម្រើនផ្នែកសង្គម-សេដ្ឋកិច្ច។ ការកែទម្រង់នេះ គ្រប់ដណ្តប់លើដំណាក់កាលសំខាន់ៗទាំងអស់នៃវដ្តថវិកាគឺ៖ ការរៀបចំថវិកា និងការអនុម័តថវិកា ការអនុវត្តថវិកា និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផល។ ផ្អែកតាមក្របខ័ណ្ឌនេះ រាជរដ្ឋាភិបាលកម្ពុជានឹងកសាងបាននូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយរឹងមាំ ដែលឈានទៅសម្រេចបានលទ្ធផលចុងក្រោយនៃការគ្រប់គ្រងហិរញ្ញវត្ថុទាំង ៣ នោះគឺ៖ (១) បូរណភាពនៃការគោរពវិន័យថវិកា, (២) ប្រសិទ្ធភាពថវិកា ទាំងផ្នែកវិភាជន៍ និងផ្នែកប្រតិបត្តិការ និង (៣) ស័ក្តិសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ។

ក្នុងគោលដៅសម្រេចបាននូវចក្ខុវិស័យ និងយុទ្ធសាស្ត្រ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានបង្កើតរចនាសម្ព័ន្ធដឹកនាំ និងសម្របសម្រួលការរៀបចំ ការអនុវត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងនោះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ដែលមាន អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ជាសេនាធិការ បានបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាពខ្ពស់ ជាមួយនឹងការឧទ្ទិសខ្លួនចំពោះការងារកែទម្រង់ឱ្យសម្រេចបានសមិទ្ធផលគន្លឹះៗជាច្រើនកន្លងមក។

បច្ចុប្បន្ន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានដល់ដំណាក់កាលចុងក្រោយរបស់ខ្លួនគឺ "**គណនេយ្យភាពសមិទ្ធកម្ម**" ដែលជាដំណាក់កាលកែទម្រង់ស៊ីជម្រៅ ដោយសម្រួចទិស និងតម្រង់គោលដៅឆ្ពោះទៅរក "**សមិទ្ធកម្ម ឬ លទ្ធផល**" និងមានគោលដៅចម្បងក្នុងការកសាងផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាពសំដៅពង្រឹងប្រសិទ្ធភាព, គុណភាព និងការទទួលខុសត្រូវលើសមិទ្ធកម្ម ឬ លទ្ធផលនៃការអនុវត្តរបស់ស្ថាប័នសាធារណៈ និងមន្ត្រីរាជការក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូល។ ក្នុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរលេខ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ សារាចរនេះ បានកំណត់ពីយន្តការស្ថាប័ន, នីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដានផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវិធានការលើកទឹកចិត្ត និងវិធានការរឹតត្បិតសម្រាប់អង្គភាពក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ផ្អែកតាមបទពិសោធន៍នៃការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកន្លងមក, **គ.ហ.ស.** បានពិនិត្យឡើងវិញលើក្របខ័ណ្ឌគ្រប់គ្រងសមិទ្ធកម្ម ដោយផ្អែកលើបទដ្ឋានគតិយុត្តដែលមានជាធរមាន និងគម្លាតនៃការអនុវត្តជាក់ស្តែង សំដៅពង្រឹងការផ្សារភ្ជាប់គ្នាឱ្យបានរឹងមាំរវាងទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពសមិទ្ធកម្ម ដែលត្រូវសម្រេចឱ្យបានដោយអង្គភាព/ស្ថាប័នអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងន័យនេះ **គ.ហ.ស.** បានរៀបចំ (១) សារាចរលេខ១៤ សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤

ស្តីពីការគ្រប់គ្រងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (២) ប្រកាសលេខ ៩៨៨ សហវ.ប្រក.អគហ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីគោលការណ៍ យន្តការ នីតិវិធី និងការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, (៣) ប្រកាសលេខ ៩៨៧ សហវ.ប្រក.អគហ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីគោលការណ៍ យន្តការ នីតិវិធី និងការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត និង (៤) គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្មនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ជាឯកសារមគ្គុទេសក៍ ក្នុងកិច្ចដំណើរការនៃការរៀបចំការអនុវត្ត និង ការត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅលើកកម្ពស់សមិទ្ធកម្មឆ្ពោះទៅរកប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាពខ្ពស់។

## ១.២. គោលបំណង និងវិសាលភាព

### ❖ គោលបំណង

គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្ម ត្រូវបានរៀបចំឡើងដើម្បីបំពេញបន្ថែមលើ សារាចរលេខ១៤ សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ឧបសម្ព័ន្ធ១) សម្រាប់ជាឯកសារមគ្គុទេសក៍ដែលប្រមូលផ្តុំនូវ គោលការណ៍ នីតិវិធី និងវិធានសម្រាប់ការគ្រប់គ្រងសមិទ្ធកម្ម ទៅតាមសមាសធាតុនិងដំណាក់កាលនីមួយៗ ដែលរួមមានជាអាទ៍៖ ដំណាក់កាលរៀបចំផែនការសមិទ្ធកម្ម, ដំណាក់កាលត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្ម, ដំណាក់កាលនៃការលើកទឹកចិត្តនិងវិតត្បិតផ្អែកលើសមិទ្ធកម្ម និង ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងសមិទ្ធកម្ម (Performance Management Information System – PMIS) ដើម្បីបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាពចំពោះសមិទ្ធកម្ម។ គោលការណ៍ណែនាំនេះ នឹងផ្តល់នូវទស្សនទានសំខាន់ៗ រួមមាន៖

- **ភាពច្បាស់លាស់ (Clarity)៖** ផ្តល់នូវទិដ្ឋភាព ឬ ទម្រង់ច្បាស់លាស់មួយនៃក្របខ័ណ្ឌលទ្ធផល និងសមិទ្ធកម្ម ក្នុងការរៀបចំផែនការ និងការគ្រប់គ្រងផ្តោតលើលទ្ធផល
- **ការផ្តោត (Focus)៖** លើកកម្ពស់សង្គតិភាពរវាងយុទ្ធសាស្ត្រ (ផែនការសកម្មភាពរួម) និងផែនការប្រតិបត្តិ (ផែនការសកម្មភាពរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន) ដើម្បីឱ្យការអនុវត្តសកម្មភាព និងការប្រើប្រាស់ធាតុចូលឆ្លើយតបទៅនឹងគោលដៅដែលបានកំណត់
- **ការធ្វើឱ្យប្រសើរឡើង (Improvement)៖** ត្រួតពិនិត្យ និងជំរុញការសម្រេចបានធាតុចេញ/លទ្ធផលក្នុងឆ្នាំ និងលទ្ធផលរយៈពេលមធ្យម, ការកំណត់សូចនាករលទ្ធផលនៃគោលបំណង និងសូចនាករសមិទ្ធកម្មគន្លឹះនៃចង្កោមសកម្មភាពនីមួយៗ។

### ❖ វិសាលភាព

គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្ម មានវិសាលភាពអនុវត្តចំពោះគ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលគ្របដណ្តប់ដល់អគ្គនាយកដ្ឋាន, អង្គភាព និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានី ខេត្ត ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។

## ១.៣. រចនាសម្ព័ន្ធនៃគោលការណ៍ណែនាំ

ឯកសារនេះ ចែកចេញជា ៨ ជំពូក រួមមាន៖

**ជំពូក ១. សេចក្តីផ្តើម៖** រៀបរាប់ដោយសង្ខេបអំពីសាវតារ, ចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យន្តការស្ថាប័នសម្រាប់អនុវត្ត និងឆ្លុះបញ្ចាំងអំពីគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ដោយសម្រួចការរៀបចំក្របខ័ណ្ឌសមិទ្ធកម្មឆ្ពោះទៅរក "**សមិទ្ធកម្ម ឬ លទ្ធផល**"។ ជំពូកនេះ ក៏គូសរំលេចផងដែរអំពីមូលហេតុ និងគោលបំណងដែលតម្រូវឱ្យរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្មនេះឡើង។

**ជំពូក ២. ក្របខ័ណ្ឌស្ថាប័ន និងរចនាសម្ព័ន្ធគ្រប់គ្រង៖** បង្ហាញពីទិដ្ឋភាពរួមនៃយន្តការស្ថាប័នក្នុងការអនុវត្តគោលការណ៍ណែនាំនេះ។ ជំពូកនេះក៏រៀបរាប់អំពីភាពប្រទាក់ក្រឡាគ្នារវាងស្ថាប័នគ្រប់គ្រង និងភ្នាក់ងារអនុវត្តដែលបង្ហាញពីរចនាសម្ព័ន្ធដឹកនាំ និងគ្រប់គ្រងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (យន្តការគ្រប់គ្រង និងសម្របសម្រួល ព្រមទាំងការទទួលខុសត្រូវនៃអង្គភាពនីមួយៗ)។

**ជំពូក ៣. ទស្សនទាន និងគោលការណ៍នៃការគ្រប់គ្រងសមិទ្ធកម្ម៖** នឹងបង្ហាញអំពីគោលការណ៍ និងនីតិវិធីរៀបចំក្របខ័ណ្ឌលទ្ធផល ដោយផ្អែកលើវដ្តនៃប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម ដែលរួមមាន៖ ការរៀបចំផែនការសមិទ្ធកម្ម ការអនុវត្ត ការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្ម និងការលើកទឹកចិត្តនិងរឹតត្បិតផ្អែកលើសមិទ្ធកម្ម។ ជំពូកនេះ ក៏នឹងពិពណ៌នាអំពីទស្សនទាន និងរចនាសម្ព័ន្ធសមិទ្ធកម្ម ដោយប្រើប្រាស់ខ្សែសង្វាក់លទ្ធផល (Result Chain) ព្រមទាំងបញ្ជាក់អំពីការកំណត់គោលដៅសមិទ្ធកម្មប្រចាំឆ្នាំនីមួយៗ សូចនាករសមិទ្ធកម្មគន្លឹះ, លទ្ធផលគោល, វិធីសាស្ត្រវាស់វែង, និងឯកសារភស្តុតាងនៅតាមសូចនាករសមិទ្ធកម្មគន្លឹះ ចង្កោមសកម្មភាព និងគោលបំណងនីមួយៗផងដែរ។

**ជំពូក ៤. ការរៀបចំផែនការសមិទ្ធកម្ម៖** ជំពូកនេះណែនាំអំពីការរៀបចំផែនការសមិទ្ធកម្ម ព្រមទាំងបង្ហាញវិធាន និងនីតិវិធីការងារនៃការរៀបចំផែនការសកម្មភាពរួម, លទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពលម្អិត ផែនការថវិកា ផែនការលើកទឹកចិត្ត និងកិច្ចព្រមព្រៀងសមិទ្ធកម្មរវាងអង្គភាព/ស្ថាប័នអនុវត្ត ក្នុងនាមជាភ្នាក់ងារអនុវត្តគម្រោង និង **អ.គ.ហ.** ក្នុងនាមជាភ្នាក់ងារគ្រប់គ្រងគម្រោង។ ការរៀបចំផែនការសមិទ្ធកម្មតាមដំណាក់កាលនីមួយៗ នឹងណែនាំអំពីទស្សនទាន របៀបនៃការរៀបចំប្រកបដោយគុណភាព ការចរចាសមិទ្ធកម្មនិងថវិកា ព្រមទាំងក្របខ័ណ្ឌពេលវេលានៃការបញ្ចប់ការរៀបចំ និងអនុវត្ត។

**ជំពូក ៥. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្ម៖** ជំពូកនេះនឹងផ្តល់ការណែនាំអំពីកិច្ចដំណើរការក្នុងការរៀបចំរបាយការណ៍សមិទ្ធកម្មនៅគ្រប់កម្រិត ទាំងផែនការសកម្មភាពលម្អិត លទ្ធផលក្នុងឆ្នាំ និងផែនការសកម្មភាពរួម ដោយប្រើប្រាស់លក្ខខណ្ឌវាយតម្លៃជាក់លាក់ និងច្បាស់លាស់ផ្អែកលើភស្តុតាងសមិទ្ធកម្ម ជាពិសេសកំណត់យន្តការសម្រាប់ប្រើប្រាស់ព័ត៌មានសមិទ្ធកម្ម ដើម្បីបន្តកែលម្អការគ្រប់គ្រងផ្អែកលើលទ្ធផលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ លទ្ធផលនៃការវាយតម្លៃនេះ នឹងក្លាយជាមូលដ្ឋានយ៉ាងសំខាន់ក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភការងារកែទម្រង់ផ្សារភ្ជាប់សមិទ្ធកម្ម។

**ជំពូក ៦. ការលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម៖** ផ្នែកនេះ នឹងបរិយាយអំពីគោលការណ៍ យន្តការ នីតិវិធី និងការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។

**ជំពូក ៧. ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងសមិទ្ធកម្ម៖** ផ្នែកនេះ ចង្អុលបង្ហាញអំពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងសមិទ្ធកម្ម (Performance Management Information System – PMIS) ក្នុងវដ្តនៃការគ្រប់គ្រងសមិទ្ធកម្ម ដោយចាប់ផ្តើមពីការរៀបចំ ការអនុវត្ត ការរៀបចំរបាយការណ៍ និងការទាញយករបាយការណ៍របស់អង្គភាព និងស្ថាប័នអនុវត្ត។

**ជំពូក ៨. សន្និដ្ឋាន៖** បូកសរុបអំពីសារសំខាន់ និងភាពចាំបាច់នៃការដាក់ចេញគោលការណ៍ណែនាំនេះឡើងសម្រាប់មគ្គុទេសក៍ណែនាំអំពីនីតិវិធី និងវិធានសម្រាប់ការគ្រប់គ្រងសមិទ្ធកម្ម ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

# ជំពូក ២. ក្របខ័ណ្ឌស្ថាប័ន និងរចនាសម្ព័ន្ធគ្រប់គ្រង

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី១ ត្រូវបានប្រមូលផ្តុំនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលដើរតួជានិម្មាបនករផង និងប្រតិបត្តិករផង ខណៈចាប់ពីដំណាក់កាលទី២, ទី៣, និងទី៤ ការអនុវត្តចាប់ផ្តើមមានភាពប្រទាក់ក្រឡាគ្នាជាមួយនឹងតួអង្គពាក់ព័ន្ធដែលមានវិសាលភាពអនុវត្ត រួមមាន៖ ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដែលមានតួនាទីជាប្រតិបត្តិករ។ ក្នុងន័យនេះ, យន្តការស្ថាប័នសម្រាប់អនុវត្តកម្មវិធីកែទម្រង់នេះ មានលក្ខណៈបត់បែន ដែលតម្រូវឱ្យមានការពង្រឹងពង្រីក និងកែលម្អជាប្រចាំ ស្របតាមបរិការណ៍កែទម្រង់ក្នុងដំណាក់កាលនីមួយៗ។

## ២.១. ក្របខ័ណ្ឌស្ថាប័ន

ជំពូកនេះ ពណ៌នាពីក្របខ័ណ្ឌស្ថាប័ន ដែលកំណត់រចនាសម្ព័ន្ធដឹកនាំ និងរចនាសម្ព័ន្ធគ្រប់គ្រងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ដែលមានវិសាលភាពអនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្មនេះ។ ក្នុងគោលដៅជានាការអនុវត្តក្របខ័ណ្ឌផែនការសកម្មភាពរួម នៅតាមដំណាក់កាលនីមួយៗ យន្តការស្ថាប័នត្រូវបានបង្កើតឡើង ដោយបែងចែកដូចជា៖ (ក) គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**), (ខ) គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**គ.ក.ហ.**), (គ) ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) ប្រចាំក្រសួងស្ថាប័ន, (ឃ) ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) ប្រចាំរដ្ឋបាលរាជធានី ខេត្ត, និង (ង) អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**)។

### ក. គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) គឺជាស្ថាប័នដឹកនាំដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤។ ការតែងតាំងសមាសភាព **គ.ហ.ស.** ត្រូវធ្វើឡើងតាមការចាំបាច់ តាមរយៈសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។ សមាសភាពនៃ **គ.ហ.ស.** រួមមាន៖ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន, រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ជាអនុប្រធាន, ព្រមទាំងថ្នាក់ដឹកនាំមួយរូប ពីគ្រប់ក្រសួង ស្ថាប័ន ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាសមាជិក។ **គ.ហ.ស.** មានតួនាទីភារកិច្ចដឹកនាំ រៀបចំសម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ។ **គ.ហ.ស.** មានកិច្ចប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំ ដែលជាវេទិកាកម្រិតនយោបាយ ក្នុងការត្រួតពិនិត្យតាមដានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ននីមួយៗ។

### ខ. គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ក.ហ.**) គឺជាស្ថាប័នកម្រិតបច្ចេកទេសដែលត្រូវបានបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ជាអង្គភាពស្នូលក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ **គ.ក.ហ.** ស្ថិតក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាប្រធាន និងមានសមាសភាពពីថ្នាក់ដឹកនាំក្រសួង និងប្រធាននៃគ្រប់អង្គភាពក្រោមឱវាទក្រសួងជាអនុប្រធាន និងជាសមាជិក។

**គ.ក.ហ.** មានភារកិច្ចសម្របសម្រួលការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដើរតួជាចំណុចប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការពិនិត្យសម្រេចលើចក្ខុវិស័យ គោលបំណង កម្មវិធី ផែនការសកម្មភាព និងការរៀបចំនិងតាមដានការអនុវត្តផែនការសកម្មភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងជាអ្នកសម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តផងដែរ។

ជាមួយគ្នានេះ **គ.ក.ហ.** ក៏បំពេញតួនាទីជាគណៈកម្មការដឹកនាំផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរក្នុងការត្រួតពិនិត្យលើការងារកែទម្រង់របស់ក្រុមការងារកែទម្រង់ ២ គឺៈ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុថ្នាក់កណ្តាល និងក្រុមការងារកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ❖ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំអគ្គនាយកដ្ឋាន និងអង្គភាពក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុថ្នាក់កណ្តាល

ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាក្រុមការងារបច្ចេកទេសដែលត្រូវបានបង្កើតឡើងនៅតាមអគ្គលេខាធិការដ្ឋាន, អគ្គនាយកដ្ឋាន, អគ្គាធិការដ្ឋាន, ក្រុម-ប្រឹក្សានីតិកម្ម, វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអង្គភាពថ្នាក់កណ្តាលផ្សេងទៀត។ **ក.ហ.ស.** ទាំងនេះ មានភារកិច្ចដឹកនាំនិងសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំអង្គភាពរបស់ខ្លួនដោយរៀបចំផែនការសកម្មភាពឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពរួម របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ❖ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ក.ហ.ស.** ប្រចាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាប្រតិបត្តិករដែលត្រូវបានបង្កើតឡើង ក្នុងគោលដៅបង្កើនការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាព។ ដូចគ្នាទៅនឹង **ក.ហ.ស.** ថ្នាក់កណ្តាលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរ, **ក.ហ.ស.** ប្រចាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវដឹកនាំ និងសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំអង្គភាពរបស់ខ្លួន ដោយរៀបចំផែនការសកម្មភាពឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពរួម របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## គ. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួង ស្ថាប័ន

**ក.ហ.ស.** ប្រចាំក្រសួង ស្ថាប័ន គឺជាតួអង្គប្រតិបត្តិករ និងជាក្រុមការងារបច្ចេកទេស ដែលត្រូវបានបង្កើតឡើងនៅតាមក្រសួង ស្ថាប័ននីមួយៗ។ **ក.ហ.ស.** ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់តំណាងក្រសួង ស្ថាប័ន ១ រូប ជាសមាជិក **គ.ហ.ស.** ដែលជារដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ ឬ ថ្នាក់ដឹកនាំ ដែលទទួលបន្ទុកជួយរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នផ្ទាល់លើការងារហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័នសាមី ព្រមទាំងមានថ្នាក់ដឹកនាំ និងមន្ត្រីនៅតាមអគ្គនាយកដ្ឋាន ឬនាយកដ្ឋានពាក់ព័ន្ធ ជាអនុប្រធាន និងជាសមាជិក។ លើសពីនេះ **ក.ហ.ស.** ត្រូវរៀបចំចាត់តាំងលេខាធិការមួយសម្រាប់ជាសេនាធិការក្នុងការសម្រួលសម្រួលការងាររបស់ **ក.ហ.ស.** ក្រសួង ស្ថាប័នសាមីជាមួយនឹង **អ.គ.ហ.**។ លេខាធិការ **ក.ហ.ស.** ត្រូវមានចំនួនសមាសភាពតាមការចាំបាច់ និងត្រូវចាត់តាំងលេខាធិការ ១ រូបជាមន្ត្រីបង្គោល។ **ក.ហ.ស.** ប្រចាំក្រសួង ស្ថាប័នមានភារកិច្ចដឹកនាំ និងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ

សាធារណៈប្រចាំក្រសួង ស្ថាប័នរបស់ខ្លួន ព្រមទាំងជាអ្នកសម្របសម្រួលរៀបចំនិងកែតម្រូវផែនការសកម្មភាពលម្អិតប្រចាំក្រសួង ស្ថាប័នរបស់ខ្លួន ឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពរួម។

### ឃ. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំរដ្ឋបាលរាជធានី ខេត្ត

**ក.ហ.ស.** ប្រចាំរដ្ឋបាលរាជធានី ខេត្ត ជាក្រុមការងារបច្ចេកទេសក្នុងនាមជាប្រតិបត្តិករ ដែលត្រូវបង្កើតឡើងក្នុងគោលបំណងពង្រឹងការទទួលខុសត្រូវលើសមិទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ **ក.ហ.ស.** ស្ថិតក្រោមការដឹកនាំផ្ទាល់របស់អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ជាប្រធាន និងជាសមាជិក **គ.ហ.ស.**។ **ក.ហ.ស.** ប្រចាំរដ្ឋបាលរាជធានី ខេត្ត ត្រូវមានអភិបាលរងដែលទទួលបន្ទុកហិរញ្ញវត្ថុ ឬបំពេញការងារផ្ទាល់ជាមួយប្រធាន **ក.ហ.ស.** ជាអនុប្រធានប្រចាំការ និងមានអភិបាលរង នាយករដ្ឋបាល និងនាយកទីចាត់ការ តាមការចាំបាច់ជាសមាជិក។ ជាមួយគ្នានេះ **ក.ហ.ស.** ប្រចាំរដ្ឋបាលរាជធានី ខេត្ត ត្រូវមានលេខាធិការ **ក.ហ.ស.** និងត្រូវចាត់តាំងមន្ត្រីបង្គោល ១ រូប សម្រាប់សម្របសម្រួលការងារជាមួយ **អ.គ.ហ.** និងផ្ទៃក្នុងរដ្ឋបាលរាជធានី ខេត្តសាមី។ **ក.ហ.ស.** មានភារកិច្ចដឹកនាំនិងអនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួន ព្រមទាំងជាអ្នកសម្របសម្រួលរៀបចំនិងកែតម្រូវផែនការសកម្មភាពលម្អិតប្រចាំរដ្ឋបាលរាជធានី ខេត្តរបស់ខ្លួនឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពរួម។

### ង. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**អ.គ.ហ.** ត្រូវបានបង្កើតឡើងដើម្បីជាសេនាធិការឱ្យ **គ.ហ.ស.** តាមរយៈអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ **អ.គ.ហ.** មានភារកិច្ចសម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.ហ.ស.** រួមទាំងការរៀបចំដាក់ឱ្យអនុវត្ត និងការតាមដានត្រួតពិនិត្យគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បន្ថែមលើនេះ **អ.គ.ហ.** ក៏មានភារកិច្ចជាសេនាធិការឱ្យ **គ.ក.ហ.** ផងដែរក្នុងការសហការ និងសម្របសម្រួលជាមួយ **ក.ហ.ស.** ប្រចាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជាជំនួយដល់ការរៀបចំផែនការសមិទ្ធកម្ម និងតាមដានការអនុវត្តការងារកែទម្រង់របស់ **ក.ហ.ស.** ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ **អ.គ.ហ.** ក៏មានតួនាទីស្នូលក្នុងការជំរុញការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួង ស្ថាប័ន និងប្រចាំរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ២.២. រចនាសម្ព័ន្ធគ្រប់គ្រង

ក្នុងគោលដៅធានាបាននូវការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យការអនុវត្តស្របតាមសភាពការណ៍ និងបរិបទជាក់ស្តែងរបស់កម្ពុជាផង និងស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិផង, ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ប.ហ.**) ឬ ជាភាសាអង់គ្លេស Public Financial Management Technical Working Group (PFM-TWG) ត្រូវបានបង្កើតឡើង ក្នុងគោលបំណងជាយន្តការ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។ **ក.ប.ហ.** មានសមាសភាពមកពី **គ.ហ.ស.** ដែលតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការដៃគូអភិវឌ្ឍ (Development Partner Committee; DPC) ដែលតំណាងឱ្យដៃគូអភិវឌ្ឍ។ DPC ផ្តល់អនុសាសន៍ក្នុងការរៀបចំផែនការសកម្មភាពរួម

ដំណាក់កាលទី៤ (CAP4) និងផ្ដល់អនុសាសន៍លើរបាយការណ៍តាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**គ.ហ.ស.** ទាំងអស់មានតួនាទីនិងភារកិច្ចរៀបចំ, អនុវត្ត និងត្រួតពិនិត្យវាយតម្លៃការអនុវត្តផែនការសកម្មភាពរបស់ខ្លួន។ **គ.ហ.ស.** ត្រូវរៀបចំឱ្យមានកិច្ចប្រជុំប្រចាំខែ ក្រោមការដឹកនាំរបស់ប្រធាន **គ.ហ.ស.** ឬអនុប្រធាន តាមការចាត់តាំង ដើម្បីតាមដានវឌ្ឍនភាពការងារ និងចាត់វិធានការដោះស្រាយបញ្ហាប្រឈមនានាដែលរាំងស្ទះដល់ការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទន្ទឹមនេះ ដើម្បីធានាថាការអនុវត្តសកម្មភាពស្ថិតក្នុងគន្លងឆ្ពោះទៅសម្រេចនូវផែនការដែលបានគ្រោងទុក ការត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់ត្រូវបានធ្វើឡើងប្រចាំត្រីមាស និងឆ្នាំ និងត្រូវបានធ្វើឡើងជា ៣ កម្រិតរួមមាន៖ (១) កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ក.ហ.**), (២) កិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) និង (៣) កិច្ចប្រជុំគណៈ-កម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយតំណាងដៃគូអភិវឌ្ឍ (**គ.ប.ហ.**)។ ការរៀបចំកិច្ចប្រជុំត្រួតពិនិត្យសមិទ្ធកម្មទាំង ៣ កម្រិតនេះមានលម្អិតនៅក្នុងជំពូកទី ៥ **ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្ម** ក្នុងចំណុច **៥.៣.** "**ការរៀបចំកិច្ចប្រជុំតាមដាននិងវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់**"។

*ដ្យាក្រាម ១ ៖ ក្របខ័ណ្ឌស្ថាប័ន និងរចនាសម្ព័ន្ធគ្រប់គ្រង*



# ជំពូក ៣. ទស្សនទាន និងគោលការណ៍នៃការគ្រប់គ្រងសមិទ្ធកម្ម

ទស្សនទាននៃការគ្រប់គ្រងសមិទ្ធកម្ម គឺជាបន្ទាត់គោលគន្លឹះមួយសម្រាប់រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្មក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីជានាប្រសិទ្ធភាពនៃវិធាន នីតិវិធី និងដំណើរការដែលមានលក្ខណៈស្តង់ដាររួមមួយដែលសមស្របទៅនឹងបរិបទកម្ពុជាផង និងអន្តរជាតិផង។ ដូចនេះ គោលការណ៍ណែនាំនេះ គឺជាស្តង់ដាររួមសម្រាប់គ្រប់អង្គភាពរៀបចំលទ្ធផលក្នុងឆ្នាំរបស់ខ្លួនទៅតាមក្របខ័ណ្ឌសមិទ្ធកម្ម ដោយចាប់ផ្តើមពីការកំណត់លទ្ធផលចុងក្រោយ (Outcomes), លទ្ធផលក្នុងឆ្នាំ (Outputs), សកម្មភាព (Activities) តាមជំហានៗ រួមមាន៖ (១) ជ្រើសរើសសូចនាករសមិទ្ធកម្មគន្លឹះ (KPIs), (២) កំណត់ទិន្នន័យមូលដ្ឋាន (Baselines) និង (៣) កំណត់គោលដៅសូចនាករសម្រាប់លទ្ធផលនីមួយៗ (Targets)។ លើសពីនេះ "ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងសមិទ្ធកម្ម" នឹងក្លាយជាឆ្អឹងខ្នងនៃការជំរុញការអនុវត្តក្របខ័ណ្ឌខាងលើប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាស្របតាមថ្នាលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

## ៣.១. ទស្សនទាន និងសារសំខាន់នៃការគ្រប់គ្រងសមិទ្ធកម្ម

ការគ្រប់គ្រងសមិទ្ធកម្ម គឺជាអភិក្រមនៃការគ្រប់គ្រងដែលផ្តោតលើសមិទ្ធកម្មនិងលទ្ធផល ដែលត្រូវសម្រេចបាន ដោយផ្អែកលើវដ្តនៃប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម រួមមាន៖ ការរៀបចំផែនការសមិទ្ធកម្ម ការអនុវត្ត ការត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្ម និងការលើកទឹកចិត្តនិងរឹតត្បិតផ្អែកលើសមិទ្ធកម្ម។ ការគ្រប់គ្រងសមិទ្ធកម្មគឺមានសារៈសំខាន់ក្នុងសម្រួចលទ្ធផល ឬ សមិទ្ធកម្ម ដើម្បីឆ្ពោះទៅសម្រេចបាននៅគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជារួម ការគ្រប់គ្រងសមិទ្ធកម្មប្រកបដោយប្រសិទ្ធភាពនឹងផ្តល់ទិដ្ឋភាពកាន់តែច្បាស់លាស់ដល់ដំណើរការនៃការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម៖

- ការផ្សារភ្ជាប់លទ្ធផលក្នុងឆ្នាំទៅនឹងក្របខ័ណ្ឌសមិទ្ធកម្ម៖ ជានាថា ការរៀបចំ និងការអនុវត្តសកម្មភាព គឺស្ថិតក្នុងគន្លងឆ្ពោះទៅសម្រេចនូវចង្កោមសកម្មភាព និងគោលបំណងនៃក្របខ័ណ្ឌផែនការសកម្មភាពរួមរបស់កម្មវិធីកែទម្រង់។
- ប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងវាយតម្លៃ៖ ការគ្រប់គ្រងសមិទ្ធកម្មគ្រប់ជ្រុងជ្រោយ ត្រូវមានយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់ និងត្រូវអនុវត្តជាប្រចាំ។ ការត្រួតពិនិត្យ និងវាយតម្លៃនេះនឹងកំណត់នូវបញ្ហាប្រឈម កត្តារាំងស្ទះដល់ការអនុវត្ត ដើម្បីលើកជាវិធានការជំរុញ និងកែលម្អប្រសិទ្ធភាពនៃការអនុវត្តក្នុងគោលដៅលើកកម្ពស់សមិទ្ធកម្ម។
- ការលើកកម្ពស់សមិទ្ធកម្ម៖ បង្កើនគណនេយ្យភាពសមិទ្ធកម្ម និងភាពជាម្ចាស់ដោយបង្កើនការទទួលខុសត្រូវចំពោះការអនុវត្តផែនការរបស់អង្គភាព ឬ ស្ថាប័នសាមី តាមរយៈការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពជាប្រចាំ។
- ការលើកទឹកចិត្តផ្សារភ្ជាប់សមិទ្ធកម្ម៖ ការគ្រប់គ្រងសមិទ្ធកម្មដែលមានប្រសិទ្ធភាពនឹងជួយដល់ការវាយតម្លៃសមិទ្ធកម្មសម្រាប់ជាមូលដ្ឋានក្នុងការផ្តល់ការលើកចិត្ត ឬ រឹតត្បិតផ្អែកហិរញ្ញវត្ថុ។

## ៣.២. រចនាសម្ព័ន្ធសមិទ្ធកម្ម

ការគ្រប់គ្រងសមិទ្ធកម្ម ត្រូវប្រើប្រាស់ "ខ្សែសង្វាក់លទ្ធផល - Result Chain" សម្រាប់ការរៀបចំផែនការ ការអនុវត្ត ការត្រួតពិនិត្យនិងវាយតម្លៃ និងការគ្រប់គ្រងសមិទ្ធកម្មទាំងមូល ដើម្បីផ្លាស់ប្តូរវប្បធម៌ស្ថាប័ន ពីការគ្រប់គ្រងផ្អែកលើធាតុចូល ទៅជាការផ្តោតការយកចិត្តទុកដាក់លើសមិទ្ធកម្មការងារដែលសម្រេចបានតាមគោលដៅសូចនាករលទ្ធផលគន្លឹះវិញ។ ខ្សែសង្វាក់លទ្ធផល គឺជាហំហូរនៃលទ្ធផលដែលមានលក្ខណៈតក្កកម្ម (Logical Flow) ដែលប្រទាក់ក្រឡាពីលទ្ធផលមួយទៅលទ្ធផលមួយទៀត តាមរយៈការប្រើប្រាស់ធាតុចូល ដើម្បីសម្រេចបានសមិទ្ធកម្មបន្តគ្នា។ ខ្សែសង្វាក់លទ្ធផលនេះ ត្រូវបានទទួលស្គាល់ជាអន្តរជាតិ ព្រមទាំងបាននិងកំពុងប្រើប្រាស់យ៉ាងទូលំទូលាយនៅតាមបណ្តាស្ថាប័ននៃប្រទេសនានា។ ការប្រើប្រាស់ខ្សែសង្វាក់លទ្ធផលនឹងផ្តល់នូវវិធីសាស្ត្រវាយតម្លៃសមិទ្ធកម្មដែលជាមូលដ្ឋានសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នៅគ្រប់កម្រិត រួមមាន៖ គោលបំណង ចង្កោមសកម្មភាព លទ្ធផលក្នុងឆ្នាំ និងសកម្មភាពលម្អិត។ លទ្ធផលនៃការវាយតម្លៃនេះ ត្រូវបានប្រើប្រាស់សម្រាប់ត្រួតពិនិត្យមើលឡើងវិញនូវក្របខ័ណ្ឌផែនការសកម្មភាពរួម ដើម្បីកែសម្រួល និងកែលម្អសម្រាប់ឆ្ពោះទៅអនុវត្តនៅឆ្នាំ ឬដំណាក់កាលបន្ទាប់។

*ដ្យាក្រាម ២ ៖ ខ្សែសង្វាក់លទ្ធផល*




*ដ្យាក្រាម ៣ ៖ រចនាសម្ព័ន្ធ និងខ្សែសង្វាក់លទ្ធផលនៃការគ្រប់គ្រងផ្អែកលើលទ្ធផល*



ក្នុងជង្វាក្រោមទី ៣ **គ.ហ.ស.** រៀបចំសៀវភៅចក្ខុវិស័យ និងបេសកកម្មនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ និងបានកំណត់ក្របខ័ណ្ឌផែនការសកម្មភាពរួម រយៈពេល ៥ឆ្នាំ ២០២៣-២០២៧។ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនៃការអនុវត្ត ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្ម, ផែនការសកម្មភាពរួមត្រូវបានកំណត់គោលដៅសមិទ្ធកម្មប្រចាំឆ្នាំនីមួយៗ ដោយបញ្ជាក់អំពីសូចនាករសមិទ្ធកម្មគន្លឹះ, លទ្ធផលគោល, វិធីសាស្ត្រវាស់វែង, គោលដៅ និងឯកសារភស្តុតាង នៅតាមសូចនាករសមិទ្ធកម្មគន្លឹះ ចង្កោមសកម្មភាព និងគោលបំណងនីមួយៗ។

## ❖ ចក្ខុវិស័យ

ចក្ខុវិស័យជាសេចក្តីប្រាថ្នា ឬ គោលដៅចុងក្រោយដែលកម្មវិធីកែទម្រង់ចង់បានបន្ទាប់ពីអនុវត្តផែនការសកម្មភាពរួម ឆ្នាំ២០២៣-២០២៧។ ចក្ខុវិស័យរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺ **"ការប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ពីប្រព័ន្ធផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការ ទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដា និងឧត្តមានុវត្តន៍ជាអន្តរជាតិ"**។ ការសម្រេចបាននូវចក្ខុវិស័យនេះ នឹងធ្វើឱ្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាកាន់តែមានភាពរឹងមាំ និងឈានទៅសម្រេចបានលទ្ធផលចុងក្រោយទាំង ៣ រួមមានៈ បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកា (ទាំងក្នុងផ្នែកវិភាជន៍ និងក្នុងផ្នែកប្រតិបត្តិការ), និងស័ក្តិសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ។

## ❖ យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រ គឺជាការអភិក្រមដើម្បីកំណត់ទិសដៅក្នុងការឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យរយៈពេលវែង។ យុទ្ធសាស្ត្រកម្មវិធីកែទម្រង់ត្រូវបានកំណត់អភិក្រមជាខឿន ឬ ដំណាក់កាល, អភិក្រមនេះ មានលក្ខណៈពិសេស ៣ យ៉ាងគឺៈ (១) ការកែទម្រង់ក្នុងខឿននីមួយៗ ឬ ដំណាក់កាលនីមួយៗ ត្រូវមានគោលបំណងស្នូលច្បាស់លាស់ ដែលឆ្លើយតបទៅនឹងចក្ខុវិស័យនៃកម្មវិធីកែទម្រង់, (២) ការកែទម្រង់ក្នុងខឿននីមួយៗ ឬ ដំណាក់កាលនីមួយៗ ត្រូវជាមូលដ្ឋានសម្រាប់ការកែទម្រង់ក្នុងខឿនបន្តបន្ទាប់, និង (៣) សមិទ្ធផលផ្សេងៗដែលសម្រេចបានក្នុងខឿនមុនៗ ឬ ដំណាក់កាលមុនៗ ត្រូវបន្តពង្រឹងបន្ថែមក្នុងខឿន ឬ ដំណាក់កាលបន្តបន្ទាប់។

## ❖ គោលបំណង/លទ្ធផលចុងក្រោយ

គោលបំណង ជាកម្មវិធី ឬ គម្រោងដែលត្រូវសម្រេចឱ្យបានក្នុងរយៈពេលមធ្យម។ ការសម្រេចបាននូវគោលបំណង នឹងចូលរួមសម្រេចបានផែនការសកម្មភាពរួម ព្រមទាំងរួមចំណែកសម្រេចបានបន្តគ្នានូវចក្ខុវិស័យរបស់កម្មវិធីកែទម្រង់។ គោលបំណងត្រូវគ្រោងឡើងតាមអភិក្រមទាំង ៣ ខាងលើ ដោយជ្រកក្រោមផ្នែកនីមួយៗ នៃក្របខ័ណ្ឌផែនការសកម្មភាពរួម។

## ❖ ចង្កោមសកម្មភាព

ចង្កោមសកម្មភាព ជាអនុកម្មវិធី ឬ អនុគម្រោង សម្រាប់អនុវត្តដើម្បីសម្រេចបានគោលបំណងរបស់ផែនការសកម្មភាពរួម ឆ្នាំ២០២៣-២០២៧។ គោលបំណង ១ មានចង្កោមសកម្មភាពច្រើនតាមការចាំបាច់។ រាល់គោលបំណង និងចង្កោមសកម្មភាព មានកំណត់គោលដៅសមិទ្ធកម្មប្រចាំឆ្នាំ សូចនាករសមិទ្ធកម្មគន្លឹះ លទ្ធផលគោល វិធីសាស្ត្រវាស់វែង និងភស្តុតាងសមិទ្ធកម្មដែលកំណត់អំពីភាពជោគជ័យនៃការអនុវត្ត។ ចង្កោមសកម្មភាពត្រូវសម្រេចបានតាមរយៈការអនុវត្តលទ្ធផលក្នុងឆ្នាំ និងសកម្មភាពដែលគាំទ្រចង្កោមសកម្មភាពនីមួយៗ។

### ❖ លទ្ធផលក្នុងឆ្នាំ/ធាតុចេញ

លទ្ធផលក្នុងឆ្នាំ ជាផលិតផល, ទំនិញ ឬ សេវា ដែលទទួលបានពីការអនុវត្តសកម្មភាព ហើយមានទំនាក់ទំនង និងការធ្វើឱ្យសម្រេចបានលទ្ធផលចុងក្រោយ។ លទ្ធផលក្នុងឆ្នាំ ត្រូវរៀបចំដោយសម្រួចទិសដៅឆ្ពោះទៅសម្រេចចង្កោមសកម្មភាព និងត្រូវអនុវត្តដោយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការរៀបចំលទ្ធផលក្នុងឆ្នាំត្រូវមានភាពច្បាស់លាស់ទាំងគោលដៅប្រចាំឆ្នាំ សូចនាករ និងអាចវាស់វែងសមិទ្ធកម្មបានក្នុងឆ្នាំ។

### ❖ សកម្មភាព

សកម្មភាព ជាការងារដែលត្រូវអនុវត្តតាមរយៈការប្រើប្រាស់ធាតុចូលដូចជា ថវិកា, ជំនួយបច្ចេកទេស និងធនធានផ្សេងៗទៀត ដើម្បីសម្រេចបានលទ្ធផលក្នុងឆ្នាំ។ សកម្មភាព ត្រូវរៀបចំដោយក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្សារភ្ជាប់ជាមួយលទ្ធផលក្នុងឆ្នាំ។ ការសម្រេចបានសកម្មភាព គឺជាបច្ច័យរុញច្រានដល់ការសម្រេចបាននូវលទ្ធផលក្នុងឆ្នាំផងដែរ។

### ❖ ធាតុចូល

ធាតុចូល គឺជាហិរញ្ញវត្ថុ, ធនធានមនុស្ស, សម្ភារៈ និងពេលវេលា សម្រាប់ប្រើប្រាស់ដើម្បីអនុវត្តសកម្មភាព។ ការប្រើប្រាស់ធាតុចូលត្រូវធានាឱ្យបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់។ ធាតុចូល គឺជាមូលដ្ឋានចាំបាច់ក្នុងការកំណត់លទ្ធផលក្នុងឆ្នាំ និងសកម្មភាព។ ក្នុងករណីធាតុចូលមានកម្រិត ឬ មិនគ្រប់គ្រាន់ លទ្ធផលក្នុងឆ្នាំ និងផែនការសកម្មភាពអាចត្រូវកែសម្រួលតាមលទ្ធភាពនៃធាតុចូល។

### ❖ សូចនាករសមិទ្ធកម្មគន្លឹះ

សូចនាករសមិទ្ធកម្មគន្លឹះ (Key Performance Indicator - KPI) គឺខ្នាតរង្វាស់ដែលត្រូវបានកំណត់សម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃដើម្បីបង្ហាញអំពីការសម្រេចបាននូវគោលដៅសមិទ្ធកម្ម។ សូចនាករសមិទ្ធកម្មគន្លឹះ គឺជាជំនួយសម្រាប់តម្រង់ទិសការអនុវត្ត ជាពិសេសផ្តល់នូវទិដ្ឋភាពសំខាន់ៗ ដើម្បីកែលម្អសមិទ្ធកម្មឱ្យកាន់តែមានភាពច្បាស់លាស់ និងប្រសើរជាងមុន។ សូចនាករសមិទ្ធកម្មគន្លឹះ គឺត្រូវរៀបចំឱ្យមាននៅគ្រប់កម្រិតនៃផែនការសកម្មភាពរួមរួមមាន៖ គោលបំណង ចង្កោមសកម្មភាព លទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិត។ គោលការណ៍នៃការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ គឺត្រូវមានលក្ខណៈ ដូចខាងក្រោម៖

- **ផ្តោតលើលទ្ធផល (Results-Oriented)៖** ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ (KPI) ត្រូវផ្តោតសំខាន់លើគោលដៅជាក់លាក់នៅតាមគោលបំណង ចង្កោមសកម្មភាព លទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិតនីមួយៗ
- **អាចវាស់វែងបាន (Measurable)៖** ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ (KPI) គឺអាចវាស់វែងបានតាមរយៈការកំណត់ជា បរិមាណ ឬគុណភាព ដែលត្រូវសម្រេចបានក្នុងពេលវេលាជាក់លាក់មួយ
- **ងាយយល់ (Understandable)៖** ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ (KPI) គឺត្រូវមានភាពប្រាកដនិយមសាមញ្ញ និងងាយយល់បានសម្រាប់អ្នកអនុវត្តផ្ទាល់
- **មានសុពលភាព (Valid)៖** ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ (KPI) គឺត្រូវតម្រឹមឱ្យមានសង្គតិភាព និងឆ្លុះបញ្ចាំងអំពីគោលដៅសមិទ្ធកម្ម
- **អាចទុកចិត្តបាន (Reliable)៖** ការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ (KPI) ដែលមានប្រភពទិន្នន័យច្បាស់លាស់ អាចប្រមូលនិងផ្ទៀងផ្ទាត់បាន និងមានសុក្រិតភាពទិន្នន័យ។

**សូចនាករសមិទ្ធកម្មគន្លឹះ បែងចែកជា ២ ប្រភេទ គឺ៖**

- សូចនាករមានលក្ខណៈជាបរិមាណ៖ ជាសូចនាករដែលអាចកំណត់ជាចំនួន រួមមាន៖ លេខ ចំនួន អត្រា អនុបាត មធ្យម នព្វន្ត មេដ្យាន ជាដើម។ ឧទាហរណ៍៖
  - ភាគរយនៃការអនុវត្តចំណូលថវិកាធៀបនឹងច្បាប់ថវិកា
  - ភាគរយនៃអ្នកជាប់ពន្ធបង់ VAT ទាន់ពេល
  - ចំនួនស្តង់ដាគណនេយ្យសាធារណៈកម្ពុជា
  - ចំនួនប័ណ្ណកម្មសិទ្ធិដីរដ្ឋត្រូវបានរៀបចំ
  - ចំនួនក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដាក់ឱ្យអនុវត្ត SARMIS។
- សូចនាករមានលក្ខណៈជាគុណភាព៖ សូចនាករនេះសម្រាប់វាស់វែងសមិទ្ធកម្មដែលមិនមែនជាលេខ ឬ ចំនួន ដែលជាទូទៅសូចនាករនេះ វាស់វែងលើលទ្ធផលដែលមានលក្ខណៈជាទស្សនៈ សេចក្តីយល់ឃើញ កម្រិតនៃការយល់ដឹង ឬ លទ្ធផលនៃការរៀបចំលិខិតបទដ្ឋានគតិយុត្ត ឬ លទ្ធផលនៃការវាយតម្លៃផ្សេងៗ។ បន្ថែមលើនេះ សូចនាករប្រភេទនេះ ក៏បង្ហាញអំពីក្របខ័ណ្ឌពេលវេលាក្នុងការរៀបចំ ឬ អនុវត្តការងារផ្សេងៗផងដែរ។ ឧទាហរណ៍៖
  - គុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP) របស់ក្រសួង ស្ថាប័ន ត្រូវបានវាយតម្លៃ និងកែលម្អ
  - កាលបរិច្ឆេទនៃការបិទបញ្ជប់ប្រតិបត្តិការថវិកាប្រចាំឆ្នាំ
  - ផែនការសកម្មភាព សម្រាប់ដោះស្រាយចំណាយកកស្ទះ
  - ក្របខ័ណ្ឌ និងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ច
  - ភាពទាន់ពេលវេលានៃការផ្តល់របាយការណ៍។

## ៣.៣. ទិដ្ឋភាពទូទៅ និងវដ្តនៃការគ្រប់គ្រងសមិទ្ធកម្ម

កន្លងមក ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺផ្អែកតាមសារាចររបស់រាជរដ្ឋាភិបាលលេខ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ និងវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខណៈការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដល់អង្គភាពអនុវត្តត្រូវបានអនុលោមតាមសារាចរលេខ០០៤ សហវ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧, ប្រកាសលេខ៦១៦ សហវប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និងប្រកាសលេខ៣៥១ សហវប្រក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨។ ផ្អែកតាមបទពិសោធន៍នៃការអនុវត្តកន្លងមកនេះ **អ.គ.ហ.** បានពិនិត្យមើលជារួមលើក្របខ័ណ្ឌសមិទ្ធកម្មដោយផ្អែកលើក្របខ័ណ្ឌគតិយុត្តជាធរមាន គម្លាតនៃការអនុវត្តជាក់ស្តែង និងទិសដៅក្នុងការកែលម្អក្របខ័ណ្ឌគ្រប់គ្រងសមិទ្ធកម្មសំដៅពង្រឹងការផ្សារភ្ជាប់គ្នាឱ្យបានរឹងមាំរវាងទិដ្ឋភាពហិរញ្ញវត្ថុ (កញ្ចប់ថវិកា និងប្រាក់ឧបត្ថម្ភដែលផ្តល់ជូនអង្គភាពអនុវត្ត) និងទិដ្ឋភាពសមិទ្ធកម្មដែលត្រូវសម្រេចដោយអង្គភាពអនុវត្ត។

ក្នុងគោលដៅជំរុញប្រសិទ្ធភាព និងលើកកម្ពស់សមិទ្ធកម្ម នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម", ក្របខ័ណ្ឌគ្រប់គ្រងសមិទ្ធកម្មចាំបាច់ត្រូវធ្វើបច្ចុប្បន្នកម្ម ដោយធ្វើសមាហរណកម្ម និងតម្រឹមពេលវេលាជាមួយគ្នា ផ្អែកលើក្របខ័ណ្ឌគតិយុត្តដែលមានស្រាប់ គំនិតផ្តួចផ្តើម

បន្ថែមថ្មី និងបទពិសោធន៍នៃការអនុវត្តជាក់ស្តែង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញសារាចរលេខ១៤ សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំនួសឱ្យសារាចរលេខ០៩ សរ រីឯប្រកាសសម្រាប់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដល់អង្គភាពអនុវត្តត្រូវបានរៀបចំថ្មី ដើម្បីជំនួសនូវសារាចរ និងប្រកាសចាស់។ ឈរលើស្មារតីខាងលើ វដ្តនៃការគ្រប់គ្រងសមិទ្ធកម្មនឹងផ្តោតលើលំដាប់លំដោយនៃការរៀបចំផែនការ ការអនុវត្ត និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ស្របតាមក្របខ័ណ្ឌពេលវេលាដូចក្នុងដ្យាក្រាម ៤ ខាងក្រោម៖

*ដ្យាក្រាម ៤ ៖ វដ្តនៃការគ្រប់គ្រងសមិទ្ធកម្ម*



# ជំពូក ៤. ការរៀបចំផែនការសមិទ្ធកម្ម

ការរៀបចំផែនការសមិទ្ធកម្ម ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលទី៤ នេះត្រូវបានបែងចែក ដូចតទៅ៖ ផែនការសកម្មភាពរួម លទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពលម្អិត ផែនការថវិកា ផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ និងកិច្ចព្រមព្រៀងសមិទ្ធកម្ម។

## ៤.១. ផែនការសកម្មភាពរួម

ផែនការសកម្មភាពរួម គឺជាផែនការកម្រិតយុទ្ធសាស្ត្រដែលរៀបចំឡើងតាមដំណាក់កាលនីមួយៗ ក្នុងគោលដៅសម្រេចឱ្យបាននូវចក្ខុវិស័យ និងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ឯកសារនេះ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ **គ.ហ.ស.** ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ទាំងអស់រៀបចំលទ្ធផលក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិតរបស់ខ្លួន។ ក្នុងនាម **គ.ហ.ស.**, **អ.គ.ហ.** មានតួនាទីភារកិច្ចសម្របសម្រួលរៀបចំផែនការសកម្មភាពរួម ដែលដំណាក់កាលនៃការរៀបចំ គឺត្រូវដាក់ឆ្លងកាត់ការពិនិត្យ និងផ្តល់យោបល់ដោយ **គ.ហ.ស.** និងដៃគូអភិវឌ្ឍ មុននឹងស្នើសុំការពិនិត្យសម្រេចពី **គ.ហ.ស.** បន្ទាប់មកត្រូវដាក់ជូនប្រមុខរដ្ឋាភិបាល អនុម័តនិងដាក់ឱ្យអនុវត្ត។ ជារៀងរាល់ឆ្នាំ **អ.គ.ហ.** ត្រូវពិនិត្យ និងធ្វើបច្ចុប្បន្នកម្មផែនការសកម្មភាពរួម តាមការចាំបាច់ នៅក្នុងអំឡុងពេលអនុវត្ត ហើយដាក់ឆ្លង **គ.ហ.ស.** អនុម័ត និងដាក់ឱ្យអនុវត្ត។ ការធ្វើបច្ចុប្បន្នកម្មនេះ ត្រូវបញ្ចប់យ៉ាងយូរត្រឹមខែសីហា នៃឆ្នាំចរន្ត ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់អនុវត្តឆ្នាំបន្ទាប់។ នៅរៀងរាល់ពាក់កណ្តាលអាណត្តិ និងចុងអាណត្តិ នៃដំណាក់កាលអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **អ.គ.ហ.** ត្រូវវាយតម្លៃការអនុវត្តផែនការសកម្មភាពរួម ដើម្បីពិនិត្យលទ្ធភាពឈានទៅអនុវត្តដំណាក់កាលបន្តទៀត ឬ តាមការសម្រេចរបស់ **គ.ហ.ស.**។

ផែនការសកម្មភាពរួម រៀបចំឡើងដោយផ្អែកលើឯកសារជាមូលដ្ឋានសំខាន់ៗរួមមាន៖ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, យុទ្ធសាស្ត្រកែទម្រង់នានាក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, សេចក្តីសម្រេចប្រតិបត្តិរបស់ **គ.ហ.ស.**, ក្របខ័ណ្ឌលទ្ធផលរបស់ដៃគូអភិវឌ្ឍ និងលទ្ធផលនៃការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈផ្សេងៗ។ ផែនការសកម្មភាពរួម បង្ហាញពីគោលបំណង និងចង្កោមសកម្មភាពការងារកែទម្រង់កម្រិតយុទ្ធសាស្ត្រ។ ឯកសារនេះចែកចេញជា ៥ ផ្នែក, ក្នុងនោះ, ផ្នែកទី១ ផ្នែកទី២ និងផ្នែកទី៣ បង្ហាញពីការងារកែទម្រង់ដែលមានទិសដៅពង្រឹងសមិទ្ធផលនានាដែលសម្រេចបាននៅក្នុងដំណាក់កាលមុនៗ។ ដោយឡែក, ផ្នែកទី៤ បង្ហាញពីការងារកែទម្រង់ដែលមានទិសដៅ "**កសាងគណនេយ្យភាពសមិទ្ធកម្ម**" ដែលជាស្នូលរបស់កម្មវិធីកែទម្រង់ដំណាក់កាលទី៤ និង ផ្នែកទី៥ បង្ហាញពីការងារកែទម្រង់ដែលមានទិសដៅគាំទ្រ និងជានាចលនការនៃការអនុវត្តកម្មវិធីកែទម្រង់។ ផ្នែកទាំង ៥ នៃផែនការសកម្មភាពរួម រួមមាន៖

- ផ្នែកទី១. ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា
- ផ្នែកទី២. ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ
- ផ្នែកទី៣. ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
- ផ្នែកទី៤. ការកសាងគណនេយ្យភាពសមិទ្ធកម្ម
- ផ្នែកទី៥. ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត។

ដ្យាក្រាមខាងក្រោម បរិយាយលម្អិតអំពីទំនាក់ទំនងក្របខ័ណ្ឌលទ្ធផលក្នុងផែនការសកម្មភាពរួម

## *ដ្យាក្រាម ៥ ៖ រចនាសម្ព័ន្ធក្របខ័ណ្ឌផែនការសកម្មភាពរួម*




ជារួម រចនាសម្ព័ននៃផែនការសកម្មភាពរួម ត្រូវបានកំណត់ដោយបែងចែកជាកម្រិត ផ្នែក គោលបំណង ចង្កោមសកម្មភាព ខណៈអង្គភាពអនុវត្តត្រូវរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិតសម្រាប់អនុវត្ត។ ដូចនេះ ការរៀបចំផែនការសកម្មភាពរួម គឺត្រូវគិតគូរអំពីការកំណត់គោលបំណង និងសូចនាករសមិទ្ធកម្មកម្រិតគោលបំណង, ចង្កោមសកម្មភាព និងសូចនាករសមិទ្ធកម្មកម្រិតចង្កោមសកម្មភាព ដើម្បីសម្រេចនូវគោលដៅសមិទ្ធកម្មប្រចាំឆ្នាំនីមួយៗ។ បន្ថែមលើនេះ ដើម្បីផ្តល់នូវទិដ្ឋភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ, ផែនការសកម្មភាពរួម ត្រូវកំណត់ឱ្យមានលទ្ធផលគោល ដែលបង្ហាញអំពីលទ្ធផលដែលបានសម្រេចចុងក្រោយ, វិធីសាស្រ្តវាស់វែងដែលកំណត់អំពីការវាស់វែងសមិទ្ធកម្មធៀបនឹងសូចនាករ, និងភស្តុតាងសមិទ្ធកម្ម។ ក្នុងក្របខ័ណ្ឌស្តីពីការគ្រប់គ្រងសមិទ្ធកម្មបច្ចុប្បន្នកម្ម លក្ខខណ្ឌវាយតម្លៃត្រូវកំណត់ដោយការប្រើប្រាស់ពណ៌ ជំនួសឱ្យការបូកពិន្ទុភាគរយ។ ការកំណត់លក្ខខណ្ឌវាយតម្លៃ ត្រូវធ្វើឡើងប្រចាំឆ្នាំ ស្របតាមគោលដៅសមិទ្ធកម្មប្រចាំឆ្នាំនីមួយៗ។ ពណ៌ត្រូវបានកំណត់ចំនួន ៤ ដែលពណ៌នីមួយៗមានអត្ថន័យ ដូចតទៅ៖

- ■ : សម្រេចពេញលេញ និងបានបិទបញ្ចប់
- ◆ : មានវឌ្ឍនភាពច្រើន ឬ ស្ទើនឹងបិទបញ្ចប់
- ▲ : មានវឌ្ឍនភាពយឺតយ៉ាវ និងទាបជាងគោលដៅ
- ● : មានវឌ្ឍនភាពយឺតយ៉ាវខ្លាំង ឬ គ្មានវឌ្ឍនភាព

## តារាងទី ១ ៖ ទម្រង់ផែនការសកម្មភាពរួម ដំណាក់កាលទី៤

| គោលបំណង/<br>ចង្កោមសកម្មភាព | អង្គភាព<br>អនុវត្ត | សូចនាករ<br>សមិទ្ធកម្មគន្លឹះ | លទ្ធផលគោល<br>(Baseline) | លក្ខខណ្ឌវាយតម្លៃ<br>ប្រចាំឆ្នាំ២០២៤ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ: ឆ្នាំ២០២៣-២០២៧ | | | | | ឯកសារភស្តុតាង |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | ឆ្នាំ ២០២៣ | ឆ្នាំ ២០២៤ | ឆ្នាំ ២០២៥ | ឆ្នាំ ២០២៦ | ឆ្នាំ ២០២៧ | |
| ផ្នែកទី ១ ៖ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា<br>ការអនុវត្តថវិកា (ចំណូល-ចំណាយ) មានភាពធន់មាំ ហើយលទ្ធផលនៃការអនុវត្តថវិកាប្រចាំត្រីមាសនិងប្រចាំឆ្នាំមានភាពរលូននិងអាចប៉ាន់ប្រមាណបានស្ថិតនៅក្នុងរង្វង់ +/-៥% នៃច្បាប់ថវិកា ។ | | | | | | | | | | |
| ១១. បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល | កសហវ. ក្រសួង ស្ថាប័ន | សគ[1] ១.<br>ភាគរយនៃការអនុវត្តចំណូលថវិកាធៀបនឹងច្បាប់ថវិកា | ឆ្នាំ២០២១៖<br>ចំណូលចរន្តសម្រេចបាន ១០៤,៤៩% ធៀបនឹងច្បាប់ថវិកា | ការអនុវត្តចំណូលចរន្តធៀបនឹងច្បាប់ថវិកា<br>■ : +/-៥%<br>◆ : +/-១០%<br>▲ : +/-១៥%<br>● : +/-២០% | ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកាជារៀងរាល់ឆ្នាំ | ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកាជារៀងរាល់ឆ្នាំ | ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកាជារៀងរាល់ឆ្នាំ | ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកាជារៀងរាល់ឆ្នាំ | ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកាជារៀងរាល់ឆ្នាំ | របាយការណ៍ចំណូល |
| | | សគ ២.<br>កំណើនចំណូលចរន្តធៀបនឹងផ.ស.ស. | ឆ្នាំ២០២១៖<br>ចំណូលចរន្តកើន -២,៦៨ ពិន្ទុភាគរយ នៃ ផ.ស.ស. | (ចំណូលចរន្តឆ្នាំ N/ផ.ស.ស. ឆ្នាំ N) - (ចំណូល ចរន្តឆ្នាំ N-1/ ផ.ស.ស ឆ្នាំ N-1)<br>■ : >= ០,៣<br>◆ : >= 0.២ , < 0.៣<br>▲ : >= 0.១ , < 0.២<br>● : <= 0 , < 0.១ | យ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស[2] | យ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស. | យ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស. | យ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស. | យ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស<br>. | របាយការណ៍ចំណូល |
| ១១.១. អនុវត្តគោល-នយោបាយ និងកែទម្រង់រដ្ឋបាលគយ និងពន្ធដារ | អ.ព.ដ. | សច[3] ១.<br>ពន្ធលើប្រាក់ចំណេញមូលធន (Capital Gain Tax) ត្រូវបានអនុវត្ត | ឆ្នាំ២០២១៖<br>បទប្បញ្ញត្តិ រំហូរការងារ និងរចនាសម្ព័ន្ធអង្គភាពពាក់ព័ន្ធនឹងការប្រមូលពន្ធលើចំណេញមូលធន (Capital | របាយការណ៍លទ្ធផលនៃការអនុវត្តពន្ធលើចំណេញមូលធន (Capital Gain Tax)<br>■ : មានរបាយការណ៍<br>◆ : | ការអនុវត្តការប្រមូលពន្ធលើចំណេញមូលធន (Capital Gain Tax) ត្រូវបានផ្សព្វផ្សាយ | ការប្រមូលពន្ធលើចំណេញមូលធន (Capital Gain Tax) ត្រូវបានអនុវត្ត | ការផ្សព្វផ្សាយ និងការបន្តពង្រឹងការប្រមូលពន្ធលើចំណេញមូលធន (Capital Gain Tax) | ការផ្សព្វផ្សាយ និងការបន្តពង្រឹងការប្រមូលពន្ធលើចំណេញមូលធន (Capital Gain Tax) | ការផ្សព្វផ្សាយ និងការបន្តពង្រឹងការប្រមូលពន្ធលើចំណេញមូលធន (Capital Gain Tax) | របាយការណ៍លទ្ធផល |

[1] សគ៖ សូចនាករគោលបំណង

[2] គោលដៅកំណត់ក្នុងយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ។ គោលដៅសូចនាករនេះអាចនឹងប្រែប្រួលដោយផលប៉ះពាល់បណ្តាមកពីការរីករាលដាលនៃជំងឺកូវីដ-១៩ ។

[3] សច៖ សូចនាករចង្កោមសកម្មភាព

| គោលបំណង/ចង្កោមសកម្មភាព | អង្គភាពអនុវត្ត | សូចនាករសមិទ្ធកម្មគន្លឹះ | លទ្ធផលគោល (Baseline) | លក្ខខណ្ឌវាយតម្លៃប្រចាំឆ្នាំ២០២៤ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ ឆ្នាំ២០២៣-២០២៧ | | | | | ឯកសារភស្តុតាង |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | ឆ្នាំ ២០២៣ | ឆ្នាំ ២០២៤ | ឆ្នាំ ២០២៥ | ឆ្នាំ ២០២៦ | ឆ្នាំ ២០២៧ | |
| | | | Gain Tax) ត្រូវបានរៀបចំ | ▲: <br>● : ពុំមានរបាយការណ៍ | | | | | | |
| | អ.ព.ដ.<br>អ.គ.ប. | សច ២.<br>ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល (Personal Income Tax - PIT) ត្រូវបានអនុវត្ត | ឆ្នាំ២០២២៖ អ.គ.ប. កំពុងរៀបចំក្របខណ្ឌគោលនយោបាយអនុវត្តពន្ធ PIT ហើយគ្រោងនឹងបញ្ចប់ក្នុងត្រីមាសទី ១ ឆ្នាំ២០២៣ | របាយការណ៍លទ្ធផលនៃការអនុវត្តពន្ធ PIT<br>■ : មានរបាយការណ៍<br>◆ :<br>▲:<br>● : ពុំមានរបាយការណ៍ | ក្របខណ្ឌប្រតិបត្តិ (Operational Framework) សម្រាប់អនុវត្តពន្ធ PIT ត្រូវបានរៀបចំ និងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច | • សេចក្តីព្រាងអនុក្រឹត្យ ប្រកាស និងសេចក្តីណែនាំស្តីពីនីតិវិធីនៃការប្រមូលពន្ធ PIT និងប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានរៀបចំ<br>• ការអនុវត្តការប្រមូលពន្ធ PIT ត្រូវបានផ្សព្វផ្សាយ | ការប្រមូលពន្ធ PIT ត្រូវបានអនុវត្ត | ការផ្សព្វផ្សាយ និងការបន្តពង្រឹងការប្រមូលពន្ធ PIT | ការផ្សព្វផ្សាយ និងការបន្តពង្រឹងការប្រមូលពន្ធ PIT | របាយការណ៍លទ្ធផល |
| ១១.១.១ (លទ្ធផលក្នុងឆ្នាំ) | អង្គភាពអនុវត្ត | (សូចនាករសមិទ្ធ-កម្ម) | (លទ្ធផលគោល) | (លក្ខខណ្ឌវាយតម្លៃ) | | | | | | |
| ១១.១.១-១ (សកម្មភាពលម្អិត) | អង្គភាពអនុវត្ត | (សូចនាករសមិទ្ធ-កម្ម) | (លទ្ធផលគោល) | (លក្ខខណ្ឌវាយតម្លៃ) | | | | | | |

## ៤.២. លទ្ធផលគន្លឹះក្នុងឆ្នាំ

លទ្ធផលគន្លឹះក្នុងឆ្នាំ គឺជាសមិទ្ធកម្មរយៈពេលខ្លី (មួយឆ្នាំ ឬ តិចជាង) ដែលត្រូវរៀបចំ និងអនុវត្តដោយ **គ.ហ.ស.**។ ការរៀបចំលទ្ធផលក្នុងឆ្នាំ ត្រូវកំណត់ដោយការសម្រួចទិសដៅឆ្ពោះទៅសម្រេចចង្កោមសកម្មភាព និងគោលបំណងដែលបានកំណត់ក្នុងផែនការសកម្មភាពរួម។ ក្នុងន័យនេះ សមិទ្ធកម្មដែលទទួលបានតាមរយៈការអនុវត្តសកម្មភាពលម្អិតនឹងរួមចំណែកសម្រេចបានលទ្ធផលគន្លឹះក្នុងឆ្នាំ ហើយជាបច្ច័យឆ្ពោះទៅសម្រេចបានចង្កោមសកម្មភាព និងគោលបំណងនៃផែនការសកម្មភាពរួម។ ជារៀងរាល់ឆ្នាំ ដោយផ្អែកលើគោលដៅសមិទ្ធកម្មប្រចាំឆ្នាំ ដូចមានចែងក្នុងផែនការសកម្មភាពរួមខាងលើ, **អ.គ.ហ.** ត្រូវរៀបចំក្របខ័ណ្ឌលទ្ធផលគន្លឹះរួម សម្រាប់ជាមូលដ្ឋានជូន **គ.ហ.ស.** ក្នុងការរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ក្របខ័ណ្ឌលទ្ធផលគន្លឹះរួមនេះត្រូវដាក់ជូនប្រធាន **គ.ហ.ស.** ពិនិត្យនិងអនុម័ត ស្របជាមួយនឹងការស្នើសុំកំណត់ពិតានថវិកាប្រចាំឆ្នាំ។ បន្ទាប់ឯកសារនេះ ទទួលបានការអនុម័ត, **គ.ហ.ស.** ត្រូវរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំរបស់ខ្លួន ដោយពិគ្រោះយោបល់ជាមួយ **អ.គ.ហ.** ក្នុងការសម្រួចគោលដៅប្រចាំឆ្នាំ សូចនាករសមិទ្ធកម្ម និងវិធីសាស្ត្រវាស់វែងឱ្យបានច្បាស់លាស់ដោយធានាសង្គតិភាពជាមួយនឹងផែនការសកម្មភាពរួមរបស់កម្មវិធីកែទម្រង់។ លទ្ធផលគន្លឹះក្នុងឆ្នាំត្រូវចុះហត្ថលេខាដោយប្រធាន **គ.ហ.ស.** ប្រចាំអង្គភាព ឬ ស្ថាប័នសាមី និងត្រូវអនុម័តនិងដាក់ឱ្យអនុវត្តដោយប្រធាន **គ.ហ.ស.** ដែលកិច្ចការនេះត្រូវរៀបចំឱ្យចប់រួចរាល់សម្រាប់អនុវត្តនាដើមឆ្នាំបន្ទាប់។ ដើម្បីផ្តល់ទិដ្ឋភាពកាន់តែច្បាស់លាស់លទ្ធផលគន្លឹះក្នុងឆ្នាំ ត្រូវមានសូចនាករសមិទ្ធកម្មប្រចាំត្រីមាស, ភស្តុតាងសមិទ្ធកម្ម និងការកំណត់លក្ខខណ្ឌវាយតម្លៃដោយប្រើប្រាស់ពណ៌ចំនួន ៤ ដូចនឹងផែនការសកម្មភាពរួមដែរ។ សមិទ្ធកម្មនៃការសម្រេចបានលទ្ធផលក្នុងឆ្នាំនេះ គឺជាមូលដ្ឋានសម្រាប់ការវាយតម្លៃការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ជាទូទៅ លទ្ធផលគន្លឹះក្នុងឆ្នាំ គឺជាផលិតផល, ទំនិញ ឬ សេវា ដែលត្រូវបានបង្កើត និងសម្រេចបានដោយ **គ.ហ.ស.**។ ក្នុងន័យនេះ សូចនាករកម្រិតលទ្ធផលក្នុងឆ្នាំនេះត្រូវបង្ហាញអំពីរង្វាស់សមិទ្ធកម្មសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីវាយតម្លៃអំពីការសម្រេចបាននូវគោលដៅសមិទ្ធកម្មនៃលទ្ធផលនោះ។ សូចនាករលទ្ធផលក្នុងឆ្នាំ អាចជារង្វាស់បរិមាណ (លេខ ចំនួន អត្រា អនុបាត មធ្យម ...) ឬ អាចជាគុណភាព ដែលប្រើប្រាស់សម្រាប់វាស់វែងសមិទ្ធកម្មដែលមិនមែនជាលេខ ឬ ចំនួន តែអាចជារង្វាស់កម្រិតនៃការយល់ដឹង គុណភាពនៃការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនានា ឬ កិច្ចការពាក់ព័ន្ធនឹងការរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។ ជាគោលការណ៍នៃសូចនាករលទ្ធផលគន្លឹះក្នុងឆ្នាំនេះ ត្រូវកំណត់ដូចខាងក្រោម៖

- ត្រូវមានលក្ខណៈជាបរិមាណ, គុណភាព ឬ ពេលវេលានៃការបញ្ចប់លទ្ធផលក្នុងឆ្នាំនោះ ហើយសូចនាករនោះគឺអាចវាស់វែងបានតាមពេលវេលាជាក់លាក់ណាមួយ
- ត្រូវផ្តោតលើលទ្ធផលដោយផ្សារភ្ជាប់ និងមានសង្គតិភាពជាមួយចង្កោមសកម្មភាព គោលបំណងនៃផែនការសកម្មភាពរួម ឬ សេចក្តីសម្រេចប្រតិបត្តិរបស់ **គ.ហ.ស.**
- ការកំណត់លទ្ធផលក្នុងឆ្នាំ និងសូចនាករត្រូវឆ្លុះបញ្ចាំងអំពីឆន្ទៈ និងទិសដៅនៃការងារកែទម្រង់ ពោលគឺមិនមែនជាការងារប្រចាំថ្ងៃ ឬការងាររដ្ឋបាលឡើយ។

ឧទាហរណ៍៖

- **ភាគរយ** នៃអ្នកជាប់ពន្ធបង់ VAT ទាន់ពេលវេលា
- **ចំនួន** ក្រសួង-ស្ថាប័ន ចូលរួមអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ
- **ចំនួន** ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់ប្រព័ន្ធ NRMIS និង E-payment
- យុទ្ធសាស្ត្រគៀរគរចំណូល ២០២៤-២០២៨ **ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត**
- គោលការណ៍ណែនាំហិរញ្ញវត្ថុសាធារណៈ **ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត**
- ផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ **ត្រូវបានរៀបចំ**
- ការទូទាត់បុរេប្រទានត្រូវបានធ្វើឡើងតាម **ពេលវេលាដែលបានកំណត់**។

*តារាងទី ២ ៖ ទម្រង់លទ្ធផលគន្លឹះក្នុងឆ្នាំ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| ចង្កោមសកម្មភាព របស់ CAP4 | លទ្ធផលគន្លឹះ | សូចនាករ សមិទ្ធកម្មគន្លឹះ | លទ្ធផលគោល | លក្ខខណ្ឌវាយតម្លៃ | គោលដៅប្រចាំឆមាស | គោលដៅប្រចាំឆ្នាំ | ឯកសារភស្តុតាង |
|---|---|---|---|---|---|---|---|
| ១១.២. អនុវត្តគោលនយោបាយ និងកែទម្រង់រដ្ឋបាលចំណូលមិនមែនពន្ធ | ១១.១.១: ឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | Blueprint និងផែនការសកម្មភាពលម្អិតត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | ឆ្នាំ២០២៤៖ មានសេចក្តីព្រាង | ■ : អនុម័ត និងដាក់ឱ្យអនុវត្ត<br>◆ : បានប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ<br>▲: បានប្រជុំពិភាក្សាកម្រិតបច្ចេកទេស<br>● : មានសេចក្តីព្រាងបឋម ឬគ្មានវឌ្ឍនភាព | **តម ១:** សេចក្តីព្រាងត្រូវបានប្រជុំពិភាក្សាកម្រិតបច្ចេកទេស<br>**តម ២:** សេចក្តីព្រាងត្រូវបានប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ<br>**តម ៣:** អនុម័ត និងដាក់ឱ្យអនុវត្ត<br>**តម ៤:** | ឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | ឯកសារគោល និងផែនការសកម្មភាព |
| ១១.២<br>.......... | ១១.១.២:<br>.......... | ឆ្នាំ២០២៤៖<br>......... | ឆ្នាំ២០២៤៖<br>......... | ■ : (សម្រេចពេញលេញ)<br>◆ : (មានវឌ្ឍនភាពច្រើន)<br>▲: (មានវឌ្ឍនភាពទាប)<br>● : (គ្មានវឌ្ឍនភាព) | **តម ១:**<br>**តម ២:**<br>**តម ៣:**<br>**តម ៤:** | ......... | ......... |
| | | | | | | | |
| | | | | | | | |

## ៤.៣. ផែនការសកម្មភាពលម្អិត

ផែនការសកម្មភាពលម្អិត គឺជាផែនការដែលត្រូវបានបំបែកគោលដៅសមិទ្ធកម្មតាមត្រីមាសនីមួយៗ សម្រាប់គាំទ្រការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំខាងលើ។ ដូចទៅនឹងលទ្ធផលគន្លឹះក្នុងឆ្នាំផងដែរ ផែនការសកម្មភាពលម្អិត ត្រូវរៀបចំដោយ **ក.ហ.ស.** និងឆ្លងកាត់ការជជែកពិភាក្សា ពិគ្រោះយោបល់ជាមួយ **អ.គ.ហ.** ដើម្បីធានាបាននូវសង្គតិភាព និងភាពគ្រប់ជ្រុងជ្រោយ។ ផ្អែកតាមលទ្ធផលក្នុងឆ្នាំ **ក.ហ.ស.** ត្រូវរៀបចំផែនការសកម្មភាពលម្អិតរបស់ខ្លួនដោយកំណត់គោលដៅសមិទ្ធកម្មប្រចាំត្រីមាសនីមួយៗ និងកំណត់សូចនាករឱ្យបានច្បាស់លាស់ ប៉ុន្តែការវាយតម្លៃផែនការសកម្មភាពលម្អិតនេះ មិនត្រូវបានកំណត់ដោយពណ៌ ឬ ពិន្ទុជាភាគរយឡើយ ពោលគឺវឌ្ឍនភាពនៃការអនុវត្តផែនការនេះត្រូវបង្ហាញបែបបរិយាយនូវសមិទ្ធកម្មដែលសម្រេចបានជាក់ស្តែង។ ក្នុងន័យនេះ វឌ្ឍនភាពនៃការអនុវត្តផែនការនេះមិនត្រូវបានប្រើប្រាស់ជាមូលដ្ឋាននៃការផ្សារភ្ជាប់ទៅនឹងការលើកទឹកចិត្តឡើយ គឺប្រើប្រាស់សម្រាប់តែជាព័ត៌មានក្នុងការរៀបចំរបាយការណ៍តាមដានការអនុវត្តប្រចាំ **ក.ហ.ស.** នៅតាមអង្គភាព ឬ ស្ថាប័នសាមី និងសម្រាប់ជាឧបករណ៍ផ្តល់នូវព័ត៌មានបន្ថែមដល់ **អ.គ.ហ.** ក្នុងបូកសរុបរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ឆមាស និងឆ្នាំជូន **គ.ហ.ស.** ប៉ុណ្ណោះ។

ផែនការសកម្មភាពលម្អិត គឺជាបណ្តុំការងារដែលត្រូវអនុវត្តតាមរយៈការប្រើប្រាស់ធាតុចូលដូចជា ថវិកា, ជំនួយបច្ចេកទេស និងធនធានផ្សេងៗទៀត ដើម្បីសម្រេចបានលទ្ធផលក្នុងឆ្នាំ។ ការអនុវត្តសកម្មភាព គឺជាដំណើរការក្នុងការបំប្លែងធាតុចូលសំដៅសម្រេចបាននូវលទ្ធផលគន្លឹះក្នុងឆ្នាំ ដូចនេះការសម្រេចបានសកម្មភាព គឺជាបច្ច័យរុញច្រានដល់ការសម្រេចបាននូវលទ្ធផលក្នុងឆ្នាំ ចង្កោមសកម្មភាព និងគោលបំណងនៃផែនការសកម្មភាពរួមផងដែរ។ ជាទូទៅ សកម្មភាពដែលគ្រោងនៅក្នុងផែនការសកម្មភាពលម្អិត មានលក្ខណៈជាការងារ រួមមាន៖ ការដំណើរការរៀបចំលិខិតបទដ្ឋានគតិយុត្ត, ការរៀបចំរបាយការណ៍, ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្សេងៗ និងការផលិតរបាយការណ៍, ការរៀបចំកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ការផ្សព្វផ្សាយ ឬ ការចងក្រងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ។ល។ ផែនការសកម្មភាពលម្អិត ត្រូវអនុម័តនិងដាក់ឱ្យអនុវត្តដោយប្រធាន **គ.ហ.ស.** រួមគ្នាជាមួយនឹងលទ្ធផលគន្លឹះក្នុងឆ្នាំ ដែលកិច្ចការនេះត្រូវរៀបចំឱ្យចប់រួចរាល់សម្រាប់អនុវត្តនាដើមឆ្នាំបន្ទាប់។ ជាគោលការណ៍នៃកំណត់សកម្មភាព ត្រូវផ្តោតលើចំណុចដូចខាងក្រោម៖

- សកម្មភាពនីមួយៗ ត្រូវមានភាពច្បាស់លាស់ និងផ្សារភ្ជាប់ជាមួយលទ្ធផលគន្លឹះក្នុងឆ្នាំ
- ការកំណត់ទំហំសកម្មភាព ត្រូវផ្អែកលើលទ្ធភាពនៃធាតុចូលដែលទទួលបាន (ថវិកា, ជំនួយបច្ចេកទេស និងធនធានផ្សេងទៀត)
- សកម្មភាពនីមួយៗ ត្រូវមានសូចនាករសមិទ្ធកម្មគន្លឹះ លទ្ធផលគោល វិធីសាស្ត្រវាស់វែង គោលដៅសមិទ្ធកម្មប្រចាំត្រីមាស និងភស្តុតាងសមិទ្ធកម្ម។
- ការកំណត់សកម្មភាព និងសូចនាករត្រូវឆ្លុះបញ្ចាំងអំពីធន្ទះ និងទិសដៅនៃការងារកែទម្រង់ ពោលគឺមិនមែនជាការងារប្រចាំថ្ងៃ ឬ ការងាររដ្ឋបាលឡើយ។

*តារាងទី ៣ ៖ ទម្រង់ផែនការសកម្មភាពលម្អិត នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| គោលបំណង/ចង្កោមសកម្មភាព | អង្គភាពអនុវត្ត | សូចនាករសមិទ្ធកម្មគន្លឹះ | លទ្ធផលគោល | វិធីសាស្ត្រវាស់វែង | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះប្រចាំ ឆ្នាំ២០២៥ | | | | ឯកសារភស្តុតាង |
|---|---|---|---|---|---|---|---|---|---|
| | | | | | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ | |
| ១១. បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល | កសហវ. ក្រសួង ស្ថាប័ន | សគ ១. ភាគរយនៃការអនុវត្តចំណូលថវិកាធៀបនឹងច្បាប់ថវិកា | ឆ្នាំ២០២១៖ ចំណូលចរន្តសម្រេចបាន ១០៤,៥៩% ធៀបនឹងច្បាប់ថវិកា | ចំណូលសរុបធៀបនឹងច្បាប់ថវិកា | ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកាជារៀងរាល់ឆ្នាំ | | | | របាយការណ៍ចំណូល |
| ១១.១. អនុវត្តគោលនយោបាយ និងកែទម្រង់រដ្ឋបាលគយ និងពន្ធដារ | អ.ព.ដ | សច.២ ពន្ធលើចំណូលរូបវន្តបុគ្គល (Personal Income Tax) ត្រូវបានត្រៀមអនុវត្ត | ឆ្នាំ២០២២៖ ក្របខណ្ឌគោលនយោបាយ PIT | របាយការណ៍លទ្ធផលនៃការអនុវត្តពន្ធលើចំណូលរូបវន្តបុគ្គល (PIT) | - សេចក្តីព្រាងអនុក្រឹត្យ ប្រកាស និងសេចក្តីណែនាំស្តីពីនីតិវិធីនៃការប្រមូលពន្ធ PIT និងប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានរៀបចំ<br>- ការអនុវត្តការប្រមូលពន្ធ PIT ត្រូវបានផ្សព្វផ្សាយ | | | | របាយការណ៍លទ្ធផល |
| ១១.១.១-១ ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល (Personal Income Tax) ត្រូវបានត្រៀមអនុវត្ត | អ.ព.ដ | សស.១ ការកំណត់ប្រភេទចំណូលជាប់ពន្ធរបស់រូបវន្តបុគ្គលរួមទាំងចំណូលពីកម្លាំងពលកម្ម ចំណូលអាជីវកម្មផ្ទាល់ខ្លួន និងចំណូលមូលធនពីប្រភពក្រៅប្រទេស និងពីប្រភពក្នុងប្រទេស | ក្របខណ្ឌគោលនយោបាយ PIT ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | របាយការណ៍លទ្ធផលនៃការសិក្សាអំពីការកំណត់ប្រភេទចំណូលជាប់ពន្ធរបស់រូបវន្តបុគ្គល | សិក្សា និងកំណត់ប្រភេទចណូលជាប់ពន្ធរបស់រូបវន្តបុគ្គល | បន្តសិក្សា និងកំណត់ប្រភេទចំណូលជាប់ពន្ធរបស់ រូបវន្តបុគ្គល | រៀបចំកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសជាមួយនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូលបន្ថែម | រៀបចំរបាយការណ៍លទ្ធផលនៃការសិក្សាអំពីការកំណត់ប្រភេទចំណូលជាប់ពន្ធរបស់រូបវន្តបុគ្គល | របាយការណ៍លទ្ធផល |
| | | | | | | | | | |
| | | | | | | | | | |

## ៤.៤. ផែនការថវិកា

ផែនការថវិកា គឺជាកញ្ចប់ថវិកាប្រចាំឆ្នាំដែលត្រូវបានផ្តល់ជូន **ក.ហ.ស.** នៅតាមអង្គភាព និងស្ថាប័ន ដើម្បីគាំទ្រការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិតរបស់ **ក.ហ.ស.** សាមីផ្ទាល់។ ជារៀងរាល់ឆ្នាំ **គ.ហ.ស.** ត្រូវចេញលិខិតជូនដំណឹងដល់គ្រប់ **ក.ហ.ស.** ដើម្បីរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពលម្អិត និងផែនការថវិកាប្រចាំឆ្នាំ ដោយកំណត់ក្របខ័ណ្ឌសមិទ្ធកម្ម និងក្របខ័ណ្ឌពិតានថវិកាប្រចាំឆ្នាំ ដោយផ្តល់នូវទស្សនទានសម្រាប់ការរៀបចំផែនការថវិកាប្រចាំឆ្នាំដោយផ្សារភ្ជាប់ជាមួយនឹងក្របខ័ណ្ឌសមិទ្ធកម្ម ឬ លទ្ធផល ក្នុងគោលដៅឆ្ពោះទៅសម្រេចបានអាទិភាពការងារដូចមានចែងក្នុងក្របខ័ណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៤។ ការរៀបចំក្របខ័ណ្ឌពិតានថវិកានេះ នឹងកំណត់ពិតានថវិកាតាមអង្គភាពអនុវត្តនីមួយៗ ដែលឆ្លើយតបនឹងតម្រូវការចំណាយជាក់ស្តែង ផ្អែកតាមលទ្ធភាពថវិការបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួនដែលទទួលបានពី ៣ ប្រភព រួមមាន៖ មូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ថវិកាទ្រទ្រង់ពីហិរញ្ញប្បទានដោយសហភាពអឺរ៉ុប និងថវិកាបដិភាគរាជរដ្ឋាភិបាល។

ផ្អែកតាមអាទិភាពការងារ និងពិតានថវិកាដែលបានកំណត់ដោយ **គ.ហ.ស.**, **ក.ហ.ស.** ត្រូវចាប់ផ្តើមរៀបចំផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួន និងផ្ញើមក **អ.គ.ហ.** ដែលជាសេនាធិការឱ្យ **គ.ហ.ស.** យ៉ាងយូរសប្តាហ៍ទី១ ខែតុលា។ បន្ទាប់ពីទទួលបានផែនការថវិកាពីគ្រប់ **ក.ហ.ស.**, **អ.គ.ហ.** ត្រូវរៀបចំកិច្ចប្រជុំពិភាក្សា និងចរចាថវិកាជា ២ កម្រិត គឺកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំ។ កិច្ចប្រជុំចរចាថវិកាកម្រិតបច្ចេកទេសរវាង **អ.គ.ហ.** និង **ក.ហ.ស.** ត្រូវធ្វើឡើងនៅសប្តាហ៍ទី៤ ខែតុលា និងសប្តាហ៍ទី១ ខែវិច្ឆិកា រីឯកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ ត្រូវធ្វើឡើងនៅក្នុងសប្តាហ៍ទី៤ ខែវិច្ឆិកា។ កិច្ចប្រជុំចរចាថវិកាទាំង ២ កម្រិតនេះត្រូវធ្វើឡើងក្នុងគោលដៅធានាបាននូវសង្គតិភាព និងភាពគ្រប់ជ្រុងជ្រោយទាំងក្របខ័ណ្ឌសមិទ្ធកម្ម និងក្របខ័ណ្ឌថវិកា ដោយសម្រួចនិងតម្រឹមលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពលម្អិត និងផែនការថវិកាឱ្យផ្សារភ្ជាប់ជាអតិបរមាទៅនឹងក្របខ័ណ្ឌផែនការសកម្មភាពរួម របស់កម្មវិធីកែទម្រង់។ ផ្អែកតាមលទ្ធផលនៃកិច្ចប្រជុំទាំង ២ កម្រិតខាងលើ, **អ.គ.ហ.** ត្រូវបូកសរុប ដើម្បីដាក់ជូនប្រធាន **គ.ហ.ស.** ពិនិត្យ អនុម័ត និងដាក់ឱ្យអនុវត្តនៅដំណាច់ឆ្នាំមុនឆ្នាំអនុវត្ត។

ការរៀបចំផែនការថវិកាត្រូវរៀបចំឡើងប្រកបដោយភាពសន្សំសំចៃខ្ពស់តាមរយៈ (១) បរិវត្តកម្មឌីជីថល, (២) ការបង្កើនភាពជាម្ចាស់ការដោយប្រើប្រាស់ធនធានខាងក្នុងអង្គភាព, (៣) ការបង្កើនតម្លៃនៃលុយ (Value for Money) និង (៤) ស្របតាមតាមគោលការណ៍ណែនាំនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ ដោយប្រកាន់ខ្ជាប់នូវ៖ វិន័យថវិកា, ប្រសិទ្ធភាពវិភាជន៍, និងប្រតិបត្តិការ ពោលគឺចំណាយចំគោលដៅ និងផ្តោតលើអាទិភាពចំពោះមុខសម្រាប់ការដ្ឋានកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ផែនការថវិកាត្រូវរៀបចំឡើងដោយផ្តោតលើមុខសញ្ញាចំណាយចំនួន ៤ សំខាន់៖ (១) ការរៀបចំសិក្ខាសាលា/វគ្គបណ្តុះបណ្តាល, (២) ទីប្រឹក្សា, (៣) ទំនិញ និង (៤) ប្រតិបត្តិការប្រចាំថ្ងៃ។

- **ការរៀបចំសិក្ខាសាលា/វគ្គបណ្តុះបណ្តាល៖** ត្រូវគ្រោងកញ្ចប់ថវិកាផ្តោតសំខាន់លើការងារអាទិភាព និងសកម្មភាពគាំទ្រលទ្ធផលគន្លឹះក្នុងឆ្នាំ ស្របតាមផែនការសកម្មភាពរួមរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬ ក្របខ័ណ្ឌលទ្ធផលរបស់ដៃគូអភិវឌ្ឍ។ សិក្ខាសាលា/វគ្គបណ្តុះបណ្តាល សំដៅដល់ទស្សនកិច្ចសិក្សា សិក្ខាសាលាពិគ្រោះយោបល់, សិក្ខាសាលាផ្សព្វផ្សាយ, វគ្គបណ្តុះបណ្តាល, ការកសាងនិងអភិវឌ្ឍសមត្ថភាពផ្សេងៗក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ ទាំងក្នុងនិងក្រៅស្រុក។ មុខសញ្ញាចំណាយសម្រាប់ការរៀបចំសិក្ខាសាលា/វគ្គបណ្តុះបណ្តាលរួមមាន៖

- **សិក្ខាសាលា/វគ្គបណ្តុះបណ្តាលក្នុងស្រុក៖** ថ្លៃបន្ទប់ប្រជុំ (សម្រាប់ការរៀបចំនៅសណ្ឋាគារ), អាហារសម្រន់ (សម្រាប់រៀបចំនៅអង្គភាព ឬ ស្ថាប័នសាមី ប៉ុន្តែថ្លៃបន្ទប់ប្រជុំមិនផ្តល់ជូនទេ), ថតចម្លងឯកសារ, សេវាបកប្រែ (ករណីចាំបាច់), បដា និងប្រាក់បេសកកម្មក្នុងស្រុកសម្រាប់សិក្ខាកាមធ្វើដំណើរឆ្លងខេត្ត (ប្រាក់ស្នាក់នៅ, ប្រាក់ហូបចុក និងប្រាក់ហោប៉ៅ)។ ដោយឡែកប្រាក់ម៉ោងគ្រូបង្គោល ពុំត្រូវបានផ្តល់ជូនទេ
- **ទស្សនកិច្ចសិក្សា/វគ្គបណ្តុះបណ្តាលក្រៅស្រុក៖** ប្រាក់បេសកកម្មក្រៅស្រុក (ប្រាក់ស្នាក់នៅ, ប្រាក់ហូបចុក និងប្រាក់ហោប៉ៅ), ថ្លៃសំបុត្រយន្តហោះទៅ-មក និងចំណាយផ្សេងៗ (ទិដ្ឋការធ្វើដំណើរ, ធានារ៉ាប់រងធ្វើដំណើរ, និងថ្លៃធ្វើដំណើរក្នុងតំបន់)។ ចំពោះវត្ថុអនុស្សាវរីយ ជាទូទៅមិនត្រូវផ្តល់ជូនទេ តែអាចត្រូវបានផ្តល់ជូនសម្រាប់តែទស្សនៈកិច្ចសិក្សា និងក្នុងករណីចាំបាច់ប៉ុណ្ណោះ (ករណីម្ចាស់ផ្ទះមិនគិតថ្លៃសេវារៀបចំ ឬផ្តល់ការគាំទ្រហិរញ្ញវត្ថុចំណែកណាមួយសម្រាប់កម្មវិធី)។

❖ **ទីប្រឹក្សា៖ គ.ហ.ស.** លើកទឹកចិត្ត និងជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើប្រាស់ធនធានរបស់សាមីអង្គភាពផ្ទាល់ឱ្យអស់សក្តានុពល ក្នុងន័យកាត់បន្ថយការជួលទីប្រឹក្សា/ជំនាញការ និងបង្ហាញភាពជាម្ចាស់នៃការចូលរួមអនុវត្តការងារកែទម្រង់ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, និងគណនេយ្យភាព។ ក្នុងករណីអង្គភាពអនុវត្តគម្រោងមានតម្រូវការទីប្រឹក្សា/ជំនាញការជាចាំបាច់ ការគ្រោងថវិកាត្រូវផ្សារភ្ជាប់ជាមួយលទ្ធផលក្នុងឆ្នាំ និងផ្អែកលើលក្ខខណ្ឌយោងការងារ ព្រមទាំងត្រូវបញ្ជាក់រយៈពេលបំពេញការងារ និងការប៉ាន់ស្មានលើតម្លៃឈ្នួល ឱ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដូចមានលម្អិតក្នុងគំរូឧបសម្ព័ន្ធ២។ ការជួលទីប្រឹក្សាត្រូវបានបែងចែកជា ២ ប្រភេទគឺ៖ (១) សេវាកម្មដែលត្រូវបំពេញជាប្រចាំផ្អែកតាមម៉ោងបំពេញការងារ (Time Based) និង(២) សេវាកម្មដែលផ្អែកលើលទ្ធផល (Output Based)។ ការគ្រោងថវិកាសម្រាប់ទីប្រឹក្សាក៏ត្រូវគិតគូរផងដែរ ថាតើទីប្រឹក្សាដែលមានតម្រូវការគឺជាទីប្រឹក្សាជាតិ ឬអន្តរជាតិ។

❖ **ទំនិញ៖** ការស្នើសុំសម្ភារៈ និងឧបករណ៍ការិយាល័យអាចផ្តល់ជូនក្នុងករណីចាំបាច់ប៉ុណ្ណោះ។ ទំនិញ ត្រូវផ្តល់ជូនសម្រាប់ការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ប៉ុណ្ណោះ។ អត្រាសម្រាប់លទ្ធកម្មទំនិញ ត្រូវបានកំណត់តាមតម្លៃប៉ាន់ស្មានតាមអត្រាទីផ្សារ ឬ តាមអត្រាតម្លៃទំនិញដែលធ្លាប់បានធ្វើកិច្ចលទ្ធកម្មញឹកញាប់។ ទំនិញ ដែលអាចផ្តល់ជូន រួមមាន៖ កំព្យូទ័រយួរដៃ, កំព្យូទ័រលើតុ, ម៉ាស៊ីនបោះពុម្ព, ម៉ាស៊ីនថតចម្លង, ម៉ាស៊ីនបញ្ចាំងស្លាយ, ម៉ាស៊ីនមេ និងការបោះពុម្ពឯកសារជាដើម។

❖ **ប្រតិបត្តិការប្រចាំថ្ងៃ៖** ត្រូវគិតគូររៀបចំថវិកាប្រកបដោយភាពសន្សំសំចៃខ្ពស់ និងនវានុវត្តន៍ដោយប្រើប្រាស់បរិវត្តកម្មឌីជីថលឱ្យបានជាអតិបរមា។

ការគ្រោងថវិកាសម្រាប់មុខសញ្ញាចំណាយខាងលើត្រូវធ្វើឡើង ដោយអនុលោមតាមតារាងតម្លៃសម្រាប់រៀបចំផែនការថវិកា ដែលត្រូវបានភ្ជាប់ជូនក្នុងលិខិតជូនដំណឹងស្តីពីរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពលម្អិត និងផែនការថវិកាប្រចាំឆ្នាំ។ ជាការអនុវត្តកន្លងមក កញ្ចប់ថវិកាត្រូវផ្តល់ជូនដោយផ្អែកលើលទ្ធផលគន្លឹះក្នុងឆ្នាំដូចបានកំណត់ក្នុងពិតានថវិកា ប៉ុន្តែពុំទាន់ត្រូវបានលើកចិត្តបន្ថែមទំហំកញ្ចប់ថវិកាលើសពិតានថវិកាសម្រាប់ **គ.ហ.ស.** ណាដែលសម្រេចបានលទ្ធផលស្របតាម ឬ លើសពីការរំពឹងទុកនៅឡើយ។ ក្នុងគោលដៅលើកកម្ពស់សមិទ្ធកម្មក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់, **គ.ហ.ស.** ផ្តល់ការលើកទឹកចិត្តដល់ **គ.ហ.ស.** ណាដែលសម្រេចបានលទ្ធផលស្របតាម ឬ លើសការរំពឹងទុកដែលបានដាក់ចេញក្នុងលទ្ធផលគន្លឹះក្នុងឆ្នាំ ដោយបន្ថែមពិតានថវិកាជូន **គ.ហ.ស.** ប៉ុន្តែការបន្ថែមពិតានថវិកានេះ គឺសម្រាប់តែការងារអាទិភាពក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់តែប៉ុណ្ណោះ មិនអនុញ្ញាតសម្រាប់ការងារប្រចាំថ្ងៃ ឬ ការងាររដ្ឋបាលផ្សេងៗឡើយ។

## តារាងទី ៤ ៖ ទម្រង់ផែនការថវិកា នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| សកម្មភាព/ចង្កោមសកម្មភាព | | | | អនុគណនី | សំណើសុំថវិកាប្រចាំឆ្នាំ២០២៥ | | | | | | | ថវិកាអនុម័តប្រចាំឆ្នាំ២០២៥ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | តម្លៃក្នុងមួយដង/មួយលើក និងសរុបតម្រូវការថវិកា | | | | | | | អនុម័តតាមត្រីមាស | | | | |
| កូដថវិកា | #GDAP/MAP | #Output | បរិយាយ | | ឯកតា | ចំនួននាក់ | ចំនួនថ្ងៃ | តម្លៃឯកតា | សរុប | ចំនួនលើក | សរុបរួម | តម១ | តម២ | តម៣ | តម៤ | សរុប |
| | | | ក. សិក្ខាសាលា/វគ្គបណ្ដុះបណ្ដាល (ក្នុងស្រុក/ក្រៅស្រុក) | | | | | | | | | | | | | |
| 68.1 | 11.2.1- | 11.2.1 | រៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីការប្រើប្រាស់ប្រព័ន្ធ SARMIS ជូនដល់រដ្ឋបាល ឃុំ សង្កាត់ ចំនួន ១២៧ | | | | | | | | | | | | | |
| | | | អាហារសម្រន់ | | | | | | | | | | | | | |
| | | | ថតចម្លងឯកសារ + សម្ភារៈសម្រាប់វគ្គបណ្ដុះបណ្ដាល | | | | | | | | | | | | | |
| | | | ប្រាក់ហោប៉ៅ | | | | | | | | | | | | | |
| | | | ប្រាក់ហូកចុក | | | | | | | | | | | | | |
| | | | ថ្លៃធ្វើដំណើរ | | | | | | | | | | | | | |
| | | | ខ. ទីប្រឹក្សា (ក្នុងស្រុក/ក្រៅស្រុក) | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | គ. ទំនិញ | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | |
| | | | សរុបតម្រូវការថវិកា (ក)+(ខ)+(គ) | | | | | | | | | | | | | |

## ៤.៥. ផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានបន្ថែមពីលើបៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកដែលបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនប្រកប ដោយផលិតភាព គុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព ដោយប្រើប្រាស់ថវិកាក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការរៀបចំផែនការប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំរបស់ **ក.ហ.ស.** នៅតាមអង្គភាព ឬ ស្ថាប័ននីមួយៗ ត្រូវផ្អែកលើលទ្ធផលគន្លឹះក្នុងឆ្នាំ ដោយត្រូវអនុលោមតាមពិតានដែលបានកំណត់ដោយ **គ.ហ.ស.**។

ការផ្តល់ជូនប្រាក់ឧបត្ថម្ភលើកទឹកចិត្តជូន **ក.ហ.ស.** ត្រូវបានបែងចែកដូចខាងក្រោម៖

- **ក.ហ.ស. នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖** ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវបានបែងចែកជា ៥ ប្រភេទ រួមមាន៖ ប្រធានគម្រោង, អនុប្រធានគម្រោង, ប្រធានក្រុមការងារ, មន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីជំនាញ ដែលប្រភេទនីមួយៗត្រូវបានកំណត់ដោយសន្ទស្សន៍ ដូចមានចែងក្នុងប្រកាសស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានក្នុង ឧបសម្ព័ន្ធ៣។ សមាសភាព **ក.ហ.ស.** ដែលទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្តពីប្រភពផ្សេងរួចហើយ គឺពុំអាចទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្រោមកម្មវិធីកែទម្រង់នេះឡើយ។
- **ក.ហ.ស. នៃក្រសួង ស្ថាប័ន៖** ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវបានបែងចែកជា ៤ ប្រភេទ រួមមាន៖ ប្រធាន **ក.ហ.ស.**, អនុប្រធាន **ក.ហ.ស.**, មន្ត្រីបង្គោល និងសមាជិក។ សមាសភាព **ក.ហ.ស.** នៃក្រសួង ស្ថាប័នដែលត្រូវទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវកម្រិតត្រឹម ១០ រូប រួមមាន៖ ប្រធាន **ក.ហ.ស. ១ រូប**, អនុប្រធាន **ក.ហ.ស.** ១ រូប, មន្ត្រីបង្គោល ១ រូប និងសមាជិក ៧ រូប។
- **ក.ហ.ស. នៃរដ្ឋបាលរាជធានី ខេត្ត៖** សម្រាប់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តនៃ **ក.ហ.ស.** នៅតាមរដ្ឋបាលរាជធានី ខេត្ត ត្រូវកម្រិតត្រឹមចំនួន ៥ រូប រួមមាន៖ ប្រធាន **ក.ហ.ស.** ១ រូប, អនុប្រធាន **ក.ហ.ស.** ១ រូប, មន្ត្រីបង្គោល ១ រូប និងសមាជិក ២ រូប។ ចំពោះអត្រាប្រាក់ឧបត្ថម្ភលើកទឹកចិត្តរបស់ **ក.ហ.ស.** នៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត តាមប្រភេទនីមួយៗ ត្រូវបានកំណត់ក្នុងប្រកាសស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ដូចមានក្នុងក្នុងឧបសម្ព័ន្ធ៤។

អនុលោមតាមពិតានដែលបានកំណត់ដោយ **គ.ហ.ស.**, **ក.ហ.ស.** នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តទាំងអស់ ត្រូវរៀបចំផែនការលើកទឹកចិត្តប្រចាំឆ្នាំ និងសមាសភាពដែលត្រូវទទួលប្រាក់ឧបត្ថម្ភ និងលក្ខខណ្ឌយោងការងារ ដូចមានចែងក្នុងប្រកាសស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ក្នុងឧបសម្ព័ន្ធ ៣ និង ៤ ខាងលើ ដោយត្រូវភ្ជាប់ជាមួយនឹងលទ្ធផលគន្លឹះក្នុងឆ្នាំ, ផែនការសកម្មភាពលម្អិត និងផែនការថវិកា រួចផ្ញើមក **អ.គ.ហ.** យ៉ាងយូរត្រឹមសប្តាហ៍ទី១ ខែតុលា មុនឆ្នាំអនុវត្ត។ **អ.គ.ហ.** ត្រូវបូកសរុបផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំពីគ្រប់ **ក.ហ.ស.** នៅតាមអង្គភាព ឬ ស្ថាប័ន និងសមាសភាពទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំពីគ្រប់អង្គភាព ឬ ស្ថាប័ន ដើម្បីដាក់ឆ្លងប្រធាន **គ.ហ.ស.** អនុម័តនៅត្រឹមដំណាច់ឆ្នាំ មុនឆ្នាំអនុវត្ត។ សមាសភាព **ក.ហ.ស.** នៃអង្គភាពក្រោមឱវាទ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្រោមកម្មវិធីកែទម្រង់ត្រូវកំណត់ដោយសេចក្ដី-សម្រេចរបស់ប្រធាន **គ.ហ.ស.** តាមការស្នើសុំរបស់ **អ.គ.ហ.**។ **ក.ហ.ស.** មានសិទ្ធិផ្លាស់ប្ដូរសមាសភាពទទួលបានប្រាក់ឧបត្ថម្ភប្រចាំអង្គភាព ឬ ស្ថាប័នរបស់ខ្លួនក្នុងឆ្នាំអនុវត្តតាមការចាំបាច់ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយត្រូវភ្ជាប់នូវសមាសភាព និងលក្ខខណ្ឌយោងការងារថ្មីមក **អ.គ.ហ.** យ៉ាងយូរត្រឹមសប្ដាហ៍ទី២ នៃខែទី១ នៃត្រីមាសបន្ទាប់ ក្រោយពីការបើកផ្ដល់ប្រាក់ឧបត្ថម្ភរួចរាល់ប្រចាំត្រីមាសណាមួយ។

## ៤.៦. កិច្ចព្រមព្រៀងសមិទ្ធកម្ម

កិច្ចព្រមព្រៀងសមិទ្ធកម្ម គឺជាដំណាក់កាលចុងក្រោយនៃដំណើរការនៃការរៀបចំផែនការ ដែលត្រូវបានដាក់ឱ្យអនុវត្តដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាពសមិទ្ធកម្មរបស់ **ក.ហ.ស.** នៅតាមអង្គភាព និងស្ថាប័នអនុវត្តកម្មវិធីទម្រង់នីមួយៗ ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាពនៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិត ដោយផ្សារភ្ជាប់ជាមួយនឹងកញ្ចប់ថវិកាគាំទ្រការអនុវត្ត និងប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ បញ្ញត្តិសំខាន់ៗដែលត្រូវចែងក្នុងកិច្ចព្រមព្រៀងសមិទ្ធកម្មនេះរួមមាន៖ ការព្រមព្រៀងលើលទ្ធផលគន្លឹះក្នុងឆ្នាំ, ការផ្ដល់កញ្ចប់ថវិកាសម្រាប់គាំទ្រការអនុវត្ត និងប្រាក់ឧបត្ថម្ភលើកទឹកចិត្តដែលចងភ្ជាប់ជាមួយលទ្ធផលគន្លឹះក្នុងឆ្នាំនីមួយៗដែលបានកំណត់ខាងលើ រួមទាំងការកំណត់អំពីលក្ខខណ្ឌនៃការបើកផ្ដល់ និងកាលបរិច្ឆេទចាប់ផ្ដើមអនុវត្តនិងបិទបញ្ចប់។ ក្នុងទិដ្ឋភាពថវិកា កិច្ចព្រមព្រៀងសមិទ្ធកម្មក៏បានបញ្ញត្តផងដែរអំពីការផ្ដល់ការលើកទឹកចិត្តដោយបន្ថែមពិតានថវិកាសម្រាប់ឆ្នាំបន្ទាប់ ជូនដល់ **ក.ហ.ស.** ណាដែលបានសម្រេចពេញលេញ ឬ លើសពីការរំពឹងទុកដូចក្នុងលទ្ធផលគន្លឹះក្នុងឆ្នាំដែលបានព្រមព្រៀងគ្នា ឬ ករណីឆ្នាំបន្ទាប់ **ក.ហ.ស.** គ្រោងលទ្ធផលគន្លឹះក្នុងឆ្នាំ ដែលមានបច្ច័យខ្ពស់ដល់ការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

បន្ទាប់ពីបញ្ចប់ការរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពលម្អិត ផែនការថវិកា និងផែនការផ្ដល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ, **អ.គ.ហ.** និង **ក.ហ.ស.** នៃអង្គភាព ឬ ស្ថាប័ននីមួយៗ ត្រូវរៀបចំចុះកិច្ចព្រមព្រៀងសមិទ្ធកម្ម ឱ្យបានរួចរាល់យ៉ាងយូរត្រឹមខែមករា នៃឆ្នាំអនុវត្ត ដើម្បីធានានូវគណនេយ្យភាពចំពោះទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពសមិទ្ធកម្ម។ កិច្ចព្រមព្រៀងសមិទ្ធកម្ម ត្រូវប្រើប្រាស់លទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការថវិកា និងផែនការប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំរបស់អង្គភាព ឬ ស្ថាប័ននីមួយៗ ជាឧបសម្ព័ន្ធ។

កិច្ចព្រមព្រៀងសមិទ្ធកម្មរវាង **អ.គ.ហ.** និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ឬ រដ្ឋបាលរាជធានី ខេត្ត ត្រូវចុះហត្ថលេខា ដោយអគ្គលេខាធិការរង នៃ **អ.គ.ហ.** ក្នុងនាមជាប្រតិបត្តិករផ្ដល់ហិរញ្ញវត្ថុ និង ប្រធាន **ក.ហ.ស.** ប្រចាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ ប្រធាន **ក.ហ.ស.** ប្រចាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ឬ ប្រធាន **ក.ហ.ស.** ប្រចាំ រដ្ឋបាលរាជធានី ខេត្ត ក្នុងនាមជាអង្គភាព ឬ ស្ថាប័នអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ អគ្គលេខាធិការ នៃ **អ.គ.ហ.** ត្រូវចុះហត្ថលេខាផ្ដល់ការឯកភាព ក្នុងនាមជាសេនាធិការ នៃ **គ.ហ.ស.**។

កិច្ចព្រមព្រៀងសមិទ្ធកម្មរវាង **អ.គ.ហ.** និងក្រសួង-ស្ថាប័ន ត្រូវចុះហត្ថលេខាដោយអគ្គលេខាធិការនៃ **អ.គ.ហ.** ក្នុងនាមជាប្រតិបត្តិករផ្ដល់ហិរញ្ញវត្ថុ និងប្រធាន **ក.ហ.ស.** ប្រចាំក្រសួង-ស្ថាប័ន ក្នុងនាមជាអង្គភាព ឬ ស្ថាប័នអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងករណីប្រធាន **ក.ហ.ស.** ជារដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័ន អនុប្រធាន **ក.ហ.ស.** ត្រូវចុះហត្ថលេខាជំនួសប្រធាន **ក.ហ.ស.**។ ប្រធាន **គ.ហ.ស.** និង រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នសាមី ត្រូវចុះហត្ថលេខាផ្ដល់ការឯកភាព។

**អ.គ.ហ.** ត្រូវប្រមូលសរុបកិច្ចព្រមព្រៀងសមិទ្ធកម្មពីគ្រប់អង្គភាព ឬ ស្ថាប័ន ដាក់ជូនប្រធាន **គ.ហ.ស.** ឯកភាព និងដាក់ឱ្យអនុវត្តយ៉ាងយូរនៅក្នុងខែមករា នៃឆ្នាំអនុវត្ត។ ទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្ម មានភ្ជាប់ក្នុងឧបសម្ព័ន្ធ៥។

*តារាងទី ៥ ៖ ក្របខ័ណ្ឌពេលវេលានៃការរៀបចំផែនការ*

| ល.រ | ផែនការ | គោលដៅ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ផែនការសកម្មភាពរួម បច្ចុប្បន្នកម្ម (ករណីចាំបាច់) | ពិនិត្យនិងធ្វើបច្ចុប្បន្នកម្មចង្កោមសកម្មភាព, គោលបំណង តាមផ្នែកនីមួយៗ ដោយ អ.គ.ហ. | | | | | | | | | | | | |
| | | កិច្ចប្រជុំចង្អៀត និងសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ | | | | | | | | | | | | |
| | | ពិនិត្យនិងអនុម័តដោយ គ.ហ.ស. | | | | | | | | | | | | |
| ២ | លទ្ធផលគន្លឹះក្នុងឆ្នាំ, ផែនការសកម្មភាព, ផែនការថវិកា និងផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ | អង្គភាពអនុវត្តរៀបចំសេចក្តីព្រាងផែនការទាំង ៤ តាមការស្នើសុំរបស់ អ.គ.ហ. | | | | | | | | | | | | |
| | | កិច្ចប្រជុំពិនិត្យពិភាក្សាកម្រិតបច្ចេកទេស | | | | | | | | | | | | |
| | | កិច្ចប្រជុំពិនិត្យពិភាក្សាកម្រិតថ្នាក់ដឹកនាំ | | | | | | | | | | | | |
| | | អនុម័ត និងដាក់ឱ្យអនុវត្ត ដោយ គ.ហ.ស. | | | | | | | | | | | | |
| ៣ | កិច្ចព្រមព្រៀងសមិទ្ធកម្ម | ចុះកិច្ចព្រមព្រៀងសមិទ្ធកម្ម ដោយផ្អែកលើលទ្ធផលគន្លឹះក្នុងឆ្នាំ, ផែនការសកម្មភាព, ផែនការថវិកា និងផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំដែលទទួលបានការអនុម័ត | | | | | | | | | | | | |

# ជំពូក ៥. ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្ម

វិធាន និងនីតិវិធីនៃការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្ម ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ នេះ ត្រូវបានបែងចែកជាដំណាក់កាល ដូចតទៅ៖ ការរៀបចំរបាយការណ៍សមិទ្ធកម្ម, ការរៀបចំកិច្ចប្រជុំតាមដាននិងវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់, និងការកែសម្រួលផែនការសកម្មភាពផ្អែកតាមព័ត៌មានសមិទ្ធកម្ម។

## ៥.១. វិធីសាស្ត្រត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្ម

### ក. ទស្សនទាននៃការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ

ជាទូទៅ ការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃ មានភាពប្រទាក់ក្រឡា និងទំនាក់ទនងគ្នាយ៉ាងស្អិតរមួត ដែលពេលខ្លះធ្វើឱ្យមានការយល់ច្រឡំដល់អង្គភាពអនុវត្តលើពាក្យគន្លឹះទាំង ២ នេះ។ ការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃគឺជាដំណើរការសំខាន់ក្នុងការគ្រប់គ្រងសមិទ្ធកម្ម ប៉ុន្តែកិច្ចការទាំងពីរនេះបម្រើឱ្យគោលបំណងផ្សេងគ្នា និងធ្វើឡើងនៅពេលផ្សេងគ្នា។ ការត្រួតពិនិត្យ គឺជាសកម្មភាពដែលកំពុងបន្ត និងក្នុងពេលអនុវត្តជាក់ស្តែង ដែលផ្តោតលើការតាមដានវឌ្ឍនភាព និងធានាថាការងារមួយស្ថិតនៅលើផ្លូវត្រូវតាមផែនការដែលបានគ្រោងទុក។ ខណៈ ការវាយតម្លៃត្រូវធ្វើឡើងតាមកាលកំណត់ណាមួយ ដែលវាស់ស្ទង់សមិទ្ធកម្មការងារក្រោយពេលអនុវត្តក្នុងពេលវេលាជាក់លាក់ ដោយធ្វើការប្រៀបធៀបរវាងវឌ្ឍនភាពដែលសម្រេចបាន ទៅនឹងគោលដៅសមិទ្ធកម្មដែលត្រូវបានកំណត់ក្នុងដំណាក់កាលរៀបចំផែនការ។ ដំណើរការទាំងពីរផ្តល់នូវមូលដ្ឋានដ៏មានសារៈសំខាន់ដោយ ការត្រួតពិនិត្យជួយដល់ការកែតម្រូវផែនការសកម្មភាពភ្លាមៗទាន់សភាពការណ៍ ខណៈការវាយតម្លៃផ្តោតលើលទ្ធផលដើម្បីជាព័ត៌មានដល់ការសម្រេចចិត្តនាពេលអនាគត។ ទន្ទឹមនេះ ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ធានាបាននូវគណនេយ្យភាព ការកែលម្អជាបន្តបន្ទាប់ និងការតម្រឹមផែនការសកម្មភាពនៅគ្រប់គម្រិតស្របតាមគោលដៅដែលបានគ្រោងទុក។ ជារួម ទស្សនទាននៃការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ត្រូវបានលម្អិត ដូចខាងក្រោម៖

❖ **ការត្រួតពិនិត្យ តាមដាន៖**

ការត្រួតពិនិត្យ តាមដាន សំដៅដល់ដំណើរការនៃការប្រមូល វិភាគ និងប្រើប្រាស់ព័ត៌មានជាប្រព័ន្ធ ដើម្បីតាមដានវឌ្ឍនភាពនៃគម្រោង កម្មវិធី ឬ សកម្មភាពឆ្ពោះទៅរកគោលដៅរបស់អង្គភាព។ ការត្រួតពិនិត្យផ្តល់នូវព័ត៌មានថាសកម្មភាពគឺស្ថិតនៅលើគន្លងត្រូវ, ផ្តល់នូវលទ្ធភាពកែតម្រូវផែនការទាន់ពេលវេលា និងជាមូលដ្ឋានសម្រាប់ការសម្រេចចិត្ត និងគណនេយ្យភាពចំពោះសមិទ្ធកម្ម។

**សមាសធាតុសំខាន់ៗនៃការត្រួតពិនិត្យតាមដាន៖**

- **ការប្រមូលទិន្នន័យ៖** ការប្រមូលទិន្នន័យពាក់ព័ន្ធនឹងសូចនាករសមិទ្ធកម្មគន្លឹះ (KPIs) និងវឌ្ឍនភាពដែលសម្រេចបានជាប្រចាំ
- **ការវិភាគ៖** ការវាយតម្លៃវឌ្ឍនភាព ដើម្បីកំណត់ថាតើវឌ្ឍនភាពដែលកំពុងសម្រេចបាន ឆ្ពោះទៅសម្រេចបានតាមគោលដៅ និងគោលបំណងដែលបានកំណត់ដែរឬទេ
- **ការរាយការណ៍៖** បូកសរុបវឌ្ឍនភាព បញ្ហាប្រឈម និងគម្លាតរវាងសមិទ្ធកម្មដែលសម្រេចបានជាក់ស្តែងធៀបនឹងគោលដៅដែលបានកំណត់
- **យន្តការកែលម្អ៖** ប្រើប្រាស់ព័ត៌មានដែលទទួលបានពីការត្រួតពិនិត្យសមិទ្ធកម្ម ដើម្បីកែតម្រូវយុទ្ធសាស្ត្រ ឬ ផែនការ ដោយធ្វើការបែងចែកធនធាន ព្រមទាំងកំណត់ពេលវេលា ដើម្បីកែលម្អលទ្ធផលចុងក្រោយ។

**គោលបំណងនៃការត្រួតពិនិត្យ តាមដាន៖**

- **គណនេយ្យភាព៖** ធានាថាធនធានត្រូវបានប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព ហើយសកម្មភាពកំពុងរួមចំណែកឆ្ពោះទៅរកលទ្ធផលដែលបានគ្រោងទុក
- **តាមដានការអនុវត្ត៖** វាស់វែងថាតើគម្រោង ឬ កម្មវិធីមួយកំពុងដំណើរការ និងសម្រេចតាមគោលដៅដែលបានគ្រោង
- **ការព្រមានជាមុន៖** កំណត់បញ្ហាដែលអាចកើតមាន ឬ គម្លាតដែលត្រូវការកែតម្រូវ មុនពេលវិវត្តក្លាយជាបញ្ហាធំ។

## ❖ ការវាយតម្លៃ៖

ការវាយតម្លៃ គឺជាការវាយតម្លៃជាប្រព័ន្ធនៃគម្រោង កម្មវិធី ឬ គោលនយោបាយដែលកំពុងបន្ត ឬ បានបញ្ចប់ រួមទាំងការរៀបចំ ការអនុវត្ត និងសម្រេចបានលទ្ធផល។ ការវាយតម្លៃពាក់ព័ន្ធនឹងការប្រៀបធៀបសមិទ្ធកម្មជាក់ស្តែងជាមួយនឹងគោលដៅដែលបានគ្រោងទុក ដើម្បីកំណត់ពីភាពពាក់ព័ន្ធ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងកម្មវិបាកដែលទទួលបានពីការអនុវត្តគម្រោង កម្មវិធី ឬ គោលនយោបាយនោះ។ ការវាយតម្លៃជួយក្នុងការរៀនសូត្រពីបទពិសោធន៍ កែលម្អគំនិតផ្តួចផ្តើមថ្មី និងធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹង។

**សមាសធាតុសំខាន់ៗនៃការវាយតម្លៃ៖**

- **ភាពពាក់ព័ន្ធ៖** វាយតម្លៃថាតើគោលបំណងរបស់គម្រោង ឬ កម្មវិធី ស្របតាមអាទិភាពនិងតម្រូវការចាំបាច់ដែរឬទេ
- **ប្រសិទ្ធភាព៖** វាយតម្លៃថាតើធនធាន (ពេលវេលា ថវិកា និងធនធានមនុស្ស) ត្រូវបានប្រើប្រាស់ប្រកដបដោយឧត្តមានុពល ដើម្បីសម្រេចបានលទ្ធផលដែរឬទេ
- **ស័ក្តិសិទ្ធិភាព៖** វាយតម្លៃថាតើគោលដៅដែលបានកំណត់ត្រូវសម្រេចបានដែរឬទេ និងថាតើសមិទ្ធកម្មដែលសម្រេចបានមានបច្ច័យទៅសម្រេចនូវលទ្ធផលដែលបានគ្រោងទុកឬទេ
- **កម្មវិបាក៖** ការយល់ដឹងពីផលប៉ះពាល់លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋគោលដៅ ឬ បរិស្ថាន និងរួមទាំងផលវិបាកនានាផងដែរ
- **និរន្តរភាព៖** ពិនិត្យថាគម្រោង ឬ កម្មវិធី ទំនងជាបន្តផ្តល់អត្ថប្រយោជន៍ដែរឬទេ បន្ទាប់ពីគម្រោង ឬ កម្មវិធីត្រូវបានបញ្ចប់ជាស្ថាពរ។

**គោលបំណងនៃការវាយតម្លៃ៖**

- **ការរៀនសូត្រ និងការកែលម្អ៖** ផ្តល់នូវការយល់ដឹងអំពីអ្វីដែលអាចអនុវត្តបាន អ្វីមិនអាចអនុវត្តបាន និងមូលហេតុដែលអាចត្រូវបានប្រើដើម្បីកែលម្អគម្រោង ឬ កម្មវិធីនាពេលអនាគត
- **គណនេយ្យភាព៖** ធានាថាអ្នកដែលទទួលខុសត្រូវចំពោះគម្រោង ឬ កម្មវិធីអាចបង្ហាញអំពីតម្លៃ និងភាពត្រឹមត្រូវនៃការប្រើប្រាស់ធនធាន
- **ការសម្រេចចិត្ត៖** ផ្តល់ព័ត៌មានឬទស្សនទានដល់អ្នករៀបចំគោលនយោបាយ អ្នកផ្តល់មូលនិធិ និងអ្នកគ្រប់គ្រងគម្រោង ឬ កម្មវិធី ដើម្បីដាក់ចេញជាយុទ្ធសាស្ត្រ ឬ ផែនការសម្រាប់អនុវត្តនាពេលអនាគត។

ចំពោះការត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវធ្វើឡើងជា ២ កម្រិតគឺ៖ (១) ផែនការសកម្មភាពរួម (CAP) សម្រាប់តាមដាន និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្ត

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជារួម និង (២) ផែនការសមិទ្ធកម្ម (លទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិត) របស់អង្គភាព ឬ ស្ថាប័នអនុវត្ត។ ជាមួយគ្នានេះ ការត្រួតពិនិត្យ ត្រូវបានធ្វើឡើងប្រចាំត្រីមាស បន្ទាប់ពីចប់ត្រីមាសអនុវត្ត រីឯការវាយតម្លៃត្រូវបានធ្វើឡើងប្រចាំឆ្នាំ បន្ទាប់ពីចប់ឆ្នាំអនុវត្ត។ ការត្រួតពិនិត្យ និងវាយតម្លៃ ត្រូវអនុវត្តដូចខាងក្រោម៖

### ខ. ការត្រួតពិនិត្យ និងវាយតម្លៃផែនការសកម្មភាពរួម

ក្នុងគោលបំណងផ្តល់នូវទិដ្ឋភាពវាយតម្លៃកាន់តែច្បាស់លាស់ផ្អែកលើសមិទ្ធកម្ម និងផ្តល់នូវភាពងាយស្រួលដល់ **គ.ហ.ស.** ពិនិត្យនិងវាយតម្លៃវឌ្ឍនភាពជារួម ការវាយតម្លៃផែនការសកម្មភាពរួម ត្រូវបានធ្វើឡើងប្រចាំឆ្នាំ ដោយផ្អែកលើវឌ្ឍនភាពនៃការអនុវត្តគោលដៅសូចនាករសមិទ្ធកម្មគន្លឹះនៅតាមចង្កោមសកម្មភាព និងគោលបំណងដែលបានកំណត់នៅក្នុងផែនការសកម្មភាពរួម ហើយប្រើប្រាស់លក្ខខណ្ឌវាយតម្លៃជាពណ៌ ដែលត្រូវបានកំណត់រួចរាល់នៅក្នុងដំណាក់កាលរៀបចំផែនការ។ ទន្ទឹមនេះ ការវាយតម្លៃ ត្រូវផ្តោតទាំងស្រុងលើគោលដៅសូចនាករសមិទ្ធកម្មគន្លឹះនៅតាមចង្កោមសកម្មភាពនិងគោលបំណង ដែលបានកំណត់ក្នុងផែនការសកម្មភាពរួម។ រីឯ ការត្រួតពិនិត្យ និងតាមដានការអនុវត្ត ត្រូវធ្វើឡើងប្រចាំត្រីមាស ដោយផ្អែកលើវឌ្ឍនភាពដែលសម្រេចបានតាមរយៈការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពប្រចាំត្រីមាស របស់អង្គភាព និងស្ថាប័ន ដើម្បីបូកសរុបនិងរាយការណ៍ជូន **គ.ហ.ស.**។ ការ-ត្រួតពិនិត្យនិងតាមដានវឌ្ឍនភាពប្រចាំត្រីមាសនេះ មិនត្រូវបានវាយតម្លៃសមិទ្ធកម្មជាពិន្ទុភាគរយ ឬ កំណត់ពណ៌ដូចទៅនឹងការវាយតម្លៃប្រចាំឆ្នាំឡើយ, ពោលខ្លឹមសាររបាយការណ៍នឹងបង្ហាញវឌ្ឍនភាពជាលក្ខណៈបរិយាយតែប៉ុណ្ណោះ ហើយអាចធ្វើការកត់សម្គាល់នូវកិច្ចការណាដែលមានភាពយឺតយ៉ាវ ដើម្បីដាក់ជូន **គ.ហ.ស.** ពិនិត្យសម្រេច ឬ ដាក់ចេញយន្តការជំរុញការអនុវត្ត។

### គ. ការត្រួតពិនិត្យ និងវាយតម្លៃផែនការសមិទ្ធកម្ម

ការត្រួតពិនិត្យ និងវាយតម្លៃផែនការសមិទ្ធកម្ម សំដៅដល់ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិតរបស់អង្គភាព និងស្ថាប័នអនុវត្ត។ ការវាយតម្លៃសមិទ្ធកម្មរបស់អង្គភាព និងស្ថាប័នអនុវត្ត ត្រូវផ្តោតលើលទ្ធផលគន្លឹះក្នុងឆ្នាំទាំងស្រុង ហើយត្រូវផ្អែកតាមលក្ខខណ្ឌវាយតម្លៃជាពណ៌ ដែលត្រូវបានកំណត់រួចរាល់នៅដំណាក់កាលរៀបចំផែនការ។ រីឯ ផែនការសកម្មភាពលម្អិត ត្រូវបានប្រើប្រាស់សម្រាប់ការអនុវត្ត និងការ-តាមដានផ្ទៃក្នុងអង្គភាព និងស្ថាប័ននីមួយៗ និងសម្រាប់ជាឧបករណ៍រាយការណ៍នៅតាមត្រីមាសនីមួយៗជូន **គ.ហ.ស.** ប៉ុណ្ណោះ។ ក្នុងន័យនេះ ការត្រួតពិនិត្យ និងវាយតម្លៃផែនការសកម្មភាពលម្អិត មិនត្រូវបានប្រើប្រាស់លក្ខខណ្ឌវាយតម្លៃជាពណ៌ ឬ ពិន្ទុភាគរយឡើយ ពោលគឺសមិទ្ធកម្មត្រូវឆ្លុះបញ្ចាំងតាមរយៈវឌ្ឍនភាពដែលសម្រេចបានជាក់ស្តែងជាលក្ខណៈបរិយាយតែប៉ុណ្ណោះ ហើយសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពលម្អិតនេះ មិនត្រូវបានប្រើប្រាស់សម្រាប់ជាមូលដ្ឋានក្នុងការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ឡើយ។

### ឃ. គោលការណ៍ប្រើប្រាស់លក្ខខណ្ឌវាយតម្លៃ

ការវាយតម្លៃសមិទ្ធកម្ម ត្រូវបានធ្វើឡើងប្រចាំឆ្នាំដោយផ្អែកតាមលក្ខខណ្ឌវាយតម្លៃដោយប្រើប្រាស់ពណ៌សម្រាប់វាស់វែងសមិទ្ធកម្មធៀបនឹងគោលដៅដែលបានកំណត់ប្រចាំឆ្នាំ។ ដូចបានគូសបញ្ជាក់ខាងលើ ការប្រើប្រាស់លក្ខខណ្ឌវាយតម្លៃជាពណ៌នេះ គឺសម្រាប់តែការវាយតម្លៃការអនុវត្តផែនការសកម្មភាពរួម និងលទ្ធផលគន្លឹះក្នុងឆ្នាំរបស់អង្គភាព ឬស្ថាប័នអនុវត្តតែប៉ុណ្ណោះ គឺពុំមានវិសាលភាពអនុវត្តចំពោះផែនការសកម្មភាពលម្អិតឡើយ។

លក្ខខណ្ឌវាយតម្លៃ ត្រូវបានកំណត់ជា ៤ ពណ៌ ហើយពណ៌នីមួយៗត្រូវបានកំណត់រួចរាល់នៅក្នុងដំណាក់កាលរៀបចំផែនការ។ ពណ៌នីមួយៗមានអត្ថន័យ ដូចតទៅ៖

- ■ (បៃតងចាស់) សម្រេចពេញលេញ និងបានបិទបញ្ចប់,
- ◆ (បៃតងខ្ចី) មានវឌ្ឍនភាពច្រើន ឬ ស្ទើនឹងបិទបញ្ចប់,
- ▲ (លឿង) មានវឌ្ឍនភាពយឺតយ៉ាវ និងទាបជាងគោលដៅ និង
- ● (ក្រហម) មានវឌ្ឍនភាពយឺតយ៉ាវខ្លាំង ឬ គ្មានវឌ្ឍនភាព។

**ឧទាហរណ៍១៖ ការវាយតម្លៃផែនការសកម្មភាពរួមកម្រិតគោលបំណង** (កម្រិតគោលបំណង និងចង្កោមសកម្មភាពគឺប្រើប្រាស់វិធីសាស្ត្រដូចគ្នា)

- គោលបំណង១១៖ បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល
- សូចនាករសមិទ្ធកម្មគន្លឹះ១៖ ភាគរយនៃការអនុវត្តចំណូលថវិកាធៀបនឹងច្បាប់ថវិកា
- លក្ខខណ្ឌវាយតម្លៃ៖ ការអនុវត្តចំណូលចរន្តធៀបនឹងច្បាប់ថវិកា
  - ■ : +/-៥%
  - ◆ : +/-១០%
  - ▲ : +/-១៥%
  - ● : +/- >២០%
- គោលដៅប្រចាំឆ្នាំ៖ ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកាជារៀងរាល់ឆ្នាំ។

នៅពេលវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ ក្នុងករណីការអនុវត្តចំណូលចរន្តសម្រេចបាន ៩០.៧% ធៀបនឹងច្បាប់ថវិកាប្រចាំឆ្នាំ (១០០% - ៩០.៧% = ៩.៣%) គឺគម្លាតស្ថិតនៅក្នុងរង្វង់ +/-១០% ដូច្នេះ គោលបំណងនេះ សម្រេចបាន ◆ (បៃតងខ្ចី)។ ប៉ុន្តែ បើសិនជាការអនុវត្តចំណូលចរន្តមានគម្លាតផ្សេងពី +/-១០% ពណ៌សមិទ្ធកម្ម នឹងត្រូវទទួលបានតាមពណ៌នីមួយៗដែលបានកំណត់ខាងលើ។

**ឧទាហរណ៍២៖ ការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំ**

- លទ្ធផលគន្លឹះក្នុងឆ្នាំ៖ ឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- សូចនាករសមិទ្ធកម្មគន្លឹះ៖ Blueprint និងផែនការសកម្មភាពលម្អិតត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត
- លក្ខខណ្ឌវាយតម្លៃ៖
  - ■ : អនុម័ត និងដាក់ឱ្យអនុវត្ត
  - ◆ : បានប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ
  - ▲ : បានប្រជុំពិភាក្សាកម្រិតបច្ចេកទេស
  - ● : មានសេចក្តីព្រាងបឋម ឬគ្មានវឌ្ឍនភាព
- គោលដៅប្រចាំឆ្នាំ៖ ឯកសារគោល (Blueprint) និងផែនការសកម្មភាពលម្អិតស្តីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត។

នៅពេលវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ ក្នុងករណីវឌ្ឍនភាពលទ្ធផលគន្លឹះខាងលើត្រូវបាន អនុម័ត និងដាក់ឱ្យអនុវត្ត ដូច្នេះលទ្ធផលនេះ សម្រេចបាន ■ (បៃតងចាស់)។ ប៉ុន្តែ បើសិនជាការអនុវត្តសម្រេចបានទាបជាងនេះ ពណ៌សមិទ្ធកម្ម នឹងត្រូវទទួលបានតាមពណ៌នីមួយៗដែលបានកំណត់ខាងលើ។

របាយការណ៍ផែនការសកម្មភាពរួម, របាយការណ៍អនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ, និងរបាយការណ៍អនុវត្តផែនការសកម្មភាពលម្អិតប្រចាំត្រីមាស/ឆ្នាំ ត្រូវអនុវត្តតាមទម្រង់គំរូ ដូចក្នុងតារាងទី៦, ៧, ៨ ខាងក្រោម៖

## *តារាងទី ៦ ៖ ទម្រង់របាយការណ៍ផែនការសកម្មភាពរួម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| គោលបំណង/ចង្កោមសកម្មភាព | អង្គភាពអនុវត្ត | សូចនាករសមិទ្ធកម្មគន្លឹះ | លទ្ធផលគោល | លក្ខខណ្ឌវាយតម្លៃប្រចាំឆ្នាំ២០២៤ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ | | | ឯកសារភស្តុតាង |
|---|---|---|---|---|---|---|---|---|
| | | | | | ឆ្នាំ២០២៤ | ពណ៌ | វឌ្ឍនភាព | |
| ១១. បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល | កសហវ. ក្រសួង ស្ថាប័ន | សគ ១.<br>ភាគរយនៃការអនុវត្តចំណូលថវិកាធៀបនឹងច្បាប់ថវិកា | ឆ្នាំ២០២១៖<br>ចំណូលចរន្ត សម្រេចបាន ១០៤,៤៩% ធៀបនឹងច្បាប់ថវិកា | ការអនុវត្តចំណូលចរន្តធៀបនឹងច្បាប់ថវិកា<br>■ : +/-៥%<br>◆ : +/-១០%<br>▲ : +/-១៥%<br>● : +/- >២០% | ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកាជារៀងរាល់ឆ្នាំ | ◆ | ការអនុវត្តចំណូលចរន្តសម្រេចបាន ៩០.៧% ធៀបនឹងច្បាប់ | របាយការណ៍ចំណូល |
| | | សគ ២.<br>កំណើនចំណូលចរន្តធៀបនឹងផ.ស.ស. | ឆ្នាំ២០២១៖ ចំណូលចរន្តថយចុះ -២,៦៨ ភាគរយ នៃ ផ.ស.ស. | (ចំណូលចរន្តឆ្នាំ N/ផ.ស.ស. ឆ្នាំ N) - (ចំណូល ចរន្តឆ្នាំ N-1/ផ.ស.ស ឆ្នាំ N-1)<br>■ : >= ០,៣<br>◆ : >= 0.២ , < 0.៣<br>▲: >= 0.១ , < 0.២<br>● : <= 0 , < 0.១ | យ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស | ● | កំណើនចំណូលចរន្តសម្រេចបាន -២,៤៤ ពិន្ទុភាគរយធៀបនឹង ផសស | របាយការណ៍ចំណូល |
| ១១.១. អនុវត្តគោល-នយោបាយ និងកែទម្រង់រដ្ឋបាលគយ និងពន្ធដារ | អ.ព.ដ. | <u>សច ១.</u><br>ពន្ធលើប្រាក់ចំណេញមូលធន (Capital Gain Tax) ត្រូវបានអនុវត្ត | ឆ្នាំ២០២១៖<br>បទប្បញ្ញត្តិ រំហូរការងារ និងរចនាសម្ព័ន្ធអង្គភាពពាក់ព័ន្ធនឹងការប្រមូលពន្ធលើចំណេញមូលធន (Capital Gain Tax) ត្រូវបានរៀបចំ | របាយការណ៍លទ្ធផលនៃការអនុវត្តពន្ធលើចំណេញមូលធន (Capital Gain Tax)<br>■ : មានរបាយការណ៍<br>◆ :<br>▲:<br>● : ពុំមានរបាយការណ៍ | ការអនុវត្តការប្រមូលពន្ធលើចំណេញមូលធន (Capital Gain Tax) ត្រូវបានផ្សព្វផ្សាយ | ● | ពន្ធលើចំណេញមូលធន ត្រូវបានពន្យារពេលអនុវត្ត | របាយការណ៍លទ្ធផល |
| ១១.២. ........ | ........ | ........ | ........ | ........ | ........ | | ........ | ........ |

*តារាងទី ៧ ៖ ទម្រង់របាយការណ៍អនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| លទ្ធផលគន្លឹះ | សូចនាករ សមិទ្ធកម្មគន្លឹះ | លទ្ធផលគោល | លក្ខខណ្ឌវាយតម្លៃ | គោលដៅប្រចាំឆមាស | គោលដៅប្រចាំឆ្នាំ | ពណ៌ សមិទ្ធកម្ម | វឌ្ឍនភាព | ឯកសារភស្តុតាង |
|---|---|---|---|---|---|---|---|---|
| ១១.១.១: ឯកសារគោល (Blueprint) ស្ដីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | Blueprint និងផែនការសកម្មភាពលម្អិតត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | ឆ្នាំ២០២៤៖ មានសេចក្តីព្រាង | ■ : អនុម័ត និងដាក់ឱ្យអនុវត្ត<br>◆ : បានប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ<br>▲: បានប្រជុំពិភាក្សាកម្រិតបច្ចេកទេស<br>● : មានសេចក្តីព្រាងបឋម ឬគ្មានវឌ្ឍនភាព | **តម ១:** សេចក្ដីព្រាងត្រូវបានប្រជុំពិភាក្សាកម្រិតបច្ចេកទេស<br>**តម ២:** សេចក្ដីព្រាងត្រូវបានប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ<br>**តម ៣:** អនុម័ត និងដាក់ឱ្យអនុវត្ត<br>**តម ៤:** | ឯកសារគោល (Blueprint) ស្ដីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត | ■ | ឯកសារគោលស្ដីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តក្នុងខែមករា | ឯកសារគោល និងផែនការសកម្មភាព |
| ១១.១.២:<br>.......... | .......... | ឆ្នាំ២០២៤៖<br>......... | ■ : (សម្រេចពេញលេញ)<br>◆ : (មានវឌ្ឍនភាពច្រើន)<br>▲: (មានវឌ្ឍនភាពទាប)<br>● : (គ្មានវឌ្ឍនភាព) | **តម ១:**<br>**តម ២:**<br>**តម ៣:**<br>**តម ៤:** | | | ......... | ......... |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

*តារាងទី ៨ ៖ ទម្រង់របាយការណ៍អនុវត្តផែនការសកម្មភាពលម្អិតប្រចាំត្រីមាស/ឆ្នាំ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

| សកម្មភាព | សូចនាករគន្លឹះប្រចាំត្រីមាស | លទ្ធផលគោល | វឌ្ឍនភាព | បញ្ហាប្រឈម | ឯកសារភស្តុតាង |
|---|---|---|---|---|---|
| **ផ្នែកទី ១ ៖ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា** | | | | | |
| **១៤. កែលម្អដំណើការនៃអនុវត្តចំណាយដោយបន្តកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ** | - **ភាគរយផែនការលទ្ធកម្ម ៩៧%**<br>- **ភាគរយរបាយការណ៍លទ្ធកម្ម ៧៥%** | **ឆ្នាំ២០២១៖ ផែនការលទ្ធកម្ម អនុម័តមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា មានចំនួន ៩៥%** | | | |
| ១៤.១. ធ្វើស្វ័យប្រវត្តិកម្មនីតិវិធីនៃការអនុវត្តលទ្ធកម្មសាធារណៈតាមប្រព័ន្ធ FMIS | នីតិវិធីការងារថ្មីស្តីពីការរៀបចំ អនុវត្ត រាយការណ៍ កិច្ចលទ្ធកម្មតាមប្រព័ន្ធត្រូវបានអនុវត្តសាកល្បងនៅកម្រិត កសហវ. | ឆ្នាំ២០២១៖ម៉ូឌុលគ្រប់គ្រងលទ្ធកម្មពេញលេញត្រូវបានអនុវត្តសាកល្បងនៅក្រសួងចំនួន២ | | | |
| ១៤.១.១-១ ដាក់ឱ្យអនុវត្តសាកល្បងនីតិវិធីការងារថ្មីស្តីពីការរៀបចំ អនុវត្ត រាយការណ៍កិច្ចលទ្ធកម្មតាមប្រព័ន្ធ FMIS | នីតិវិធីការងារថ្មីស្តីពីការរៀបចំ អនុវត្ត រាយការណ៍កិច្ចលទ្ធកម្មតាមប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅ កសហវ (សស ១.) | | បានដាក់ឱ្យអនុវត្តសាកល្បងនៅ កសហវ តាមរយៈសារាចរណែនាំលេខ ០២៩ សហវ.ស.ណ.ន.បគហ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ | | សារាចរណែនាំលេខ ០២៩ សហវ.ស.ណ.ន . បគហ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ |
| **ផ្នែកទី ២ ៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ** | | | | | |
| | | | | | |
| **ផ្នែកទី ៣ ៖ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** | | | | | |
| | | | | | |
| **ផ្នែកទី ៤ ៖ ការកសាងគណនេយ្យភាពសមិទ្ធកម្ម** | | | | | |
| | | | | | |
| **ផ្នែកទី ៥ ៖ ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត** | | | | | |
| | | | | | |
| | | | | | |

## ៥.២. ការរៀបចំរបាយការណ៍សមិទ្ធកម្ម

របាយការណ៍សមិទ្ធកម្ម សំដៅដល់របាយការណ៍លទ្ធផលនៃការអនុវត្តផែនការសកម្មភាពដែលផ្តល់នូវព័ត៌មានលម្អិតអំពីវឌ្ឍនភាពនៃធៀបទៅនឹងគោលដៅដែលបានកំណត់ ដោយប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះជាមូលដ្ឋានសម្រាប់វាស់វែងសមិទ្ធកម្មក្នុងពេលវេលាជាក់លាក់ណាមួយ។ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អង្គភាព ឬ ស្ថាប័នអនុវត្តមានភារកិច្ចរៀបចំ និងបូកសរុបរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំតាមទម្រង់នៅក្នុងចំណុច ៥.១. ខាងលើ។ របាយការណ៍ដែលត្រូវផ្តល់ដោយអង្គភាព ឬ ស្ថាប័នអនុវត្ត រួមមាន៖ របាយការណ៍អនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ, របាយការណ៍អនុវត្តផែនការសកម្មភាពលម្អិត, និងរបាយការណ៍សង្ខេបសមិទ្ធកម្ម ដោយភ្ជាប់ជាមួយឯកសារភស្តុតាងពាក់ព័ន្ធ តាមកាលបរិច្ឆេទដូចខាងក្រោម៖

- **របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស៖** យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទីមួយ នៃខែទីមួយ នៃត្រីមាសបន្ទាប់។
- **របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ៖** យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទីមួយ នៃខែទីមួយ នៃឆ្នាំបន្ទាប់។

បន្ទាប់ពីទទួលបានរបាយការណ៍សមិទ្ធកម្មពីអង្គភាព ឬ ស្ថាប័នអនុវត្ត **អ.គ.ហ.** ត្រូវបូកសរុបរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសឱ្យបានរួចរាល់ត្រឹមដំណាច់សប្តាហ៍ទីបី នៃខែទីមួយ នៃត្រីមាសបន្ទាប់ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ត្រឹមសប្តាហ៍ទីបី នៃខែទីមួយ នៃឆ្នាំបន្ទាប់ ដើម្បីដាក់ឆ្លង **គ.ហ.ស.**។ ជាមួយគ្នានេះ របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវផ្ញើជូនប្រមុខរដ្ឋាភិបាល ពិនិត្យ និងផ្តល់ចំណាត់ការបន្ថែមក្នុងករណីចាំបាច់។

## ៥.៣. ការរៀបចំកិច្ចប្រជុំត្រួតពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់

### ក. ការរៀបចំកិច្ចប្រជុំកម្រិតអង្គភាព ឬ ស្ថាប័ន

ក្នុងគោលដៅធានាប្រសិទ្ធភាពនៃការអនុវត្ត អង្គភាព ឬ ស្ថាប័នអនុវត្ត ត្រូវរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស និងឆ្នាំ ក្រោមការដឹកនាំរបស់ប្រធាន **ក.ហ.ស.** ឬ អនុប្រធាន **ក.ហ.ស.** តាមការចាត់តាំង។ ការរៀបចំកិច្ចប្រជុំនេះ គឺក្នុងគោលបំណងតាមដានវឌ្ឍនភាពការងារ, និងកត់សម្គាល់នូវបញ្ហាប្រឈមនានាដែលរាំងស្ទះដល់ការអនុវត្ត ដើម្បីចាត់វិធានការក្នុងការជំរុញការអនុវត្តឱ្យសម្រេចបានតាមផែនការដែលបានគ្រោងទុក។ ជាមួយគ្នានេះ អង្គភាព ឬ ស្ថាប័នអាចអញ្ជើញមន្ត្រីជំនាញទទួលបន្ទុកសម្របសម្រួលការងារ នៃ **អ.គ.ហ.** ចូលរួមកិច្ចប្រជុំ ក្នុងករណីចាំបាច់។

### ខ. ការរៀបចំកិច្ចប្រជុំកម្រិតគោលនយោបាយ

បន្ទាប់ពី **អ.គ.ហ.** បានបូកសរុបរបាយការណ៍សមិទ្ធកម្មរបស់អង្គភាព ឬ ស្ថាប័នរួចរាល់ស្របតាមក្របខ័ណ្ឌពេលវេលាកំណត់ខាងលើ, របាយការណ៍សមិទ្ធកម្មនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំត្រីមាស និងប្រចាំឆ្នាំនេះ ត្រូវដាក់ឆ្លងកិច្ចប្រជុំកម្រិតគោលនយោបាយចំនួនពីរ តាមកាលបរិច្ឆេទដូចខាងក្រោម៖

- **កិច្ចប្រជុំប្រចាំត្រីមាស**
  - កិច្ចប្រជុំ **គ.ក.ហ.** នៅសប្តាហ៍ទីបួន នៃខែទីមួយ នៃត្រីមាសបន្ទាប់
  - កិច្ចប្រជុំ **គ.ហ.ស.** នៅសប្តាហ៍ទីមួយ នៃខែទីពីរ នៃត្រីមាសបន្ទាប់។
- **កិច្ចប្រជុំប្រចាំឆ្នាំ**
  - កិច្ចប្រជុំ **គ.ក.ហ.** នៅសប្តាហ៍ទីបួន នៃខែទីមួយ នៃឆ្នាំបន្ទាប់
  - កិច្ចប្រជុំ **គ.ហ.ស.** នៅសប្តាហ៍ទីមួយ នៃខែទីពីរ នៃឆ្នាំបន្ទាប់។

### គ. កិច្ចប្រជុំ គ.ហ.ស. ជាមួយដៃគូអភិវឌ្ឍ

កិច្ចប្រជុំ **គ.ហ.ស.** ជាមួយតំណាងដៃគូអភិវឌ្ឍ ត្រូវធ្វើឡើងពីរដងក្នុងមួយឆ្នាំ គឺនៅឆមាសទី១ និងប្រចាំឆ្នាំ តាមកាលបរិច្ឆេទខាងក្រោម៖

- កិច្ចប្រជុំប្រចាំឆមាសទី១ នៅសប្តាហ៍ទីបី នៃខែទីពីរ នៃឆមាសបន្ទាប់
- កិច្ចប្រជុំប្រចាំឆ្នាំ នៅសប្តាហ៍ទីបួន នៃខែទីពីរ នៃឆ្នាំបន្ទាប់។

អគ្គលេខាធិការ នៃ **អ.គ.ហ.** ក្នុងនាមជាសេនាធិការ នៃ **គ.ហ.ស.** អាចដឹកនាំកិច្ចប្រជុំប្រចាំឆមាសទី១ រវាង **គ.ហ.ស.** ជាមួយតំណាងដៃគូអភិវឌ្ឍ តាមការប្រគល់សិទ្ធិរបស់ប្រធាន **គ.ហ.ស.**។

ក្នុងករណីចាំបាច់ **គ.ហ.ស.** អាចរាយការណ៍ជូនប្រមុខរដ្ឋាភិបាល តាមរយៈកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ដែលមានការចូលរួមពីសមាជិករាជរដ្ឋាភិបាល សមាជិក **គ.ហ.ស.** តំណាងដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល ព្រមទាំងអង្គភាព ឬ ស្ថាប័នដែលមានការពាក់ព័ន្ធផ្សេងទៀត។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.** អាចកំណត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំណាមួយ តាមការចាំបាច់។

### ឃ. ការកែសម្រួលផែនការសកម្មភាពផ្អែកតាមព័ត៌មានសមិទ្ធកម្ម

ផ្អែកតាមលទ្ធផលនៃការវាយតម្លៃសមិទ្ធកម្មតាមពេលវេលាកំណត់ខាងលើ **គ.ហ.ស.** នៅអង្គភាព ឬ ស្ថាប័ន អាចស្នើកែសម្រួលផែនការសមិទ្ធកម្មនៅក្នុងឆ្នាំអនុវត្ត តាមការចាំបាច់។ ជាមួយគ្នា **គ.ហ.ស.** ត្រូវប្រើប្រាស់ព័ត៌មានសមិទ្ធកម្មដែលទទួលបានពីការត្រួតពិនិត្យនិងវាយតម្លៃនេះ សម្រាប់ជាធាតុចូលក្នុងការរៀបចំផែនការសមិទ្ធកម្មសម្រាប់ការអនុវត្តនៅឆ្នាំបន្ទាប់ ដែលកិច្ចការទាំងអស់នេះត្រូវសហការ និងសម្របសម្រួលដោយ **អ.គ.ហ.**។

*ដ្យាក្រាម ៦ ៖ យន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់*



# ជំពូក ៦. ការលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម

ការលើកទឹកចិត្ត សំដៅដល់ការផ្តល់ប្រាក់ឧបត្ថម្ភជូន **ក.ហ.ស.** នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តទាំងអស់ ដែលបានបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនប្រកបដោយផលិតភាព គុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តជូនអង្គភាព ឬ ស្ថាប័ន ត្រូវផ្អែកលើផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំដែលបានកំណត់ក្នុងដំណាក់កាលរៀបចំផែនការ ដូចមានក្នុងចំណុច ៤.៤.។ ជាមួយគ្នានេះ ការបើកផ្តល់ត្រូវផ្អែកលើលក្ខខណ្ឌចំនួនពីរ គឺលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌសមិទ្ធកម្ម។

## ៦.១. លក្ខខណ្ឌទូទៅ

សម្រាប់ការបំពេញលក្ខខណ្ឌទូទៅ មានន័យថា **ក.ហ.ស.** នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តទាំងអស់ ត្រូវមានលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពលម្អិត ផែនការថវិកា ផែនការលើកទឹកចិត្ត លក្ខខណ្ឌយោងការងារ កិច្ចព្រមព្រៀងសមិទ្ធកម្ម របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងឆ្នាំ ព្រមទាំងបានផ្ញើជូន **អ.គ.ហ.** បានទាន់ពេលវេលា។ សម្រាប់ការបំពេញលក្ខខណ្ឌទូទៅ **ក.ហ.ស.** ត្រូវអនុវត្តដូចតទៅ៖

- កិច្ចព្រមព្រៀងសមិទ្ធកម្ម ភ្ជាប់មកជាមួយនូវលទ្ធផលគន្លឹះក្នុងឆ្នាំ
- ផែនការលើកទឹកចិត្ត និងលក្ខខណ្ឌយោងការងាររបស់ **ក.ហ.ស.** នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- របាយការណ៍សមិទ្ធកម្ម នៃការអនុវត្តផែនការសកម្មភាពលម្អិតប្រចាំត្រីមាស និងប្រចាំឆ្នាំ N-1 ក្នុងនោះ របាយការណ៍ប្រចាំឆ្នាំ N-1 សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី១, របាយការណ៍ប្រចាំត្រីមាសទី១ សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី២, របាយការណ៍ប្រចាំត្រីមាសទី២ សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី៣
- របាយការណ៍បូកសរុបការវាយតម្លៃសមិទ្ធកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំ របស់មន្ត្រីរាជការ បុគ្គលិក ដែលជាសមាសភាព **ក.ហ.ស.** ទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ក្នុងនោះ របាយការណ៍ប្រចាំឆ្នាំ N-1 សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី១, របាយការណ៍ប្រចាំត្រីមាសទី១ សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី២, របាយការណ៍ប្រចាំត្រីមាសទី២ សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី៣។

សម្រាប់ការបំពេញលក្ខខណ្ឌទូទៅនេះ **ក.ហ.ស.** នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តទាំងអស់ ទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ៦០% នៃប្រាក់ឧបត្ថម្ភលើកទឹកចិត្តសរុបប្រចាំឆ្នាំ។ ចំនួន ៦០% នេះត្រូវចែកជា ៣ ចំណែកស្មើគ្នា សម្រាប់បើកផ្តល់ចំនួន ៣ ត្រីមាសដោយស្វ័យប្រវត្តិនៅ **ក.ហ.ស.** បានបំពេញលក្ខខណ្ឌទូទៅ។ ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត សម្រាប់លក្ខខណ្ឌទូទៅនេះ ត្រូវធ្វើឡើងក្នុងសប្តាហ៍ទី១ ក្នុងខែទី១ នៃត្រីមាសបន្ទាប់។

## ៦.២. លក្ខខណ្ឌសមិទ្ធកម្ម

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តមួយចំណែក ត្រូវបើកផ្តល់ដោយផ្អែកលើសមិទ្ធកម្មការងាររបស់ អង្គភាព ឬ ស្ថាប័ន តាមរយៈការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំរបស់អង្គភាព ឬ ស្ថាប័ននីមួយៗ។ ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត សម្រាប់លក្ខខណ្ឌសមិទ្ធកម្ម គឺមានទំហំ ៤០% នៃប្រាក់ឧបត្ថម្ភលើកទឹកចិត្តសរុបប្រចាំឆ្នាំ។ មូលដ្ឋានសម្រាប់ការបើកផ្តល់ គឺត្រូវផ្អែកទាំងស្រុងលើវឌ្ឍនភាពជាក់ស្តែងនៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ នៅតាម **ក.ហ.ស.** នៃអង្គភាព

ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តនីមួយៗ។ ការបើកផ្តល់ ត្រូវផ្អែកតាមនីតិវិធី ដូចខាងក្រោម៖

- **អ.គ.ហ.** ត្រូវរៀបចំវិភាជសមាមាត្រប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៤០% ទៅតាមលទ្ធផលគន្លឹះក្នុងឆ្នាំនីមួយៗ ហើយចែកសមាមាត្រប្រាក់ឧបត្ថម្ភស្មើៗគ្នាទៅតាមសូចនាករសមិទ្ធកម្មគន្លឹះគាំទ្រនីមួយៗ។
- សូចនាករសមិទ្ធកម្មគន្លឹះនីមួយៗគាំទ្រដល់លទ្ធផលគន្លឹះក្នុងឆ្នាំ ត្រូវបានដាក់ពិន្ទុ ១ សម្រាប់វឌ្ឍនភាព ■ (បៃតងចាស់), ពិន្ទុ ០,៧៥ សម្រាប់វឌ្ឍនភាព ◆ (បៃតងខ្ចី), ពិន្ទុ ០,៥ សម្រាប់វឌ្ឍនភាព ▲ (លឿង) និង ០ សម្រាប់វឌ្ឍនភាព ● (ក្រហម) និង
- លទ្ធផលនៃការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំនីមួយៗ ដែលបូកយោងពីពិន្ទុវាយតម្លៃសូចនាករសមិទ្ធកម្មគន្លឹះនីមួយៗ នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការបើកផ្តល់ប្រាក់ឧត្ថម្ភលើកទឹកចិត្ត ប្រចាំត្រីមាសទី៤។

**ឧទាហរណ៍៖ ក.ហ.ស.** នៃអង្គភាពមួយបានគ្រោងលទ្ធផលគន្លឹះក្នុងឆ្នាំចំនួន ៤ ដូចនេះ សម្រាប់ការវិភាជសមាមាត្រប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៤០% ត្រូវអនុវត្តដូចខាងក្រោម៖

- ➢ ប្រាក់ឧបត្ថម្ភ ៤០% ត្រូវវិភាជតាមលទ្ធផលក្នុងឆ្នាំចំនួន ៤។ ដូចនេះ លទ្ធផល ១ សមមាត្រនឹងប្រាក់ឧបត្ថម្ភចំនួន ១០%
- ➢ ករណី លទ្ធផលនោះ មានសូចនាករសមិទ្ធកម្មគន្លឹះតែ១, ដូចនេះ ១០% នេះត្រូវវិភាជលើសូចនាករ ១ នោះតែម្តង
- ➢ ប៉ុន្តែករណី លទ្ធផលក្នុងឆ្នាំ មានសូចនាករចំនួន ២ ឬ ច្រើន, ដូចនេះ ១០% ត្រូវចែកតាមចំនួនសូចនាករទាំងនោះ។

ដើម្បីបើកផ្តល់ប្រាក់ឧបត្ថម្ភទាន់ពេលវេលាសម្រាប់លក្ខខណ្ឌសមិទ្ធកម្ម **ក.ហ.ស.** នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវផ្ញើរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពលម្អិតប្រចាំត្រីមាសទី៣ នៅដំណាច់សប្តាហ៍ទីមួយ នៃខែទីមួយ នៃត្រីមាសទី៤, និងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ ប្រចាំឆ្នាំ ដោយភ្ជាប់មកជាមួយឯកសារយោងឱ្យបានត្រឹមត្រូវ មក **អ.គ.ហ.** យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទីមួយ នៃខែទីមួយ ឆ្នាំបន្ទាប់។ **អ.គ.ហ.** ត្រូវបញ្ចប់ការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំនេះត្រឹមសប្តាហ៍ទីបួន នៃខែទីមួយ នៃឆ្នាំបន្ទាប់ និងបើកផ្តល់យ៉ាងយូរត្រឹមសប្តាហ៍ទីមួយ នៃខែទីពីរ នៃឆ្នាំបន្ទាប់។

ទន្ទឹមនេះ សម្រាប់ **ក.ហ.ស.** ណាដែលសម្រេចបានសមិទ្ធកម្មពេញលេញ ឬ លើស ផែនការ, **គ.ហ.ស.** អាចពិចារណាលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ដោយបន្ថែមកញ្ចប់ថវិកា ឬ កញ្ចប់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ ជូនអង្គភាព ឬ ស្ថាប័ននោះ។ ដោយឡែក ចំពោះ **ក.ហ.ស.** ណាដែលសម្រេច បានសមិទ្ធកម្មត្រឹមពាក់កណ្តាល ឬទាបជាងពាក់កណ្តាល, **គ.ហ.ស.** ក៏អាចពិចារណាកាត់បន្ថយកញ្ចប់ថវិកា និងប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចពិចារណាពិនិត្យលទ្ធភាពកាត់បន្ថយឥណទានថវិកាចរន្តក្នុងក្របខ័ណ្ឌថវិកាជាតិផងដែរ។

# ជំពូក ៧. ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងសមិទ្ធកម្ម

ក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងសមិទ្ធកម្ម ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **គ.ហ.ស.** នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ត្រូវប្រើប្រាស់ "**ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងសមិទ្ធកម្ម** - Performance Management Information System" សម្រាប់ការរៀបចំផែនការ និងការតាមដាននិងវាយតម្លៃសមិទ្ធកម្មនៅតាម **គ.ហ.ស.** សាមីរៀងៗខ្លួន។



## ៧.១. ទិដ្ឋភាពទូទៅ

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងសមិទ្ធកម្ម (PMIS) ត្រូវបានផ្តួចផ្តើមរៀបចំឡើងក្នុងគោលបំណងធានាបាននូវប្រសិទ្ធភាព និងសុក្រឹតភាពនៃការរៀបចំផែនការ ការអនុវត្ត និងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្មការងារក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈថ្នាលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលមានលក្ខណៈជា Online Web-Based Application និង Mobile Application។ ប្រព័ន្ធនេះត្រូវបានចាប់ផ្តើមរៀបចំ និងទទួលបានការអភិវឌ្ឍជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០១៨ ដោយបានឆ្លងកាត់ការពិនិត្យពិភាក្សាយ៉ាងល្អិតល្អន់ ដើម្បីសិក្សាអំពីកិច្ចដំណើរការ នីតិវិធីប្រតិបត្តិការ និងតម្រូវការអ្នកប្រើប្រាស់ផ្ទាល់។ ក្នុងឆ្នាំ២០១៩ ប្រព័ន្ធនេះត្រូវបានដាក់ឱ្យអនុវត្តសាកល្បងផ្ទៃក្នុង **អ.គ.ហ.** ដើម្បីដកស្រង់នូវបទពិសោធន៍ និងកែលម្អរបញ្ហាប្រឈមនានាក្នុងកំឡុងពេលអនុវត្ត។ បន្ទាប់ពីបានឆ្លងកាត់នូវការដកស្រង់បទពិសោធន៍ និងការកែលម្អជាបន្តបន្ទាប់, ប្រព័ន្ធ PMIS ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការផ្ទៃក្នុង **អ.គ.ហ.** នៅឆ្នាំ២០២០ សម្រាប់ការរៀបចំ ការអនុវត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ **អ.គ.ហ.**។ ជាទិសដៅ ប្រព័ន្ធ PMIS គឺត្រូវប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅគ្រប់ អង្គភាព/ស្ថាប័ន ដែលចូលរួមអនុវត្តសកម្មភាពក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ប្រព័ន្ធ PMIS គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលត្រូវបានរៀបចំឡើង ក្នុងគោលបំណង ដូចតទៅ៖**

- ផ្តល់នូវភាពងាយស្រួលដល់អង្គភាព ឬ ស្ថាប័នអនុវត្តក្នុងការគ្រប់គ្រងផែនការ និងសមិទ្ធកម្មការរបស់ខ្លួន
- ភាពទាន់ពេលវេលានៃរៀបចំផែនការ និងការធ្វើផែនការតាមប្រព័ន្ធ

- ធានាប្រសិទ្ធភាព និងសមានគតិភាពនៃការអនុវត្តផែនការ
- ភាពទាន់ពេលវេលានៃការរៀបចំរបាយការណ៍ និងការផ្ញើរបាយការណ៍តាមប្រព័ន្ធ
- សុវត្ថិភាព និងភាពងាយស្រួលនៃការរក្សាទុកទិន្នន័យ និងការបោះពុម្ពឯកសារនានា។

### ៧.២. មុខងារសំខាន់ៗ នៃប្រព័ន្ធ PMIS

ក្នុងប្រព័ន្ធ PMIS ត្រូវបានបែងចែកជាម៉ូឌុលសំខាន់ៗ រួមមាន៖ ការកំណត់សិទ្ធិប្រើប្រាស់, ផ្ទាំងគ្រប់គ្រង, ម៉ូឌុលរៀបចំផែនការ ម៉ូឌុលត្រួតពិនិត្យនិងវាយតម្លៃ និងម៉ូឌុលបោះពុម្ព។ ដែលម៉ូឌុលនីមួយៗ មានសមាសធាតុសំខាន់ៗ ដូចតទៅ៖

#### ❖ ការកំណត់សិទ្ធិប្រើប្រាស់

មុននឹងឈានចូលដល់ការប្រើប្រាស់ប្រព័ន្ធ អ្នកប្រើប្រាស់ទាំងអស់តម្រូវឱ្យវាយបញ្ចូលនូវឈ្មោះគណនី និងលេខសម្ងាត់របស់ខ្លួន បន្ទាប់មកប្រព័ន្ធនឹងតម្រូវឱ្យអ្នកប្រើប្រាស់នោះជ្រើសរើសសិទ្ធិក្នុងការប្រើប្រាស់ប្រព័ន្ធ តាមរយៈម៉ូឌុល "**ការកំណត់សិទ្ធិប្រើប្រាស់**"។ ម៉ូឌុលនេះ អនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចកំណត់សិទ្ធិប្រើប្រាស់របស់ខ្លួនចំនួន ២ រួមមាន៖

(១) ផែនការប្រតិបត្តិ **អ.គ.ហ.**៖ មុខងារនេះ គឺអនុញ្ញាតឱ្យអ្នកប្រើប្រាស់ដែលជាមន្ត្រី ឬ ថ្នាក់ដឹកនាំនៃ **អ.គ.ហ.** មានសិទ្ធិក្នុងការរៀបចំផែនការប្រតិបត្តិ, ការរៀបចំរបាយការណ៍ និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការប្រតិបត្តិរបស់ខ្លួន។ មុខងារនេះ គឺអាចប្រើប្រាស់បានសម្រាប់តែ **អ.គ.ហ.** ប៉ុណ្ណោះ។ ដោយឡែក សម្រាប់អង្គភាព/ស្ថាប័នអនុវត្តដទៃគឺពុំមានមុខងារនេះឡើយ។

(២) កម្មវិធីកែទម្រង់៖ មុខងារនេះ អនុញ្ញាតឱ្យ **អ.គ.ហ.** និង អង្គភាព/ស្ថាប័នអនុវត្ត ដូចតទៅ៖

- **អ.គ.ហ.**៖ ក្នុងនាមជាសេនាធិការឱ្យ **គ.ហ.ស.** ដែលមានតួនាទីភារកិច្ចក្នុងការសហការ និងសម្របសម្រួលជាមួយអង្គភាព/ស្ថាប័ន, **អ.គ.ហ.** មានសិទ្ធិចូលប្រើប្រាស់មុខងារនេះ ដើម្បីបញ្ចូលក្របខ័ណ្ឌផែនការសកម្មភាពរួម សម្រាប់ជាមូលដ្ឋានឱ្យអង្គភាព/ស្ថាប័នរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពលម្អិត និងផែនការថវិការបស់ខ្លួន។ ជាមួយគ្នានេះ **អ.គ.ហ.** ក៏មានសិទ្ធិក្នុងការចូលត្រួតពិនិត្យ និងទាញយកផែនការ និងរបាយការណ៍របស់អង្គភាព/ស្ថាប័នផងដែរ។
- **អង្គភាព/ស្ថាប័នអនុវត្ត៖** មុខងារនេះ គឺអនុញ្ញាតឱ្យអ្នកប្រើប្រាស់ដែលជាអង្គភាព/ស្ថាប័នមានសិទ្ធិក្នុងការរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ, ផែនការសកម្មភាពលម្អិត, ផែនការថវិកា, របាយការណ៍វឌ្ឍនភាព និងការបោះពុម្ពផែនការ, របាយការណ៍ និងឯកសារផ្សេងៗ។

#### ❖ ផ្ទាំងគ្រប់គ្រង

នៅក្នុងម៉ូឌុលនេះ នឹងអនុញ្ញាតឱ្យអង្គភាព/ស្ថាប័ន ចូលពិនិត្យមើលព័ត៌មានសង្ខេបរបស់ខ្លួនអំពីលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាព ផែនការថវិកាប្រចាំឆ្នាំរបស់ខ្លួន។ ជាមួយគ្នានេះ អង្គភាព/ស្ថាប័ន ក៏អាចពិនិត្យមើលអំពីស្ថានភាព និងវឌ្ឍនភាពនៃការអនុវត្តផែនការប្រចាំត្រីមាសដោយសង្ខេបរបស់ខ្លួនផងដែរ តាមរយៈផ្ទាំងព័ត៌មានដែលមានបង្ហាញក្នុងម៉ូឌុលនេះ។

#### ❖ ការរៀបចំផែនការ

មុខងារនេះ គឺប្រើប្រាស់សម្រាប់ការរៀបចំផែនការសកម្មភាពរួម, លទ្ធផលគន្លឹះក្នុងឆ្នាំ, ផែនការសកម្មភាព និងផែនការថវិកា។ ក្នុងដំណាក់កាលនៃការរៀបចំផែនការ, **អ.គ.ហ.** នឹងធ្វើការបញ្ចូលក្របខ័ណ្ឌផែនការសកម្មភាពរួម ដែលរួមមាននូវគោលបំណង និងចង្កោមសកម្មភាពនៃផ្នែកទាំង ៥ បន្ទាប់មកអង្គភាព/ស្ថាប័ន ត្រូវគ្រោងសេចក្ដីព្រាងផែនការទាំង ៣ របស់ខ្លួននៅក្នុងប្រព័ន្ធ។ ជានីតិវិធី អង្គភាព/ស្ថាប័នត្រូវគ្រោងលទ្ធផលគន្លឹះក្នុងឆ្នាំរបស់ខ្លួននៅក្រោម

ចង្កោមសកម្មភាព បន្ទាប់មកត្រូវគ្រោងសកម្មភាពក្រោមលទ្ធផលគន្លឹះក្នុងឆ្នាំ បន្ទាប់មកទៀតត្រូវគ្រោងថវិកានៅក្រោមសកម្មភាព។ ក្នុងករណីមានសកម្មភាពកែទម្រង់ដែលមិនជ្រកក្រោមលទ្ធផលគន្លឹះណាមួយ នោះសកម្មភាពនោះអាចជ្រកក្រោមចង្កោមសកម្មភាពផ្ទាល់តែម្តង។ សេចក្តីព្រាងផែនការទាំង ៣ នេះគឺជាមូលដ្ឋានសម្រាប់ការពិនិត្យពិភាក្សាជាមួយ **អ.គ.ហ.**។ បន្ទាប់ពីបានពិនិត្យនិងព្រមព្រៀងគ្នា នោះអង្គភាព/ស្ថាប័ន ត្រូវទាញផែនការចេញពីប្រព័ន្ធ ដើម្បីបន្តនីតិវិធីចុះហត្ថលេខា និងផ្ញើមក **អ.គ.ហ.** ដើម្បីបូកសរុបស្នើសុំការអនុម័តពី **គ.ហ.ស.**។

### ការត្រួតពិនិត្យនិងវាយតម្លៃ

បន្ទាប់លទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាព ទទួលបានការអនុម័ត និងដាក់ឱ្យអនុវត្ត, អង្គភាព/ស្ថាប័នប្រើប្រាស់ម៉ូឌុលត្រួតពិនិត្យនិងវាយតម្លៃ សម្រាប់រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពរបស់ខ្លួនប្រចាំត្រីមាស និងឆ្នាំ។ ក្រៅអំពីការបញ្ចូលវឌ្ឍនភាពនៅតាមសកម្មភាព និងលទ្ធផលគន្លឹះនីមួយៗ ម៉ូឌុលនេះក៏អនុញ្ញាតឱ្យអង្គភាព/ស្ថាប័ន ធ្វើការភ្ជាប់ឯកសារភស្តុតាងផងដែរ។ បន្ទាប់ពីអង្គភាព/ស្ថាប័នបញ្ចប់ការបញ្ចូលវឌ្ឍនភាពនៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពរបស់ខ្លួន, **អ.គ.ហ.** ត្រូវប្រើប្រាស់របាយការណ៍នេះសម្រាប់ជាមូលដ្ឋានក្នុងការបូកសរុបរបាយការណ៍វឌ្ឍនភាព ដើម្បីគោរពរាយការណ៍ជូន **គ.ហ.ស.** ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

### ការបោះពុម្ព

ក្រោយឯកសារទាំងអស់ត្រូវបានបញ្ចូលក្នុងប្រព័ន្ធដោយជោគជ័យ, នោះអង្គភាព/ស្ថាប័ន អាចទាញយកឯកសារទាំងអស់នោះពីមុខងារបោះពុម្ព។ ឯកសារដែលអាចទាញបាន រួមមាន៖ (១) ផែនការសកម្មភាពរួម, (២) លទ្ធផលគន្លឹះក្នុងឆ្នាំ, (៣) ផែនការសកម្មភាព, (៤) ផែនការថវិកា និង (៥) របាយការណ៍វឌ្ឍនភាព និងឯកសារភស្តុតាង ផ្សេងៗដែលបានភ្ជាប់ជាមួយ។

## ៧.៣. គោលការណ៍ណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធ PMIS

ជាវិធាន និងនីតិវិធីលម្អិតអំពីរបៀបនៃការប្រើប្រាស់ប្រព័ន្ធ តាមមុខងារនីមួយៗ នឹងមានលម្អិតក្នុងគោលការណ៍ណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធ PMIS ព្រមទាំងកម្រងវីដេអូណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធ PMIS។ គោលការណ៍ណែនាំ និងកម្រងវីដេអូនេះ នឹងពន្យល់លម្អិតអំពីរបៀបនៃការប្រើប្រាស់ប្រព័ន្ធ រួមមាន៖

- ការចូលប្រើប្រាស់ប្រព័ន្ធ
- រចនាសម្ព័ន្ធអង្គភាព និងប្រព័ន្ធ
- ប្រតិបត្តិការរបស់ប្រព័ន្ធ
- ការរៀបចំផែនការ
- ការត្រួតពិនិត្យ និងវាយតម្លៃ
- ការបោះពុម្ពឯកសារ
- ការពន្យល់អំពីតួនាទី និងព័ត៌មានដែលមានបង្ហាញក្នុងផ្ទាំងគ្រប់គ្រង។

# ជំពូក ៨. សេចក្តីសន្និដ្ឋាន

ក្នុងគោលដៅធានាបានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ស្របតាមគោលបំណងរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, **អ.គ.ហ.** ដែលជាសេនាធិការជូន **គ.ហ.ស.** បានរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសមិទ្ធកម្ម សម្រាប់ជាឯកសារមគ្គុទេសក៍ក្នុងកិច្ចដំណើរការនៃការរៀបចំ ការអនុវត្ត និង ការត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅលើកកម្ពស់សមិទ្ធកម្មឆ្ពោះទៅរកប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាពខ្ពស់។ គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងសម្រាប់បំពេញបន្ថែម (១) សារាចរស្តីពីការគ្រប់គ្រងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (២) ប្រកាសស្តីពីគោលការណ៍ យន្តការ នីតិវិធី និងការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និង (៣) ប្រកាសស្តីពីគោលការណ៍ យន្តការ នីតិវិធី និងការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្តជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។ ឯកសារនេះ ផ្តល់នូវខ្លឹមសារណែនាំលម្អិតអំពីវិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ និងយន្តការនៃការលើកទឹកចិត្តក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយកំណត់នូវក្របខ័ណ្ឌពេលវេលា និងតួនាទីភារកិច្ចរបស់ **គ.ហ.ស.** នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលគ្របដណ្តប់ដល់អគ្គនាយកដ្ឋាន, អង្គភាព និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រាជធានីខេត្ត ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល។

ជាគោលដៅ, ការដាក់ចេញគោលការណ៍ណែនាំនេះរំពឹងថានឹងអាចកែលម្អគុណភាពនៃការរៀបចំលទ្ធផលគន្លឹះនៃការងារកែទម្រង់របស់អង្គភាពអនុវត្ត ព្រមទាំងពន្លឿនការរៀបចំផែនការសកម្មភាពលម្អិតនិងផែនការថវិកាឱ្យបានទាន់ពេលវេលា ប្រកបដោយគុណភាព សង្គតិភាព និងសិនិទ្ធភាពជាមួយនឹងក្របខ័ណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី៤។ ការណ៍នេះ នឹងរួមចំណែកផ្តល់នូវទិដ្ឋភាពកាន់តែច្បាស់លាស់ថែមទៀតដល់ការតាមដាន និងត្រួតពិនិត្យវឌ្ឍនភាព និងវាយតម្លៃសមិទ្ធកម្ម សម្រាប់ការរាយការណ៍ជាប្រចាំជូន **គ.ហ.ស.** និងប្រមុខរាជរដ្ឋាភិបាល។

គោលការណ៍ណែនាំនេះ នឹងក្លាយជាឧបករណ៍ថ្មីមួយជួយជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលទី៤ នេះ ឱ្យសម្រេចបានដល់កម្ពស់នៃវឌ្ឍនភាពតាមគោលដៅរំពឹងទុក។ ឯកសារគោលការណ៍ណែនាំនេះ ត្រូវបានចាត់ទុកជាឯកសាររស់ដែលអនុញ្ញាតឱ្យមានការកែសម្រួលនាពេលអនាគតតាមការចាំបាច់ ដោយផ្អែកលើធាតុចូលនានានៃវដ្តប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលអាចរួមមាន៖ ការណែនាំ ទម្រង់បែបបទ ឬឧបសម្ព័ន្ធផ្សេងៗ៕

# សន្ទានុក្រម

| | |
|---|---|
| **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** (Public Financial Management) | សំណុំនៃច្បាប់ បទដ្ឋាន ប្រព័ន្ធ និងនីតិវិធី សម្រាប់គ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរួមមាន ការរៀបចំគោលនយោបាយ, ការកៀរគរធនធានហិរញ្ញវត្ថុ, ការវិភាជថវិកា, ការអនុវត្តចំណាយ, ការធ្វើកិច្ចបញ្ជិការ និងការធ្វើសវនកម្ម។ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏រួមបញ្ចូលក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ទ្រព្យទាំងជាទ្រព្យហិរញ្ញវត្ថុ និងទ្រព្យមិនមែនជាហិរញ្ញវត្ថុ។ |
| **ការតម្រឹម** (Alignment) | ការធ្វើឱ្យត្រឹមគ្នារវាងរចនាសម្ព័ន្ធកម្មវិធីនៃស្ថាប័នថ្នាក់ជាតិ និងរចនាសម្ព័ន្ធកម្មវិធីនៃស្ថាប័នថ្នាក់ក្រោមជាតិដែលរួមចំណែកដល់ការសម្រេចបានបំណងគោលនយោបាយជាតិ។ |
| **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** (Budget-Policy Linkage) | ការតម្រង់ការចំណាយរបស់ក្រសួងស្ថាប័ន និងការប្រមូលចំណូលឆ្ពោះទៅរកសម្រេចបាននូវគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ថវិកាកម្មវិធី គឺជាឧបករណ៍ក្នុងការផ្សារភ្ជាប់នេះ។ |
| **ការវាយតម្លៃសមិទ្ធកម្ម** (Performance Evaluation) | សំដៅដល់ការពិនិត្យលទ្ធផលនៃកម្មវិធីមួយធៀបទៅនឹងការរំពឹងទុក ព្រមទាំងប្រសិទ្ធភាពនៃការអនុវត្តការងារក្នុងការសម្រេចគោលបំណង និងប្រសិទ្ធភាពនៃការចំណាយ។ ការវាយតម្លៃសមិទ្ធកម្ម ត្រូវបានរៀបចំឡើងដើម្បីធានាថាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តកម្មវិធីកន្លងមកត្រូវបានប្រើប្រាស់ក្នុងការធ្វើការសម្រេចចិត្ត។ ការវាយតម្លៃនេះគឺជាកត្តាចាំបាច់ណាស់ក្នុងការធានាគណនេយ្យភាពចំពោះលទ្ធផលធៀបនឹងថវិកាដែលបានផ្តល់និងចើម្បីកំណត់កម្រិតចំណុចដៅនៃការអនុវត្ត និងកម្រិតថវិកាដែលអាចមាននាពេលអនាគតដោយប្រើប្រាស់ព័ត៌មានសមិទ្ធកម្មកន្លងមក។ |
| **កិច្ចព្រមព្រៀងសមិទ្ធកម្ម** (Performance Agreement) | គឺជាការព្រមព្រៀងរវាងភាគីពីរ ដែលកំណត់ច្បាស់អំពីកាតព្វកិច្ចរួមរបស់ភាគីទាំងពីរ ហើយកិច្ចព្រមព្រៀងនេះនឹងជួយលើកកម្ពស់គណនេយ្យភាព និងមានចែងច្បាស់ពីការទទួលខុសត្រូវចំពោះសមិទ្ធកម្មរបស់បុគ្គលិក និងអ្នកគ្រប់គ្រង ព្រមទាំងរវាងអ្នកផ្តល់អាណត្តិ និងអ្នកទទួលអាណត្តិ ដែលត្រូវអនុវត្តកិច្ចការនាពេលខាងមុខ។ កិច្ចព្រមព្រៀងសមិទ្ធកម្ម ក៏ជាវិធីសាស្ត្រក្នុងការកំណត់អំពីសេចក្តីរំពឹងទុក និងគណនេយ្យភាពក្នុងការសម្រេចសមិទ្ធកម្មស្របតាមកម្រងស្តង់ដារប្រតិបត្តិឧត្តមភាព ដែលជាទូទៅមានបញ្ជាក់នៅក្នុងផ្នែកសមិទ្ធកម្ម និងការទទួលខុសត្រូវចំពោះលទ្ធផលដែលមិនអាចសម្រេចបាន។ កិច្ចព្រមព្រៀងសមិទ្ធកម្មរួមមាន៖ កិច្ចសន្យាសមិទ្ធកម្ម, កិច្ចសន្យាកម្មវិធី, កិច្ចសន្យាបញ្ជាទិញ, ផែនការអាជីវកម្ម ។ល។ |
| **ក្របខ័ណ្ឌវាយតម្លៃ** (Evaluation Framework) | គឺជាការកំណត់នូវអភិក្រមគ្រប់ជ្រុងជ្រោយរួមមួយសម្រាប់វាយតម្លៃកម្មវិធីមួយ ឬ ច្រើនដែលធ្វើឡើងក្នុងកម្រិតខុសៗគ្នា និងទទួលខុសត្រូវដោយអង្គភាព និងស្ថាប័នផ្សេងគ្នា។ ការវាយតម្លៃនេះ អាចផ្តោតលើនីតិវិធីការងារ ឬបច្ច័យនៃការអនុវត្ត ក៏ដូចជាប្រភពទិន្នន័យ និងរបៀបគ្រប់គ្រង។ |

| | |
|---|---|
| **ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ** (Framework for Public Expenditure and Financial Accountability-PEFA) | វិធីសាស្ត្រនានាសម្រាប់ការវាយតម្លៃការអនុវត្តនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ PEFA ជាមូលដ្ឋានគ្រឹះសម្រាប់ជាខ្នាតវាស់វែងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសមួយ ដោយមានមូលដ្ឋានសំអាងច្បាស់លាស់។ PEFA វាស់វែងកម្រិតវិសាលភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ដំណើរការ និងស្ថាប័ន ចូលរួមចំណែកដល់ការសម្រេចនូវលទ្ធផលចុងក្រោយដែលបានកំណត់ មានដូចជា បូរណភាពនៃការគោរពវិន័យថវិកា, យុទ្ធសាស្ត្រវិភាជន៍ធនធាន និងស័ក្តិសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ។ |
| **គណនេយ្យភាពសមិទ្ធកម្ម** (Performance Accountability) | ជាការទទួលខុសត្រូវចំពោះលទ្ធផលនៃការអនុវត្តដែលបានព្រមព្រៀង ឬ សន្យានៅពេលដែលថវិកាត្រូវបានស្នើសុំនៅចំពោះមុខគណៈរដ្ឋមន្ត្រី ឬស្ថាប័ននីតិបញ្ញត្តិ។ វាក៏អាចជាការទទួលខុសត្រូវរបស់បុគ្គល ក្រុម ឬ អង្គភាពក្នុងការសម្រេចគោលដៅ ការងារ ឬស្តង់ដារដាក់លាក់សម្រាប់អនុវត្ត ដោយរួមមានការទទួលខុសត្រូវចំពោះលទ្ធផលនៃសកម្មភាព ការសម្រេចចិត្ត ឬ ដំណើរការ និងធានាថាការអនុវត្តស្របតាមលទ្ធផលរំពឹងទុកស្តង់ដាររួម ឬ សូចនាករដែលបានកំណត់។ |
| **គណនេយ្យភាពហិរញ្ញវត្ថុ** (Financial Accountability) | ការទទួលខុសត្រូវចំពោះមុខច្បាប់លើការគ្រប់គ្រងថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុ ស្របតាមបទបញ្ញត្តិទាំងឡាយដែលមានជាធរមាន។ ដើម្បីធានាបាននូវគណនេយ្យភាពហិរញ្ញវត្ថុ ចាំបាច់ត្រូវមានការរៀបចំប្រព័ន្ធតាមដាន, ប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ប្រកបដោយសុក្រឹត្យភាព, អាចទុកចិត្តបាន និងទាន់ពេលវេលា។ |
| **បច្ច័យ** (Impacts) | លទ្ធផលចុងក្រោយបំផុតនៃកម្មវិធី ដែលជាមូលដ្ឋានក្នុងការវាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី ឬ គោលនយោបាយ ដែលបានផ្តួចផ្តើមធ្វើឡើងក្នុងបរិការណ៍មួយ។ (ឧ.អត្រាភាពក្រីក្រថយចុះ, អត្រាអ្នកមានការងារធ្វើកើនឡើង)។ |
| **ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម** (Performance Management System) | ការគ្រប់គ្រងដោយមានការកំណត់បេសកកម្ម, គោលដៅ និងលទ្ធផលរំពឹងទុក ហើយអាចវាស់វែង និងផ្ទៀងផ្ទាត់បាន ឬដៅជាសមិទ្ធកម្ម។ ប្រតិបត្តិការទាំងអស់ទាំងថវិកា និងនីតិវិធីផ្សេងៗ ត្រូវផ្អែកទៅលើសមិទ្ធកម្ម។ ហើយរបាយការណ៍លទ្ធផល គឺជាមូលដ្ឋាននៃគណនេយ្យភាពការងារ។ អង្គភាពត្រូវជំរុញឱ្យមានការចូលរួមពីបុគ្គលិក មន្ត្រី ក្រុមការងារ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការសម្រេចបាននូវបេសកកម្ម និងគោលដៅរបស់អង្គភាព។ |
| **ថវិកា** (Budget) | ការប្រកាសជាផ្លូវការ អំពីផែនការគ្រប់គ្រងចំណូល, ចំណាយ, ឱនភាព ឬ អតិរេក និងបំណុលដើម្បីសម្រេចបានលទ្ធផល សមិទ្ធកម្ម និងគោលដៅរបស់រដ្ឋ ក្រសួង ស្ថាប័ន ឬ អង្គភាព។ |
| **លក្ខណៈតក្កកម្ម** (Logical Flow) | គឺជាភាពសមហេតុសមផលនៃទំនាក់ទំនងរវាង ការរៀបចំកម្មវិធី, ការគ្រប់គ្រងកម្មវិធី, លទ្ធផលរំពឹងទុក និងឧបករណ៍សម្រាប់វាយតម្លៃ ដែលបង្ហាញអំពីធាតុសំខាន់ៗនៃកម្មវិធី និងការផ្សាភ្ជាប់ទំនាក់ទំនងនៃធាតុទាំងនេះ ដើម្បីឈានទៅសម្រេចគោលដៅជាក់លាក់មួយ។ ធាតុសំខាន់ៗទាំងនេះរួមមាន៖ ធាតុចូល សកម្មភាព ធាតុចេញ លទ្ធផល បច្ច័យ។ |
| **លទ្ធផលក្នុងឆ្នាំ** (Outputs) | លទ្ធផលបានពីការអនុវត្តសកម្មភាពដែលអាចវាស់បានក្នុងឆ្នាំ ក្រោយពីការអនុវត្តកម្មវិធី អនុកម្មវិធី ឬ ចង្កោមសកម្មភាព។ |
| **លទ្ធផលចុងក្រោយ** (Outcomes) | លទ្ធផលសម្រេចបានពីមួយឆ្នាំទៅមួយឆ្នាំ ក្រោយពីការអនុវត្តបានពេញលេញនូវកម្មវិធី និងកម្មវិធីក្នុងរយៈពេលកំណត់មួយ។ |
| **សមានគតិភាព** (Appropriateness) | ភាពត្រូវគ្នា ឬ ដូចគ្នា ឬ សមហេតុនិងផល (ឧ.ការរៀបចំសកម្មភាព គឺមានសមានគតិភាពនឹងការរៀបចំចង្កោមសកម្មភាព)។ |
| **សេចក្តីសម្រេចប្រតិបត្តិ គ.ហ.ស.** (Executive Order) | គឺជាវិធានការគន្លឹះដែលត្រូវបានដាក់ចេញបន្ថែមដោយ គ.ហ.ស. លើផែនការដែលត្រូវបានអនុម័តរួច សម្រាប់អង្គភាពឬស្ថាប័ន ដែលជា ក.ហ.ស. យកទៅអនុវត្ត ឬសម្រេចឱ្យបាន។ |

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១៖

## សារាចរលេខ១៤ សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពី ការគ្រប់គ្រងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការិយាល័យរដ្ឋបាល ក្រ.សហវ
មកដល់ថ្ងៃទី 24/12/24 ម៉ោង 11h:00
លេខ: 606191 សហវ
អ្នកទទួល: ... ហត្ថលេខា ...
អ្នកប្រគល់: ... ហត្ថលេខា ...
បញ្ជូនទៅ: ...

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៤ សរ

# សារាចរ

## ស្តីពី

## ការគ្រប់គ្រងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅខែធ្នូ ឆ្នាំ២០០៤ ក្នុងគោលបំណងកែប្រែជាជំហានៗ នូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ពីប្រព័ន្ធដែលផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការ ឆ្ពោះទៅប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬលទ្ធផល និងមានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដារ និងឧត្តមានុវត្តន៍អន្តរជាតិ។ កម្មវិធីកែទម្រង់មួយនេះ កំណត់យកយុទ្ធសាស្ត្របោះជំហានតាមអភិក្រមជាខឿន និងតាមការគ្រោងទុក មាន ៤ (បួន) ដំណាក់កាល ដូចខាងក្រោម៖

ដំណាក់កាលទី១ **«ភាពជឿទុកចិត្តបាននៃថវិកា»** អនុវត្តពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨

ដំណាក់កាលទី២ **«គណនេយ្យភាពហិរញ្ញវត្ថុ»** អនុវត្តពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥

ដំណាក់កាលទី៣ **«ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ»** អនុវត្តពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២២

ដំណាក់កាលទី៤ **«គណនេយ្យភាពសមិទ្ធកម្ម»** អនុវត្តពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧។

ដំណាក់កាលនីមួយៗ ត្រូវអនុវត្តក្របខ័ណ្ឌផែនការសកម្មភាពរួម ដែលផ្សំឡើងពីបណ្តាសកម្មភាពចាំបាច់ សម្រាប់ការកសាងមូលដ្ឋានគ្រឹះនៅតាមដំណាក់កាលនីមួយៗ និង សកម្មភាពចាំបាច់នានា ដែលត្រូវចាប់ផ្តើមសាកល្បងដកពិសោធន៍ជាបណ្តើរៗ មុនឈានចូលទៅដល់ដំណាក់កាលបន្ទាប់។ ក្របខ័ណ្ឌផែនការសកម្មភាពរួមនេះ ត្រូវអនុម័ត និងដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល តាមការស្នើសុំរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលហៅកាត់ថា "**គ.ហ.ស.**"។ **គ.ហ.ស.** មានអគ្គលេខាធិការដ្ឋានមួយដែលហៅកាត់ថា "**អ.គ.ហ.**" ជាសេនាធិការ ក្នុងការងារប្រតិបត្តិការប្រចាំថ្ងៃ។

អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ដែលជាអង្គភាព ឬ ស្ថាប័នអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវរៀបចំ និងអនុវត្តផែនការសកម្មភាព ដោយគាំទ្រ និងមានសង្គតិភាពពេញលេញជាមួយក្របខ័ណ្ឌផែនការសកម្មភាពរួម។

គ្រប់អង្គភាព ឬ ស្ថាប័នអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនីមួយៗ ត្រូវរៀបចំបង្កើតក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយដែលហៅកាត់ថា "**ក.ហ.ស.**" នៅក្នុងអង្គភាព ឬ ស្ថាប័នរបស់ខ្លួន។

ដើម្បីពង្រឹងការគ្រប់គ្រងសមិទ្ធកម្ម ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្របទៅនឹងបរិការណ៍នៃការឈានទៅអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម រាជរដ្ឋាភិបាលធ្វើការណែនាំដល់ **គ.ហ.ស.** និងគ្រប់អង្គភាព ឬ ស្ថាប័នអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នូវយន្តការ វិធាន និងនីតិវិធីដូចតទៅ៖

## ក. យន្តការស្ថាប័ន

**ក.ហ.ស.** នៅតាមអង្គភាព ឬ ស្ថាប័ននីមួយៗ ត្រូវមានសមាសភាពដូចខាងក្រោម៖

### ក.១. សមាសភាព ក.ហ.ស. នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

#### ក.១.១. ប្រធាន ក.ហ.ស.

**ក.ហ.ស.** ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ឬ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

#### ក.១.២. អនុប្រធានប្រចាំការ និងអនុប្រធាន ក.ហ.ស.

អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់តាំងឱ្យមានអនុប្រធានប្រចាំការ **ក.ហ.ស.** ១ (មួយ) រូប ដែលជាអគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ឬ អនុប្រធានអង្គភាព។

អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់តាំងអនុប្រធាន ១ (មួយ) ឬ ច្រើនរូប ដែលជាអគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ឬ អនុប្រធានអង្គភាព ក្រៅពីអគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ឬ អនុប្រធានអង្គភាព ដែលត្រូវបានចាត់តាំងជាអនុប្រធានប្រចាំការ។

#### ក.១.៣. សមាជិក ក.ហ.ស.

អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់តាំងឱ្យមានសមាជិក នៃ **ក.ហ.ស.** ដែលជាប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទ។

#### ក.១.៤. លេខាធិការ ក.ហ.ស.

អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់តាំងក្រុមលេខាធិការ ដែលមានចំនួនសមាសភាពតាមការចាំបាច់។ ក្នុងចំណោមក្រុមលេខាធិការ **ក.ហ.ស.** ត្រូវជ្រើសតាំងលេខាធិការ ១ (មួយ) រូប ជាមន្ត្រីបង្គោល ដើម្បីសម្របសម្រួលការងារជាមួយ **អ.គ.ហ.** និងផ្ទៃក្នុងអង្គភាព។

សមាសភាពជាក់ស្តែង នៃ **ក.ហ.ស.** នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ក.២. សមាសភាព ក.ហ.ស. នៅតាមមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត

#### ក.២.១. ប្រធាន ក.ហ.ស.

**ក.ហ.ស.** ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត។

#### ក.២.២. អនុប្រធាន ក.ហ.ស.

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវចាត់តាំងឱ្យមានអនុប្រធាន **ក.ហ.ស.** ១ (មួយ) រូប ដែលជាអនុប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ដែលទទួលបន្ទុកការងារហិរញ្ញវត្ថុ ឬ ដែលបំពេញការងារផ្ទាល់ជាមួយប្រធាន **ក.ហ.ស.**។



9

**ក.២.៣. សមាជិក គ.ហ.ស.**

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវចាត់តាំងឱ្យមានសមាជិក នៃ **គ.ហ.ស.** ដែលជាអនុប្រធានមន្ទីរ ក្រៅពីអនុប្រធានមន្ទីរដែលត្រូវបានចាត់តាំងជាអនុប្រធាន **គ.ហ.ស.**។

**ក.២.៤. លេខាធិការ គ.ហ.ស.**

មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវចាត់តាំងឱ្យមានលេខាធិការ ១ (មួយ) រូប ជាមន្ត្រីបង្គោល ដើម្បីសម្របសម្រួលការងារជាមួយ **អ.គ.ហ.** និងផ្នែកក្នុងមន្ទីរសាមី។

សមាសភាពជាក់ស្តែង នៃ **គ.ហ.ស.** នៅតាមមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ក.៣. សមាសភាព គ.ហ.ស. នៅតាមក្រសួង-ស្ថាប័ន**

**ក.៣.១. ប្រធាន គ.ហ.ស.**

**គ.ហ.ស.** ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់តំណាងក្រសួង-ស្ថាប័ន ១ (មួយ) រូប ជាសមាជិក **គ.ហ.ស.** ដែលជារដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬ ថ្នាក់ដឹកនាំ ដែលទទួលបន្ទុកជួយរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័នផ្ទាល់លើការងារហិរញ្ញវត្ថុរបស់ក្រសួង-ស្ថាប័នសាមី។

**ក.៣.២. អនុប្រធានប្រចាំការ និងអនុប្រធាន គ.ហ.ស.**

ក្រសួង-ស្ថាប័ន ត្រូវចាត់តាំងឱ្យមានអនុប្រធានប្រចាំការ **គ.ហ.ស.** ១ (មួយ) រូប ដែលជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គនាយកទទួលបន្ទុកហិរញ្ញវត្ថុ ឬ ថ្នាក់ដឹកនាំ ដែលបំពេញការងារផ្ទាល់ជាមួយប្រធាន **គ.ហ.ស.**។

ក្រសួង-ស្ថាប័ន អាចចាត់តាំងឱ្យមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ ឬ អគ្គនាយកទទួលបន្ទុកការងារពាក់ព័ន្ធ ក្រៅពីរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ ឬ ថ្នាក់ដឹកនាំ ដែលត្រូវបានចាត់តាំងជាអនុប្រធានប្រចាំការ។

**ក.៣.៣. សមាជិក គ.ហ.ស.**

ក្រសួង-ស្ថាប័ន ត្រូវចាត់តាំងសមាជិក នៃ **គ.ហ.ស.** ដែលមានសមាសភាពជាតំណាង ១ (មួយ) រូប នៃគ្រប់អគ្គនាយកដ្ឋាន ឬ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមឱវាទក្រសួង-ស្ថាប័នផ្ទាល់ និងតំណាង ១ (មួយ) រូប នៃគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួង-ស្ថាប័នសាមី។

**ក.៣.៤. លេខាធិការ គ.ហ.ស.**

ក្រសួង-ស្ថាប័ន ត្រូវចាត់តាំងក្រុមលេខាធិការ **គ.ហ.ស.** ដែលមានចំនួនសមាសភាពតាមការចាំបាច់។ ក្នុងចំណោមក្រុមលេខាធិការ **គ.ហ.ស.** ត្រូវជ្រើសតាំងលេខាធិការ ១ (មួយ) រូប ជាមន្ត្រីបង្គោល ដើម្បីសម្របសម្រួលការងារជាមួយ **អ.គ.ហ.** និង ផ្នែកក្នុងក្រសួង-ស្ថាប័នសាមី។

សមាសភាពជាក់ស្តែង នៃ **គ.ហ.ស.** នៅតាមក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័ន។

**ក.៤. សមាសភាព ក.ហ.ស. នៅតាមរដ្ឋបាលរាជធានី-ខេត្ត**

**ក.៤.១. ប្រធាន ក.ហ.ស.**

**ក.ហ.ស.** ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត ដែលជាសមាជិក **គ.ហ.ស.**។

**ក.៤.២. អនុប្រធានប្រចាំការ និងអនុប្រធាន ក.ហ.ស.**

រដ្ឋបាលរាជធានី-ខេត្ត ត្រូវចាត់តាំងឱ្យមានអនុប្រធានប្រចាំការ **ក.ហ.ស.** ១ (មួយ) រូប ដែលជាអភិបាលរង នៃគណៈអភិបាលរាជធានី-ខេត្ត ដែលទទួលបន្ទុកហិរញ្ញវត្ថុ ឬ ដែលបំពេញការងារផ្ទាល់ជាមួយប្រធាន **ក.ហ.ស.**។

រដ្ឋបាលរាជធានី-ខេត្ត អាចចាត់តាំងឱ្យមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលជាអភិបាលរង នៃគណៈអភិបាលរាជធានី-ខេត្ត ក្រៅពីអភិបាលរង ដែលត្រូវបានចាត់តាំងជាអនុប្រធានប្រចាំការ។

**ក.៤.៣. សមាជិក ក.ហ.ស.**

រដ្ឋបាលរាជធានី-ខេត្ត ត្រូវចាត់តាំងសមាជិក នៃ **ក.ហ.ស.** ដែលជានាយករដ្ឋបាល និងនាយកទីចាត់ការ នៃសាលារាជធានី-ខេត្ត។

**ក.៤.៤. លេខាធិការ ក.ហ.ស.**

រដ្ឋបាលរាជធានី-ខេត្ត ត្រូវចាត់តាំងក្រុមលេខាធិការ **ក.ហ.ស.** ដែលមានចំនួនសមាសភាពតាមការចាំបាច់។ ក្នុងចំណោមក្រុមលេខាធិការ **ក.ហ.ស.** ត្រូវជ្រើសតាំងលេខាធិការ ១ (មួយ) រូប ជាមន្ត្រីបង្គោល ដើម្បីសម្របសម្រួលការងារជាមួយ **អ.គ.ហ.** និង ផ្នែកក្នុងរដ្ឋបាលរាជធានី-ខេត្តសាមី។

សមាសភាពជាក់ស្តែង នៃ **ក.ហ.ស.** នៅតាមរដ្ឋបាលរាជធានី-ខេត្តនីមួយៗ ត្រូវកំណត់ដោយសេចក្ដី-សម្រេចរបស់អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត។

**ខ. វិធាន និងនីតិវិធី នៃការរៀបចំផែនការ**

ឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងការរៀបចំផែនការ រួមមាន៖ ផែនការសកម្មភាពរួម លទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិតប្រចាំឆ្នាំ ផែនការថវិកានិងផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ និងកិច្ចព្រមព្រៀងសមិទ្ធកម្ម។

**ខ.១. ផែនការសកម្មភាពរួម**

ក្នុងនាម **គ.ហ.ស.** **អ.គ.ហ.** ត្រូវសម្របសម្រួលរៀបចំផែនការសកម្មភាពរួម នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីដាក់ឆ្លងប្រមុខរដ្ឋាភិបាល អនុម័តនិងដាក់ឱ្យអនុវត្ត។ ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃផែនការសកម្មភាពរួមសម្រាប់អនុវត្តប្រចាំឆ្នាំ **អ.គ.ហ.** ត្រូវកំណត់លក្ខខណ្ឌវាយតម្លៃជាពណ៌ ដើម្បីវាស់វែងអំពីកម្រិតវឌ្ឍនភាពនៃការសម្រេចបាននូវគោលដៅសូចនាករសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំនីមួយៗ។

**អ.គ.ហ.** ត្រូវពិនិត្យ និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពរួម តាមការចាំបាច់ នៅក្នុងអំឡុងពេលអនុវត្ត ហើយដាក់ឆ្លង **គ.ហ.ស.** អនុម័ត និងដាក់ឱ្យអនុវត្ត។ នៅរៀងរាល់ពាក់កណ្ដាលអាណត្តិ និងចុងអាណត្តិ នៃដំណាក់កាលអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវវាយតម្លៃផែនការសកម្មភាពរួម ដើម្បីពិនិត្យលទ្ធភាពឈានទៅអនុវត្តដំណាក់កាលមួយទៀត ឬ ចាំបាច់ត្រូវបន្តពន្យារពេលបន្ថែម ឬ ត្រូវទៅអនុវត្តតាមអភិក្រមថ្មី។

## ២.២. លទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិតប្រចាំឆ្នាំ

ដោយផ្អែកលើផែនការសកម្មភាពរួម **អ.គ.ហ.** ត្រូវរៀបចំក្របខ័ណ្ឌលទ្ធផលគន្លឹះរួម សម្រាប់ជាមូលដ្ឋានជូនអង្គភាព ឬ ស្ថាប័ន រៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ និងផែនការសកម្មភាពលម្អិតប្រចាំឆ្នាំរបស់ខ្លួន។ ក្របខ័ណ្ឌលទ្ធផលគន្លឹះរួមនេះ ត្រូវដាក់ជូនប្រធាន **គ.ហ.ស.** ពិនិត្យ និងអនុម័ត។

ដោយអនុលោមតាមក្របខ័ណ្ឌលទ្ធផលគន្លឹះរួម អង្គភាព ឬ ស្ថាប័ននីមួយៗ ត្រូវរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ ដែលត្រូវគាំទ្រដោយសូចនាករសមិទ្ធកម្មគន្លឹះមួយចំនួន តាមការចាំបាច់។

ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃសម្រាប់ជាកម្មវត្ថុនៃការលើកទឹកចិត្ត សូចនាករសមិទ្ធកម្មគន្លឹះនីមួយៗ ត្រូវកំណត់គោលដៅប្រចាំឆ្នាំឱ្យបានច្បាស់លាស់ ហើយត្រូវកំណត់លក្ខខណ្ឌវាយតម្លៃជាពណ៌សម្រាប់វាស់វែងអំពីកម្រិតវឌ្ឍនភាព នៃការសម្រេចបាននូវគោលដៅសូចនាករសមិទ្ធកម្មគន្លឹះទាំងនោះ។

លទ្ធផលគន្លឹះក្នុងឆ្នាំ ត្រូវមានការពិគ្រោះយោបល់ជាមួយ **អ.គ.ហ.** និងចុះហត្ថលេខាដោយប្រធាន **គ.ហ.ស.** ប្រចាំអង្គភាព ឬ ស្ថាប័ននីមួយៗ និងត្រូវចម្លងជូន **អ.គ.ហ.**។

ផ្អែកលើលទ្ធផលគន្លឹះក្នុងឆ្នាំ អង្គភាព ឬ ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការសកម្មភាពលម្អិតប្រចាំឆ្នាំរបស់ខ្លួន ដោយត្រូវកំណត់គោលដៅប្រចាំត្រីមាសនីមួយៗឱ្យបានច្បាស់លាស់។ ផែនការសកម្មភាពលម្អិត ត្រូវមានការពិគ្រោះយោបល់ជាមួយ **អ.គ.ហ.** និងចុះហត្ថលេខាដោយប្រធាន **គ.ហ.ស.** ប្រចាំអង្គភាព ឬ ស្ថាប័ននីមួយៗ និងត្រូវចម្លងជូន **អ.គ.ហ.**។

## ២.៣. ផែនការថវិកា និងផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ

### ២.៣.១. ផែនការថវិកាប្រចាំឆ្នាំ

**គ.ហ.ស.** ត្រូវកំណត់ពិតានថវិកាសម្រាប់អង្គភាព ឬ ស្ថាប័ននីមួយៗ ដោយផ្អែកលើលទ្ធភាពនៃថវិកាក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

អង្គភាព ឬ ស្ថាប័ននីមួយៗ ត្រូវរៀបចំវិភាជថវិកាគាំទ្រដល់លទ្ធផលគន្លឹះក្នុងឆ្នាំ ដោយមានការពិគ្រោះយោបល់ពី **អ.គ.ហ.** អនុលោមតាមពិតានកំណត់ដោយ **គ.ហ.ស.**។ **អ.គ.ហ.** ត្រូវបញ្ចប់ការចរចាថវិកា ដើម្បីដាក់ឆ្លងប្រធាន **គ.ហ.ស.** អនុម័ត និងដាក់ឱ្យអនុវត្ត នៅដំណាច់ឆ្នាំ មុនឆ្នាំអនុវត្ត។

### ២.៣.២. ផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ ត្រូវបានផ្តល់ជូន **គ.ហ.ស.** នៃ អង្គភាព ឬ ស្ថាប័ន ដែលបានបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនប្រកបដោយផលិតភាព គុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**គ.ហ.ស.** ត្រូវកំណត់ពិតានប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ សម្រាប់អង្គភាព ឬ ស្ថាប័ននីមួយៗ ដោយផ្អែកលើលទ្ធភាព នៃថវិកាក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

អង្គភាព ឬ ស្ថាប័ន ត្រូវផ្ញើសមាសភាពទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ ស្របតាមពិតានកំណត់ដោយ **គ.ហ.ស.** មក **អ.គ.ហ.** ឱ្យបានទាន់ពេលវេលា។ ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំសម្រាប់សមាសភាពនីមួយៗ ត្រូវផ្សារភ្ជាប់ឱ្យបានពេញលេញជាមួយលទ្ធផលគន្លឹះក្នុងឆ្នាំ ឬ សូចនាករសមិទ្ធកម្មគន្លឹះ របស់អង្គភាព ឬ ស្ថាប័ន។

**អ.គ.ហ.** ត្រូវបូកសរុបផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំពីគ្រប់អង្គភាព ឬ ស្ថាប័ន និងសមាសភាពទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំពីគ្រប់អង្គភាព ឬ ស្ថាប័ន ដើម្បីដាក់ឆ្លងប្រធាន **គ.ហ.ស.** អនុម័តនៅត្រឹមដំណាច់ឆ្នាំ មុនឆ្នាំអនុវត្ត។



9

### ខ.៤. កិច្ចព្រមព្រៀងសមិទ្ធកម្ម

បន្ទាប់ពីបញ្ចប់ការរៀបចំលទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការសកម្មភាពលម្អិត ផែនការថវិកា និងផែនការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ **អ.គ.ហ.** និង អង្គភាព ឬ ស្ថាប័ននីមួយៗ ត្រូវរៀបចំចុះកិច្ចព្រមព្រៀងសមិទ្ធកម្ម ឱ្យបានរួចរាល់យ៉ាងយូរត្រឹមដំណាច់ខែធ្នូ មុនឆ្នាំអនុវត្ត ដើម្បីជានានូវគណនេយ្យភាពចំពោះទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពសមិទ្ធកម្ម។ កិច្ចព្រមព្រៀងសមិទ្ធកម្ម ត្រូវប្រើប្រាស់លទ្ធផលគន្លឹះក្នុងឆ្នាំ ផែនការថវិកា និងផែនការប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំរបស់អង្គភាព ឬ ស្ថាប័ននីមួយៗ ជាឧបសម្ព័ន្ធ។

កិច្ចព្រមព្រៀងសមិទ្ធកម្មរវាង **អ.គ.ហ.** និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ឬ រដ្ឋបាលរាជធានី-ខេត្ត ត្រូវចុះហត្ថលេខា ដោយអគ្គលេខាធិការរង នៃ **អ.គ.ហ.** ក្នុងនាមជាប្រតិបត្តិករផ្តល់ហិរញ្ញវត្ថុ និង ប្រធាន **ក.ហ.ស.** ប្រចាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ ប្រធាន **ក.ហ.ស.** ប្រចាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ឬ ប្រធាន **ក.ហ.ស.** ប្រចាំរដ្ឋបាលរាជធានី-ខេត្ត ក្នុងនាមជាអង្គភាព ឬ ស្ថាប័នអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ អគ្គលេខាធិការ នៃ **អ.គ.ហ.** ត្រូវចុះហត្ថលេខា ផ្តល់ការឯកភាព ក្នុងនាមជាសេនាធិការនៃ **គ.ហ.ស.**។

កិច្ចព្រមព្រៀងសមិទ្ធកម្មរវាង **អ.គ.ហ.** និងក្រសួង-ស្ថាប័ន ត្រូវចុះហត្ថលេខាដោយអគ្គលេខាធិការ នៃ **អ.គ.ហ.** ក្នុងនាមជាប្រតិបត្តិករផ្តល់ហិរញ្ញវត្ថុ និងប្រធាន **ក.ហ.ស.** ប្រចាំក្រសួង-ស្ថាប័ន ក្នុងនាមជាអង្គភាព ឬ ស្ថាប័នអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងករណីប្រធាន **ក.ហ.ស.** ជារដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័ន អនុប្រធាន **ក.ហ.ស.** ត្រូវចុះហត្ថលេខាជំនួសប្រធាន **ក.ហ.ស.**។ ប្រធាន **គ.ហ.ស.** និង រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័នសាមី ត្រូវចុះហត្ថលេខាផ្តល់ការឯកភាព។

**អ.គ.ហ.** ត្រូវបូកសរុបកិច្ចព្រមព្រៀងសមិទ្ធកម្ម ពីគ្រប់អង្គភាព ឬ ស្ថាប័ន ដាក់ជូនប្រធាន **គ.ហ.ស.** ឯកភាព និងដាក់ឱ្យអនុវត្តយ៉ាងយូរនៅក្នុងខែមករា នៃឆ្នាំអនុវត្ត។

## គ. វិធាន និងនីតិវិធី នៃការតាមដាន និងវាយតម្លៃ

### គ.១. ការរៀបចំរបាយការណ៍សមិទ្ធកម្ម

អង្គភាព ឬ ស្ថាប័ន ត្រូវរៀបចំ និងបូកសរុបរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ទី២ ទី៣ និងប្រចាំឆ្នាំ តាមទម្រង់ដែលកំណត់ដោយ **អ.គ.ហ.** ហើយផ្ញើមក **អ.គ.ហ.** ដោយភ្ជាប់មកជាមួយឯកសារយោងពាក់ព័ន្ធ តាមកាលបរិច្ឆេទ ដូចខាងក្រោម៖

- របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស៖ យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទី១ នៃខែទី១ នៃត្រីមាសបន្ទាប់
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ៖ យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទី១ នៃខែទី១ នៃឆ្នាំបន្ទាប់។

របាយការណ៍សមិទ្ធកម្ម ដែលត្រូវផ្ញើមក **អ.គ.ហ.** ក្រោយកាលបរិច្ឆេទខាងលើ ជាកម្មវត្ថុនៃការកត់សម្គាល់ថាមានភាពយឺតយ៉ាវ និងត្រូវរាយការណ៍ជូន **គ.ហ.ស.**។

**អ.គ.ហ.** ត្រូវរៀបចំ និងបូកសរុបរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសឱ្យបានរួចរាល់ត្រឹមដំណាច់សប្តាហ៍ទី៣ នៃខែទី១ នៃត្រីមាសបន្ទាប់ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ត្រឹមសប្តាហ៍ទី៣ នៃខែទី១ នៃឆ្នាំបន្ទាប់ ដើម្បីដាក់ឆ្លង **គ.ហ.ស.**។



9

របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវផ្ញើជូនប្រមុខរដ្ឋាភិបាល ពិនិត្យនិងផ្តល់ចំណាត់ការបន្ថែមក្នុងករណីចាំបាច់។

### គ.២. ការរៀបចំកិច្ចប្រជុំតាមដាននិងវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់

#### គ.២.១. ការរៀបចំកិច្ចប្រជុំកម្រិតអង្គភាព ឬ ស្ថាប័ន

អង្គភាព ឬ ស្ថាប័ន ត្រូវរៀបចំឱ្យមានកិច្ចប្រជុំប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ក្រោមការដឹកនាំរបស់ប្រធាន **ក.ហ.ស**. ឬ អនុប្រធាន តាមការចាត់តាំង ដើម្បីតាមដានវឌ្ឍនភាពការងារ និងចាត់វិធានការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនានា។ អង្គភាព ឬ ស្ថាប័ន អាចអញ្ជើញមន្ត្រីជំនាញទទួលបន្ទុកសម្របសម្រួលការងារ នៃ **អ.គ.ហ**. ចូលរួមកិច្ចប្រជុំ ក្នុងករណីចាំបាច់។

#### គ.២.២. ការរៀបចំកិច្ចប្រជុំកម្រិតគោលនយោបាយ

របាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ត្រូវឆ្លងកិច្ចប្រជុំកម្រិតគោលនយោបាយចំនួន២ (ពីរ) តាមកាលបរិច្ឆេទដូចខាងក្រោម៖

- **របាយការណ៍ប្រចាំត្រីមាស**
  - កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ក.ហ**.) នៅសប្តាហ៍ទី៤ នៃខែទី១ នៃត្រីមាសបន្ទាប់
  - កិច្ចប្រជុំ **គ.ហ.ស**. នៅសប្តាហ៍ទី១ នៃខែទី២ នៃត្រីមាសបន្ទាប់។
- **របាយការណ៍ប្រចាំឆ្នាំ**
  - កិច្ចប្រជុំ **គ.ក.ហ**. នៅសប្តាហ៍ទី៤ នៃខែទី១ នៃឆ្នាំបន្ទាប់
  - កិច្ចប្រជុំ **គ.ហ.ស**. នៅសប្តាហ៍ទី១ នៃខែទី២ នៃឆ្នាំបន្ទាប់។

#### គ.២.៣. កិច្ចប្រជុំ គ.ហ.ស. ជាមួយតំណាងដៃគូអភិវឌ្ឍ

កិច្ចប្រជុំ **គ.ហ.ស**. ជាមួយតំណាងដៃគូអភិវឌ្ឍ ត្រូវធ្វើឡើង ២ (ពីរ)ដង ក្នុងមួយឆ្នាំ គឺនៅឆមាសទី១ និងប្រចាំឆ្នាំ តាមកាលបរិច្ឆេទខាងក្រោម៖

- កិច្ចប្រជុំប្រចាំឆមាសទី១ នៅសប្តាហ៍ទី៣ នៃខែទី២ នៃឆមាសបន្ទាប់
- កិច្ចប្រជុំប្រចាំឆ្នាំ នៅសប្តាហ៍ទី៤ នៃខែទី២ នៃឆ្នាំបន្ទាប់។

អគ្គលេខាធិការ នៃ **អ.គ.ហ**. ក្នុងនាមជាសេនាធិការ នៃ **គ.ហ.ស**. អាចដឹកនាំកិច្ចប្រជុំប្រចាំឆមាសទី១ រវាង **គ.ហ.ស**. ជាមួយតំណាងដៃគូអភិវឌ្ឍ តាមការប្រគល់សិទ្ធិរបស់ប្រធាន **គ.ហ.ស**.។

ក្នុងករណីចាំបាច់ **គ.ហ.ស**. អាចរាយការណ៍ជូនប្រមុខរដ្ឋាភិបាល តាមរយៈកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ដែលមានការចូលរួមពីសមាជិករាជរដ្ឋាភិបាល សមាជិក **គ.ហ.ស**. តំណាងដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល ព្រមទាំងអង្គភាព ឬ ស្ថាប័នដែលមានការពាក់ព័ន្ធផ្សេងទៀត។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស**. អាចកំណត់កាលបរិច្ឆេទសម្រាប់កិច្ចប្រជុំណាមួយ តាមការចាំបាច់។

### គ.៣. ការវាយតម្លៃសមិទ្ធកម្ម

ការវាយតម្លៃសមិទ្ធកម្មត្រូវធ្វើឡើងប្រចាំឆ្នាំ និងមាន ២ (ពីរ) កម្រិត គឺកម្រិតផែនការសកម្មភាពរួម សម្រាប់វាយតម្លៃវឌ្ឍនភាពរួម នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្រិតវឌ្ឍនភាពការងាររបស់អង្គភាព ឬ ស្ថាប័ន។

### គ.៣.១. ផែនការសកម្មភាពរួម

ការវាយតម្លៃផែនការសកម្មភាពរួមប្រចាំឆ្នាំ ត្រូវផ្អែកលើវឌ្ឍនភាពនៃការអនុវត្តគោលដៅ សូចនាករសមិទ្ធកម្មគន្លឹះ ដែលបានកំណត់នៅក្នុងផែនការសកម្មភាពរួម ហើយប្រើប្រាស់លក្ខខណ្ឌវាយតម្លៃជាពណ៌ ដែលត្រូវបានកំណត់រួចរាល់ នៅក្នុងដំណាក់កាលរៀបចំផែនការ។ ដើម្បីជាព័ត៌មានវិភាគបន្ថែម **អ.គ.ហ.** អាចផ្តួចផ្តើមសិក្សាស្រាវជ្រាវលើប្រធានបទនានាពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### គ.៣.២. វឌ្ឍនភាពការងាររបស់អង្គភាព ឬស្ថាប័ន

ការវាយតម្លៃវឌ្ឍនភាពការងាររបស់អង្គភាព ឬ ស្ថាប័ន ត្រូវផ្អែកលើវឌ្ឍនភាព នៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំរបស់អង្គភាព ឬ ស្ថាប័ននីមួយៗ ហើយផ្អែកលើលក្ខខណ្ឌវាយតម្លៃជាពណ៌ ដែលត្រូវបានកំណត់រួចរាល់ នៅក្នុងដំណាក់កាលរៀបចំផែនការ។ លទ្ធផលនៃការវាយតម្លៃ គឺជាមូលដ្ឋានដ៏ចាំបាច់សម្រាប់ការលើកទឹកចិត្ត។

## ឃ. វិធានការលើកទឹកចិត្ត

ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តជូនអង្គភាព ឬ ស្ថាប័ន ត្រូវផ្អែកលើលក្ខខណ្ឌចំនួន ២ (ពីរ) គឺលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌសមិទ្ធកម្ម។

### ឃ.១. លក្ខខណ្ឌទូទៅ

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តមួយចំណែក ត្រូវបើកផ្តល់ជូនអង្គភាព ឬ ស្ថាប័ន សម្រាប់ ៣ (បី) ត្រីមាស ដោយចែកសមាមាត្រស្មើៗគ្នាសម្រាប់ត្រីមាសនីមួយៗ។ ការបើកផ្តល់ គឺផ្អែកត្រឹមតែតម្រូវការឯកសារមួយចំនួន ប៉ុណ្ណោះ។

### ឃ.២. លក្ខខណ្ឌសមិទ្ធកម្ម

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តមួយចំណែក ត្រូវបើកផ្តល់ដោយផ្អែកលើសមិទ្ធកម្មការងាររបស់អង្គភាព ឬ ស្ថាប័ន តាមរយៈការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំរបស់អង្គភាព ឬ ស្ថាប័ននីមួយៗ។

**គ.ហ.ស.** ត្រូវពិចារណាលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ដោយបន្ថែមកញ្ចប់ថវិកា ឬ កញ្ចប់ប្រាក់-ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ ជូនអង្គភាព ឬ ស្ថាប័នណាដែលសម្រេចបានសមិទ្ធកម្មពេញលេញ ឬ លើសផែនការ។

**គ.ហ.ស.** អាចពិចារណាកាត់បន្ថយកញ្ចប់ថវិកា និងប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចពិចារណាពិនិត្យលទ្ធភាពកាត់បន្ថយឥណទានថវិកាចរន្តក្នុងក្របខ័ណ្ឌថវិកាជាតិ ចំពោះអង្គភាព ឬ ស្ថាប័នដែលសម្រេចបានសមិទ្ធកម្មត្រឹមពាក់កណ្តាល ឬ ទាបជាងពាក់កណ្តាល។

គោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។

## ង. ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

**អ.គ.ហ.** អង្គភាព ឬ ស្ថាប័ន ត្រូវប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងសមិទ្ធកម្ម ដែលអភិវឌ្ឍដោយ **អ.គ.ហ.** ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំផែនការ និង ការតាមដាននិងវាយតម្លៃ ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ច. ការរៀបចំគោលការណ៍ណែនាំលម្អិត

**អ.គ.ហ.** ត្រូវរៀបចំគោលការណ៍ណែនាំលម្អិត ស្តីពីការគ្រប់គ្រងសមិទ្ធកម្ម ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.** អនុម័តនិងដាក់ឱ្យអនុវត្ត ដើម្បីពង្រឹងប្រសិទ្ធភាព នៃការអនុវត្តសារាចរនេះ។

ទទួលបានសារាចរនេះ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គ្រប់ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត ពាក់ព័ន្ធការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង-ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ២៖

# លក្ខខណ្ឌយោងការងារ

# លក្ខខណ្ឌយោង

តួនាទី៖ រៀបចំប្រព័ន្ធស្តង់ដាថ្លៃ

ទីកន្លែងបម្រើការងារ៖ នាយកដ្ឋានប្រសិទ្ធភាពចំណាយ នៃអគ្គនាយកដ្ឋានគោលនយោបាយ

**សាវតារ**

ការរៀបចំប្រព័ន្ធស្តង់ដាថ្លៃ គឺជាគោលបំណងស្នូលមួយ នៃគោលបំណងទាំង ៣ នៃការងារកែទម្រង់កិច្ច-ដំណើរការលទ្ធកម្មសាធារណៈ ក្នុងគោលដៅធ្វើឱ្យប្រព័ន្ធលទ្ធកម្មសាធារណៈ ក្លាយជាប្រព័ន្ធមួយកាន់តែមានភាពជឿទុកចិត្ត ប្រសិទ្ធភាព ការប្រកួតប្រជែង និងការសន្សំសំចៃ ព្រមទាំងស្របតាមឧត្តមានុវត្តន៍អន្តរជាតិ ។ បញ្ជីស្តង់ដាថ្លៃទំនិញ និងសេវា ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានមុខទំនិញ និងសេវា ដែលមានការប្រើប្រាស់ជាប្រចាំ និងញឹកញាប់តាមក្រសួង-ស្ថាប័ន តាមរយៈការជួបពិភាក្សាប្រមូលធាតុចូលពីក្រសួង-ស្ថាប័ន និងទិន្នន័យដែលបានកត់ត្រា និងរក្សាទុកក្នុងប្រព័ន្ធ FMIS សម្រាប់ប្រើប្រាស់ជាឯកសារយោងក្នុងសកម្មភាពអនុវត្តលទ្ធកម្មសាធារណៈ ។ ជាលទ្ធផល បញ្ជីស្តង់ដាថ្លៃទំនិញ និងសេវា ត្រូវបានរៀបចំរួចរាល់នៅចុងត្រីមាសទី ៤ ឆ្នាំ ២០២៣ ដោយមានវិសាលភាពគ្របដណ្តប់លើមុខទំនិញ និងសេវាសរុបប្រមាណជិត ៣ ០០០ មុខ ។ ក្នុងឆ្នាំ ២០២៤ បញ្ជីស្តង់ដាថ្លៃទំនិញ និងសេវា ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅ ក្រសួង-ស្ថាប័នចំនួន ៥ សម្រាប់ការរៀបចំថវិកាកម្មវិធី ឆ្នាំ២០២៥ និងគ្រោងពង្រីកវិសាលភាពទៅលើក្រសួង-ស្ថាប័នថ្នាក់ជាតិផ្សេងទៀតនៅឆ្នាំបន្ទាប់ ។ បន្ទាប់ពីបានដាក់ឱ្យអនុវត្តសាកល្បងបញ្ជីស្តង់ដាថ្លៃទំនិញ និងសេវានេះ ក្រុមការងារបច្ចេកទេសស្តង់ដាថ្លៃ របស់អគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្តចុះប្រមូលទិន្នន័យថ្លៃ ព្រមទាំងជួបពិភាក្សា និងប្រមូលធាតុចូលពីក្រសួង-ស្ថាប័ន ដើម្បីសិក្សាស្វែងយល់បន្ថែមអំពីតម្រូវការនៃការប្រើប្រាស់បញ្ជីស្តង់ដាថ្លៃទំនិញ និងសេវា តាមតម្រូវការជាក់ស្តែង ក៏ដូចជាបញ្ហាប្រឈមនៃការប្រើប្រាស់បញ្ជីស្តង់ដាថ្លៃ សម្រាប់ជាមូលដ្ឋានធ្វើបច្ចុប្បន្នភាព និងកែលម្អបញ្ជីស្តង់ដាថ្លៃទំនិញ និងសេវា ឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយបន្ថែមទៀត ។

មន្ត្រីជំនាញបច្ចេកទេស សម្រាប់រៀបចំប្រព័ន្ធស្តង់ដាថ្លៃ ជួយមន្ត្រីនៃនាយកដ្ឋានប្រសិទ្ធភាពចំណាយ នៃអគ្គនាយកដ្ឋានគោលនយោបាយ ដោយមានមុខងារ ភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

## ១- ភារកិច្ច និងការទទួលខុសត្រូវ

- សិក្សា ស្រាវជ្រាវ និងវិភាគលើយន្តការ និងបច្ចេកទេសនៃការគណនាថ្លៃទំនិញ និងសេវាក្នុងផ្នែកសំណង់
- ចូលរួមប្រមូលទិន្នន័យថ្លៃ រៀបចំ ចងក្រង និងធ្វើបច្ចុប្បន្នភាពបញ្ជីស្តង់ដាថ្លៃទំនិញ និងសេវា ជាពិសេសផ្នែកសំណង់
- ចូលរួមរៀបចំ ចងក្រង និងធ្វើបច្ចុប្បន្នភាព តារាងសម្រង់ថ្លៃទំនិញ និងសេវាលើទីផ្សារ ប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆមាស,
- សម្របសម្រួល និងគ្រប់គ្រងបច្ចេកទេសនៃការអនុវត្តបញ្ជីស្តង់ដាថ្លៃទំនិញ និងសេវា របស់ក្រសួង-ស្ថាប័ន,
- ចូលរួមសិក្សា និងរៀបចំស្តង់ដាថ្លៃដើម (cost standard) ព្រមទាំងរៀបចំស្តង់ដាទំនិញ និងសេវា សម្រាប់ការប្រើប្រាស់ក្នុងវិស័យសាធារណៈ ,
- តាមដាន និងវាយតម្លៃ គោលនយោបាយពាក់ព័ន្ធនឹងគោលការណ៍ថ្លៃ សម្រាប់ការគាំទ្រដល់ការរៀបចំចំណាយសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព,
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ថ្នាក់ដឹកនាំ ។

## ២- លក្ខណៈសម្បត្តិ

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ឬអនុបណ្ឌិតទាក់ទងនឹងជំនាញសេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ទីផ្សារ, ស្ថិតិ ឬជំនាញពាក់ព័ន្ធផ្សេងៗ,
- មានបទពិសោធន៍ក្នុងកិច្ចការស្រាវជ្រាវទីផ្សារ និងវិភាគយ៉ាងតិចចំនួន ០២ ឆ្នាំ ជាពិសេសពាក់ព័ន្ធនឹងថ្លៃនៃទំនិញ និងសេវាក្នុងវិស័យសំណង់
- មានបទពិសោធន៍ក្នុងការចុះប្រមូលទិន្នន័យថ្លៃលើទីផ្សារ ជាពិសេសផ្នែកសំណង់ (ជាការប្រសើរ)
- មានការយល់ដឹងអំពីស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា,
- មានសមត្ថភាពក្នុងការអាន ស្តាប់ សរសេរ និងនិយាយ ទាំងភាសាខ្មែរ និងភាសាអង់គ្លេស ។

## ៣- អត្ថប្រយោជន៍

- ទទួលបានប្រាក់បៀវត្ស និងលាភការផ្សេងៗ មានលក្ខណៈប្រកួតប្រជែង ស្របតាមជំនាញ និងបទពិសោធន៍,
- មានឱកាសធ្វើការទំនាក់ទំនងជាមួយស្ថាប័នជាច្រើន ទាំងក្នុង និងក្រៅប្រទេស,
- មានឱកាសចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលានានា ទាំងក្នុងប្រទេស និងក្រៅប្រទេស ដើម្បីកសាងសមត្ថភាពរបស់ខ្លួន, និង
- មានបរិស្ថានការងារល្អ ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធគាំទ្រគ្រប់គ្រាន់ ដូចជាប្រព័ន្ធអ៊ីនធឺណេត និងសម្ភារៈផ្គត់ផ្គង់ការិយាល័យផ្សេងៗទៀត ស្របតាមតម្រូវការបំពេញការងារជាក់ស្តែង ។

## ៤- រយៈពេលបំពេញការងារ

- កិច្ចសន្យាការងារមានរយៈពេល ១២ខែ និងអាចបន្តបានតាមសមិទ្ធផលការងាររបស់បុគ្គល និងតាមស្ថានភាពជាក់ស្តែង ។

# លក្ខខណ្ឌយោង

តួនាទី៖ វិភាគ និងវាយតម្លៃគម្រោងវិនិយោគសាធារណៈ

ទីកន្លែងបម្រើការងារ៖ នាយកដ្ឋានប្រសិទ្ធភាពចំណាយ នៃអគ្គនាយកដ្ឋានគោលនយោបាយ

__សាវតារ__

ស្របតាមទិសដៅនៃយុទ្ធសាស្ត្រស្តីពី ការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ (PIMSRS) ២០១៩-២០២៥, រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រ ដោយបង្កើតប្រព័ន្ធរួមមួយរបស់ជាតិ សម្រាប់ពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន ដែលក្នុងនោះ គណៈកម្មការវិនិយោគសាធារណៈ (គ.វ.ស.) ត្រូវបានបង្កើតឡើងសម្រាប់បំពេញមុខងារជាទ្វារបាលនៃការគ្រប់គ្រងការវិនិយោគសាធារណៈ ពីគ្រប់ប្រភពហិរញ្ញប្បទាន ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងចីរភាព នៃការបែងចែក និងប្រើប្រាស់ធនធាន នៃការវិនិយោគសាធារណៈ ។ គ.វ.ស. មានតួនាទីពង្រឹងការផ្សារភ្ជាប់រវាងផែនការវិនិយោគសាធារណៈ នឹងថវិកានីយកម្មវិនិយោគសាធារណៈ, គ្រប់គ្រង និងសម្របសម្រួលយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោងវិនិយោគសាធារណៈ, ពិនិត្យ និងវាយតម្លៃសំណើគម្រោងវិនិយោគសាធារណៈ, កំណត់ប្រភពហិរញ្ញប្បទាន សម្រាប់គម្រោងវិនិយោគសាធារណៈ, ពិនិត្យ និងកំណត់លក្ខខណ្ឌវិនិច្ឆ័យ សម្រាប់កំណត់ទំហំ និងភាពស្មុគស្មាញនៃគម្រោងវិនិយោគសាធារណៈ និងបំពេញការកិច្ចពាក់ព័ន្ធផ្សេងទៀត ។ អគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបន្ទុកជាលេខាធិការដ្ឋាន គ.វ.ស. មានតួនាទីផ្តល់ការគាំទ្រដល់កិច្ចដំណើរការទាំងស្រុងរបស់ គ.វ.ស. ។

មន្ត្រីជំនាញបច្ចេកទេស សម្រាប់វិភាគ និងវាយតម្លៃគម្រោងវិនិយោគសាធារណៈ ជួយមន្ត្រីនៃនាយកដ្ឋានប្រសិទ្ធភាពចំណាយ នៃអគ្គនាយកដ្ឋានគោលនយោបាយ ដោយមានភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

### ១- *ភារកិច្ច និងការទទួលខុសត្រូវ*

- សិក្សា និងរៀបចំឧបករណ៍វាយតម្លៃផលចំណេញសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់គម្រោងវិនិយោគសាធារណៈ
- សិក្សា និងរៀបចំឧបករណ៍សម្រាប់វិភាគ និងវាយតម្លៃ សំណើគម្រោងវិនិយោគសាធារណៈ ស្របតាមឧត្តមានុវត្តអន្តរជាតិ
- ចូលរួមអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈ
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ថ្នាក់ដឹកនាំ ។

### ២- លក្ខណៈសម្បត្តិ

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ឬអនុបណ្ឌិតទាក់ទងនឹងជំនាញសេដ្ឋកិច្ច, ហិរញ្ញវត្ថុ, ទំនាក់ទំនងអន្តរជាតិ, ស្ថិតិ ឬជំនាញពាក់ព័ន្ធផ្សេងៗ,
- មានបទពិសោធន៍ពាក់ព័ន្ធនឹងជំនាញបានរៀបរាប់ខាងលើ យ៉ាងតិច ០២ ឆ្នាំ,
- មានសមត្ថភាពប្រើប្រាស់កម្មវិធី Microsoft ដូចជា Word, Excel និង PowerPoint
- មានការយល់ដឹងអំពីស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា,
- មានសមត្ថភាពក្នុងការអាន ស្តាប់ សរសេរ និងនិយាយ ទាំងភាសាខ្មែរ និងភាសាអង់គ្លេស, និង
- មានការអត់ធ្មត់ខ្ពស់ ធន់នឹងសម្ពាធការងារ មានទំនាក់ទំនងល្អជាមួយក្រុមការងារ និងចេះធ្វើការងារជាក្រុម ។

### ៣- អត្ថប្រយោជន៍

- ទទួលបានប្រាក់បៀវត្ស និងលាភការផ្សេងៗ មានលក្ខណៈប្រកួតប្រជែង ស្របតាមជំនាញ និងបទពិសោធន៍,
- មានឱកាសធ្វើការទំនាក់ទំនងជាមួយស្ថាប័នជាច្រើន ទាំងក្នុង និងក្រៅប្រទេស,
- មានឱកាសចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលានានា ទាំងក្នុងប្រទេស និងក្រៅប្រទេស ដើម្បីកសាងសមត្ថភាពរបស់ខ្លួន, និង
- មានបរិស្ថានការងារល្អ ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធគាំទ្រគ្រប់គ្រាន់ ដូចជាប្រព័ន្ធអ៊ីនធឺណេត និងសម្ភារៈផ្គត់ផ្គង់ការិយាល័យផ្សេងៗទៀត ស្របតាមតម្រូវការបំពេញការងារជាក់ស្តែង ។

### ៤- រយៈពេលបំពេញការងារ

- កិច្ចសន្យាការងារមានរយៈពេល ១២ខែ និងអាចបន្តបានតាមសមិទ្ធផលការងាររបស់បុគ្គល និងតាមស្ថានភាពជាក់ស្តែង ។

# លក្ខខណ្ឌយោង

តួនាទី៖ វិភាគ និងវាយតម្លៃប្រសិទ្ធភាពចំណាយ នៃវិធានការគោលនយោបាយរបស់រាជរដ្ឋាភិបាល

ទីកន្លែងបម្រើការងារ៖ នាយកដ្ឋានប្រសិទ្ធភាពចំណាយ នៃអគ្គនាយកដ្ឋានគោលនយោបាយ

<u>***សាវតារ***</u>

រាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ខ្ពស់ ដល់ការអភិវឌ្ឍនៃវិស័យឯកជន ជាពិសេសសហគ្រាស ធុនមីក្រូ តូច និងមធ្យម និងធុរកិច្ចថ្មី និងបានដាក់ចេញនូវយន្តការអន្តរាគមន៍សំដៅជួយដោះស្រាយបញ្ហាប្រឈមនានា និងគាំទ្រ សហគ្រាសធុនមីក្រូ តូច និងមធ្យម ជាបន្តបន្ទាប់ សំដៅគាំទ្រដល់ការចូលរួមឱ្យបានពេញលេញ ទៅក្នុងដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ជាក់ស្តែង ការបង្កើតឡើងនូវយន្តការគាំទ្រ ដូចជា មូលនិធិអភិវឌ្ឍន៍ជំនាញ និងមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព ជាដើម បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងការឈានទៅកសាងកម្លាំងពលកម្មជំនាញឱ្យសមស្របទៅនឹងតម្រូវការទីផ្សារ ព្រមទាំងកសាងនូវប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព នៅក្នុងប្រទេសកម្ពុជា។ បន្ទាប់ពីបានដាក់ចេញនូវវិធានការគោលនយោបាយ និងកម្មវិធីអន្តរាគមន៍ជាបន្តបន្ទាប់ នាពេលកន្លងមក, រាជរដ្ឋាភិបាលដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសេនាធិការ មានភាពចាំបាច់វាយតម្លៃគ្រប់ជ្រុងជ្រោយ កម្រិតអនុវត្ត និងកម្រិតគោលនយោបាយ លើវិធានការគោលនយោបាយ និងកម្មវិធីអន្តរាគមន៍ទាំងនោះ ដើម្បីធានានូវប្រសិទ្ធភាពគោលនយោបាយ ប្រសិទ្ធភាពថវិកា និងគណនេយ្យភាពហិរញ្ញវត្ថុជាតិ ដែលជាផ្នែកមួយនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

មន្ត្រីបច្ចេកទេសជាន់ខ្ពស់ សម្រាប់វិភាគ និងវាយតម្លៃប្រសិទ្ធភាពចំណាយ នៃវិធានការគោលនយោបាយរបស់រាជរដ្ឋាភិបាល ជួយមន្ត្រីនៃនាយកដ្ឋានប្រសិទ្ធភាពចំណាយ នៃអគ្គនាយកដ្ឋានគោលនយោបាយ ដោយមានភារកិច្ច និងការទទួលខុសត្រូវ ដូចខាងក្រោម៖

## ***១- ភារកិច្ច និងការទទួលខុសត្រូវ***

- រៀបចំក្របខណ្ឌទស្សនាទាន ស្តីពីក្របខណ្ឌនៃការវិភាគប្រសិទ្ធភាពចំណាយ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ និងបរិបទរបស់កម្ពុជា,
- រៀបចំក្របខណ្ឌទស្សនាទាន ស្តីពីឧបករណ៍វាស់វែងប្រសិទ្ធភាពចំណាយ ដែលរួមបញ្ចូលទាំងវិធីសាស្ត្រ សូចនាករ និងបច្ចេកទេសក្នុងការប្រមូល និងវិភាគទិន្នន័យ,
- ប្រមូលទិន្នន័យ និងធ្វើការវិភាគ និងវាយតម្លៃ ការអនុវត្តវិធានការគោលនយោបាយ និងកម្មវិធីអន្តរាគមន៍របស់រាជរដ្ឋាភិបាល,
- រៀបចំកិច្ចពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីប្រមូលធាតុចូល និងកែលម្អសេចក្តីព្រាងក្របខណ្ឌទស្សនាទាន ដែលបានរៀបចំ
- ចូលរួមអនុវត្តផែនការសកម្មភាពការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពាក់ព័ន្ធនឹងការវាយតម្លៃប្រសិទ្ធភាពចំណាយ និងការលើកកម្ពស់គណនេយ្យភាពសមិទ្ធកម្ម និង
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនរបស់ថ្នាក់ដឹកនាំ ។

## ***២- លទ្ធផលរំពឹងទុក***

- របាយការណ៍លទ្ធផលនៃការរៀបចំក្របខណ្ឌទស្សនាទាន ស្តីពីក្របខណ្ឌការវិភាគប្រសិទ្ធភាពចំណាយ,
- របាយការណ៍លទ្ធផលនៃការរៀបចំក្របខណ្ឌទស្សនាទាន ស្តីពីឧបករណ៍វាស់វែងប្រសិទ្ធភាពចំណាយ, និង

- របាយការណ៍លទ្ធផលនៃការវិភាគ និងវាយតម្លៃការអនុវត្តវិធានការគោលនយោបាយ និងកម្មវិធីអន្តរាគមន៍របស់រាជរដ្ឋាភិបាល ។

## ៣- លក្ខណៈសម្បត្តិ

- មានសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ឬអនុបណ្ឌិតទាក់ទងនឹងជំនាញសេដ្ឋកិច្ច, ហិរញ្ញវត្ថុ, គោលនយោបាយសាធារណៈ ឬជំនាញពាក់ព័ន្ធផ្សេងៗ,
- បទពិសោធន៍ការងារយ៉ាងតិច ៣ ទៅ ៤ ឆ្នាំ ពាក់ព័ន្ធនឹងការវិភាគ និងវាយតម្លៃការអនុវត្តគោលនយោបាយ, ការស្រាវជ្រាវផ្នែកសេដ្ឋកិច្ច, ឬកិច្ចការប្រហាក់ប្រហែល ដែលផ្តោតលើការវាយតម្លៃប្រសិទ្ធភាពចំណាយ ឬការវិភាគបន្ទុកចំណាយ និងផលចំណេញ (cost benefit analysis) ។
- មានបទពិសោធន៍ពាក់ព័ន្ធនឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី ឬគម្រោង ជាការប្រសើរ
- មានសមត្ថភាពក្នុងការអាន ស្តាប់ សរសេរ និងនិយាយ ទាំងភាសាខ្មែរ និងភាសាអង់គ្លេស, និង
- មានការអត់ធ្មត់ខ្ពស់ ធន់នឹងសម្ពាធការងារ មានទំនាក់ទំនងល្អជាមួយក្រុមការងារ និងចេះធ្វើការងារជាក្រុម ។

## ៤- អត្ថប្រយោជន៍

- ទទួលបានប្រាក់បៀវត្ស និងលាភការផ្សេងៗ មានលក្ខណៈប្រកួតប្រជែង ស្របតាមជំនាញ និងបទពិសោធន៍,
- មានឱកាសធ្វើការទំនាក់ទំនងជាមួយស្ថាប័នជាច្រើន ទាំងក្នុង និងក្រៅប្រទេស,
- មានឱកាសចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលានានា ទាំងក្នុងប្រទេស និងក្រៅប្រទេស ដើម្បីកសាងសមត្ថភាពរបស់ខ្លួន, និង
- មានបរិស្ថានការងារល្អ ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធគាំទ្រគ្រប់គ្រាន់ ដូចជាប្រព័ន្ធអ៊ីនធឺណេត និងសម្ភារៈផ្គត់ផ្គង់ការិយាល័យផ្សេងៗទៀត ស្របតាមតម្រូវការបំពេញការងារជាក់ស្តែង ។

## ៥- រយៈពេលបំពេញការងារ

- កិច្ចសន្យាការងារមានរយៈពេល ១២ខែ និងអាចបន្តបានតាមសមិទ្ធផលការងាររបស់បុគ្គល និងតាមស្ថានភាពជាក់ស្តែង ។

# ឧបសម្ព័ន្ធ៣៖

# ប្រកាសស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាន និងវាយតម្លៃ សម្រាប់ផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...........សហវ.......

# ប្រកាស
# ស្តីពី
# គោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួល មាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់-គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈ-កម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញសារាចររាជរដ្ឋាភិបាលលេខ ១៤ សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ ស្តីពីការបង្កើតមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញសេចក្តីសម្រេចលេខ ២៥ សសរ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ ស្តីពីការបង់ភាគទានរបស់ក្រសួង ស្ថាប័នចូលក្នុងមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងរញ្ញវត្ថុសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) ប្រចាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយប្រើប្រាស់ថវិកាក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយសមធម៌ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់ការលើកចិត្តជូន **ក.ហ.ស.** ប្រចាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត។

## ជំពូកទី២
## គោលការណ៍លើកទឹកចិត្ត

**ប្រការ៣ .-**

ការលើកទឹកចិត្ត សំដៅដល់ការផ្តល់ប្រាក់ឧបត្ថម្ភជូន **គ.ហ.ស**. ប្រចាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនប្រកបដោយផលិតភាព គុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ៤ .-**

ការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់សមាសភាព **គ.ហ.ស**. ប្រចាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាត់ទុកជាគម្រោង ដោយបែងចែកមុខតំណែងជា ៥ (ប្រាំ) ប្រភេទ រួមមាន៖ ប្រធានគម្រោង អនុប្រធានគម្រោង ប្រធានក្រុមការងារ មន្ត្រីជំនាញជាន់ខ្ពស់ និងមន្ត្រីជំនាញ។

**ប្រការ៥ .-**

ប្រាក់ឧបត្ថម្ភ ត្រូវបានកំណត់ ១ (មួយ) សន្ទស្សន៍ ស្មើនឹង ៣៨០០ (បីពាន់ប្រាំបីរយ) រៀល និងមានកម្រិតសន្ទស្សន៍ ប្រចាំខែ ដូចខាងក្រោម៖

**ក. កម្រិតសន្ទស្សន៍ទូទៅ**

- ប្រធានគម្រោង ស្មើនឹង ៥២៦
- អនុប្រធានគម្រោង ស្មើនឹង ៣៩៥
- ប្រធានក្រុមការងារ ស្មើនឹង ៣៤២
- មន្ត្រីជំនាញជាន់ខ្ពស់ ស្មើនឹង ២៦៣ និង
- មន្ត្រីជំនាញ ស្មើនឹង ២១១។

**ខ. កម្រិតសន្ទស្សន៍ពិសេស**

- សន្ទស្សន៍ពិសេសកម្រិត១ ស្មើនឹង ២១០៥
- សន្ទស្សន៍ពិសេសកម្រិត២ ស្មើនឹង ១៣១៦ និង
- សន្ទស្សន៍ពិសេសកម្រិត៣ ស្មើនឹង ១០៥៣។

ក្នុងករណីមានជំនាញពិសេសចាំបាច់ពាក់ព័ន្ធនឹងការរៀបចំគោលនយោបាយ ឬ លិខិតបទដ្ឋានគតិយុត្តក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលជាក់ស្តែងតម្រូវឱ្យមានការផ្តល់ប្រាក់ឧបត្ថម្ភខ្ពស់ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស**.) អាចពិនិត្យ និងសម្រេចលើការស្នើផ្តល់សន្ទស្សន៍ទូទៅ ឬ សន្ទស្សន៍ពិសេសក្នុងកម្រិតណាមួយ ដូចបានកំណត់ក្នុងចំណុច "**ក**" និង ចំណុច "**ខ**" ខាងលើ។ សមាសភាព **គ.ហ.ស**. ពុំអាចស្នើសុំប្រាក់ឧបត្ថម្ភ ក្រៅពីសន្ទស្សន៍ដូចមានកំណត់បានឡើយ។

## ជំពូកទី៣
## យន្តការ

**ប្រការ៦ .-**

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ត្រូវរៀបចំបង្កើតក្រុមការងារវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ ហៅកាត់ថា **ក.ល.ហ.** ជាសេនាធិការរបស់ **គ.ហ.ស.** ក្នុងតួនាទីភារកិច្ចត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | អគ្គលេខាធិការ នៃ **អ.គ.ហ.** | ប្រធាន |
| ២. | អគ្គលេខាធិការរង ទទួលបន្ទុកហិរញ្ញវត្ថុ នៃ **អ.គ.ហ.** | អនុប្រធានប្រចាំការ |
| ៣. | អគ្គលេខាធិការរង នៃ **អ.គ.ហ.** | អនុប្រធាន |
| ៤. | នាយករដ្ឋបាល ហិរញ្ញវត្ថុ និង ត្រួតពិនិត្យនិងវាយតម្លៃ នៃ **អ.គ.ហ.** | អនុប្រធាន និងជាលេខាធិការ |
| ៥. | មន្ត្រីជំនាញជាន់ខ្ពស់ នៃ **អ.គ.ហ.** មួយចំនួន | សមាជិក |
| ៦. | មន្ត្រីជំនាញ នៃ **អ.គ.ហ.** មួយចំនួន | សមាជិក |

សមាសភាពជាក់ស្តែង និងតួនាទីភារកិច្ច នៃ **ក.ល.ហ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។

**ប្រការ៧ .-**

អនុលោមតាមពិតានប្រាក់ឧបត្ថម្ភដែលកំណត់ដោយ **គ.ហ.ស.** **ក.ហ.ស.** នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំផែនការលើកទឹកចិត្តប្រចាំឆ្នាំ និងសមាសភាពទទួលប្រាក់-ឧបត្ថម្ភ ដោយបំពេញឧបសម្ព័ន្ធទី១ និងទី២ ហើយភ្ជាប់មកជាមួយនូវលទ្ធផលគន្លឹះក្នុងឆ្នាំ ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្ញើមក **អ.គ.ហ.** ត្រឹមសប្តាហ៍ទី១ ខែតុលា មុនឆ្នាំអនុវត្ត។

**ប្រការ៨ .-**

ក្នុងនាមជាសេនាធិការ នៃ **គ.ហ.ស.** **ក.ល.ហ.** ត្រូវពិនិត្យ និងវាយតម្លៃផែនការលើកទឹកចិត្តប្រចាំឆ្នាំដូចមានចែងក្នុងប្រការ៧ យ៉ាងម៉ឺងម៉ាត់ ដោយផ្អែកលើលទ្ធផលគន្លឹះក្នុងឆ្នាំ និងលក្ខខណ្ឌយោងការងារ នៃឆ្នាំបន្ទាប់ របស់ **ក.ហ.ស.** នៃ អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីដាក់ឆ្លងប្រធាន **គ.ហ.ស.** ពិនិត្យ និងឯកភាព ត្រឹមដំណាច់ខែធ្នូ មុនឆ្នាំអនុវត្ត។

**ប្រការ៩ .-**

សមាសភាព **ក.ហ.ស.** ដែលទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.** តាមការស្នើសុំរបស់ **អ.គ.ហ.**។

**ប្រការ១០ ..**

**គ.ហ.ស.** ប្រចាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិផ្លាស់ប្តូរសមាសភាពទទួលបានប្រាក់ឧបត្ថម្ភប្រចាំអង្គភាពរបស់ខ្លួន ក្នុងឆ្នាំអនុវត្ត តាមការចាំបាច់ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយភ្ជាប់មកជាមួយនូវលក្ខខណ្ឌយោងការងាររបស់សមាសភាពថ្មី មក **អ.គ.ហ.** យ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែ១ នៃត្រីមាសបន្ទាប់ បន្ទាប់ពីការបើកផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ត្រីមាសណាមួយ។

## ជំពូកទី៤

## ការតាមដាន និងវាយតម្លៃ និងនីតិវិធីនៃការបើកផ្តល់

**ប្រការ១១ ..**

ប្រធាន **គ.ហ.ស.** ត្រូវកោះប្រជុំប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ឬ តាមការចាំបាច់ ដើម្បីតាមដាន និងវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសមិទ្ធកម្មរបស់មន្ត្រីរាជការ បុគ្គលិក ដែលជាសមាសភាព **គ.ហ.ស.** ទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត។ ក្នុងករណីអវត្តមាន ប្រធាន **គ.ហ.ស.** អាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួស។ ចំពោះសមិទ្ធកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំរបស់មន្ត្រីរាជការ បុគ្គលិក ត្រូវប្រើប្រាស់ទម្រង់វាយតម្លៃសមិទ្ធកម្ម ក្នុងឧបសម្ព័ន្ធទី៤ ដើម្បីជាមូលដ្ឋានសម្រាប់កិច្ចពិភាក្សា និងជាកម្មវត្ថុ នៃការផ្អាក ឬ បន្តផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត។

**ប្រការ១២ ..**

**គ.ហ.ស.** ប្រចាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំរបាយការណ៍សមិទ្ធកម្ម នៃការអនុវត្តផែនការសកម្មភាពលម្អិតប្រចាំត្រីមាស និងប្រចាំឆ្នាំ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ចំពោះរបាយការណ៍បូកសរុបការវាយតម្លៃសមិទ្ធកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំ របស់មន្ត្រីរាជការ បុគ្គលិក ដែលជាសមាសភាព **គ.ហ.ស.** ទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវរៀបចំតាមឧបសម្ព័ន្ធទី៣ រួចផ្ញើមក **អ.គ.ហ.** ឱ្យបានទាន់ពេលវេលា ដែលជាលក្ខខណ្ឌតម្រូវសម្រាប់បើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត សម្រាប់ ៣ (បី) ត្រីមាស។

**ប្រការ១៣ ..**

ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវបើកផ្តល់ តាមលក្ខខណ្ឌដូចខាងក្រោម៖

**ក. លក្ខខណ្ឌទូទៅ**

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៦០ (ហុកសិប) ភាគរយ នៃប្រាក់ឧបត្ថម្ភប្រចាំឆ្នាំ ត្រូវបើកផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ដែលជាសមាសភាព **គ.ហ.ស.** នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ ៣ (បី) ត្រីមាស ដោយក្នុង ១ (មួយ) ត្រីមាស ត្រូវបើកផ្តល់ចំនួន ២០ (ម្ភៃ) ភាគរយ។ ការបើកផ្តល់ អាចប្រព្រឹត្តទៅបាន បន្ទាប់ពី **អ.គ.ហ.** ទទួលបាននូវឯកសារ ដូចខាងក្រោម៖

- កិច្ចព្រមព្រៀងសមិទ្ធកម្ម ភ្ជាប់មកជាមួយនូវលទ្ធផលគន្លឹះក្នុងឆ្នាំ
- ផែនការលើកទឹកចិត្ត និងលក្ខខណ្ឌយោងការងាររបស់ **គ.ហ.ស.** នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- របាយការណ៍សមិទ្ធកម្ម នៃការអនុវត្តផែនការសកម្មភាពលម្អិតប្រចាំត្រីមាស និងប្រចាំឆ្នាំ N-1 ក្នុងនោះ របាយការណ៍ប្រចាំឆ្នាំ N-1 សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី១ របាយការណ៍ប្រចាំត្រីមាសទី១



ម៉ាង

សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី២ របាយការណ៍ប្រចាំត្រីមាសទី២ សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី៣ និង

- របាយការណ៍បូកសរុបការវាយតម្លៃសមិទ្ធកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំ របស់មន្ត្រីរាជការ បុគ្គលិក ដែលជាសមាសភាព **ក.ហ.ស**. ទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ក្នុងនោះ របាយការណ៍ប្រចាំឆ្នាំ N-1 សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី១ របាយការណ៍ប្រចាំត្រីមាសទី១ សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី២ របាយការណ៍ប្រចាំត្រីមាសទី២ សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី៣។

**ខ. លក្ខខណ្ឌសមិទ្ធកម្ម**

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៤០ (សែសិប) ភាគរយ ដែលនៅសេសសល់ក្នុងឆ្នាំ ត្រូវបើកផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ដែលជាសមាសភាព **ក.ហ.ស**. សម្រាប់ត្រីមាសទី៤ តាមលក្ខខណ្ឌ និងនីតិវិធី ដូចខាងក្រោម៖

- **ក.ល.ហ**. ត្រូវរៀបចំវិភាជសមាមាត្រប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៤០ (សែសិប) ភាគរយ ទៅតាមលទ្ធផលគន្លឹះក្នុងឆ្នាំនីមួយៗ ហើយចែកសមាមាត្រស្មើៗគ្នាទៅតាមសូចនាករសមិទ្ធកម្មគន្លឹះគាំទ្រនីមួយៗ
- សូចនាករសមិទ្ធកម្មគន្លឹះនីមួយៗគាំទ្រដល់លទ្ធផលគន្លឹះក្នុងឆ្នាំ ត្រូវបានដាក់ពិន្ទុ ១ សម្រាប់វឌ្ឍនភាពពណ៌បៃតងចាស់, ពិន្ទុ ០,៧៥ សម្រាប់វឌ្ឍនភាពពណ៌បៃតងខ្ចី, ពិន្ទុ ០,៥ សម្រាប់វឌ្ឍនភាពពណ៌លឿង និង ០ សម្រាប់វឌ្ឍនភាពពណ៌ក្រហម និង
- លទ្ធផលនៃការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំនីមួយៗ ដែលបូកយោងពីពិន្ទុវាយតម្លៃសូចនាករសមិទ្ធកម្មគន្លឹះនីមួយៗ នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការបើកផ្តល់ប្រាក់ឧត្ថម្ភលើកទឹកចិត្តសម្រាប់ត្រីមាសទី៤។

**ក.ល.ហ**. ត្រូវប្រើប្រាស់ទម្រង់ឧបសម្ព័ន្ធទី៥ សម្រាប់ជាមូលដ្ឋាននៃការវិភាជ ការវាយតម្លៃ និងការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៤០ (សែសិប) ភាគរយ។

ដើម្បីបើកផ្តល់ប្រាក់ឧបត្ថម្ភទាន់ពេលវេលាសម្រាប់លក្ខខណ្ឌសមិទ្ធកម្ម អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ ប្រចាំឆ្នាំ ដោយភ្ជាប់មកជាមួយឯកសារយោងឱ្យបានត្រឹមត្រូវ មក **អ.គ.ហ**. យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទី១ នៃខែទី១ នៃឆ្នាំបន្ទាប់។ **ក.ល.ហ**. ត្រូវបញ្ចប់ការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំ ត្រឹមសប្តាហ៍ទី៤ នៃខែទី១ នៃឆ្នាំបន្ទាប់ និងបើកផ្តល់យ៉ាងយូរត្រឹមសប្តាហ៍ទី១ នៃខែទី២ នៃឆ្នាំបន្ទាប់។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ១៤ ..**

ផែនការលើកទឹកចិត្តសម្រាប់ឆ្នាំ២០២៤ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបន្តអនុវត្ត អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន រហូតដល់ដំណាច់ខែធ្នូ ឆ្នាំ២០២៤។

**ប្រការ១៥ ..**

សន្ទស្សន៍ប្រាក់ឧបត្ថម្ភលើកទឹកចិត្តរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ដែលជាសមាសភាព **ក.ហ.ស**. នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបានកន្លងមក ដោយអនុលោម

ឬ មិនអនុលោមតាមប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទុកជានិរាករណ៍ ហើយត្រូវរៀបចំថ្មី បន្ទាប់ពីប្រកាសនេះ ត្រូវបានដាក់ឱ្យអនុវត្ត។

**ប្រការ១៦ ..**

ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ អាចមានការប្រែប្រួលជាយថាហេតុ ផ្អែកតាមស្ថានភាព និង លទ្ធភាព នៃថវិកាក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ១៧ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៨ ..**

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។

**ប្រការ១៩ ..**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង **អ.គ.ហ.** ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

នៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ៤៨៨ សហវ.ប្រក.អគហ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០២៤ ស្ដីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្ដល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អង្គភាព/អគ្គនាយកដ្ឋាន/មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**........

## ផែនការលើកទឹកចិត្តប្រចាំឆ្នាំ.................
## សម្រាប់ ក.ហ.ស. នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ. | គោត្តនាម និងនាម | ភេទ | មុខងារក្នុងគម្រោង | សន្ទស្សន៍ | ប្រាក់ឧបត្ថម្ភប្រចាំខែ | ប្រាក់ឧត្ថម្ភប្រចាំឆ្នាំ | ឈ្មោះធនាគារ | លេខគណនី |
|---|---|---|---|---|---|---|---|---|
| | | | ប្រធានគម្រោង | | | | | |
| | | | អនុប្រធានគម្រោង | | | | | |
| | | | ប្រធានក្រុមការងារ | | | | | |
| | | | មន្ត្រីជំនាញជាន់ខ្ពស់ | | | | | |
| | | | មន្ត្រីជំនាញ | | | | | |

បានឃើញ និងឯកភាព
ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......
**ប្រធាន ក.ហ.ស. នៃអង្គភាព/អគ្គនាយកដ្ឋាន/មន្ទីរ**
**សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**.......................

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......
**អ្នករៀបចំតារាង**

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ៤៨៨ សហវ.ប្រក.អគហ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អង្គភាព/អគ្គនាយកដ្ឋាន/មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**........

## លក្ខខណ្ឌយោងការងារ ប្រចាំឆ្នាំ...................
## សម្រាប់ ក.ហ.ស. នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ. | គោត្តនាម និងនាម | ភេទ | មុខតំណែងក្នុងក្របខ័ណ្ឌមន្ត្រីរាជការ | មុខងារក្នុងគម្រោង | សន្ទស្សន៍ | លទ្ធផលគន្លឹះក្នុងឆ្នាំ/សូចនាករសមិទ្ធកម្មគន្លឹះ |
|---|---|---|---|---|---|---|
| | | | | ប្រធានគម្រោង | | - ទទួលបន្ទុក |
| | | | | អនុប្រធានគម្រោង | | - ទទួលបន្ទុក |
| | | | | ប្រធានក្រុមការងារ | | - ទទួលបន្ទុក |
| | | | | មន្ត្រីជំនាញជាន់ខ្ពស់ | | - ទទួលបន្ទុក |
| | | | | មន្ត្រីជំនាញ | | - ទទួលបន្ទុក |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......
**ប្រធាន ក.ហ.ស. នៃអង្គភាព/អគ្គនាយកដ្ឋាន/មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**......................

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ៩៨៨ សហវ.ប្រក ១១៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៤ ស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អង្គភាព/អគ្គនាយកដ្ឋាន/មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**........

**របាយការណ៍បូកសរុបការវាយតម្លៃសមិទ្ធកម្ម មន្ត្រីរាជការ បុគ្គលិក ដែលជាសមាសភាព គ.ហ.ស.**

**ទទួលប្រាក់ឧបត្ថម្ភ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី........ឆ្នាំ......../ប្រចាំឆ្នាំ........**

| ល.រ. | គោត្តនាម និងនាម | ភេទ | មុខងារក្នុងគម្រោង | លទ្ធផលគន្លឹះក្នុងឆ្នាំ/សូចនាករសមិទ្ធកម្មគន្លឹះ | លទ្ធផលសម្រេចបាន | ពិន្ទុសមិទ្ធកម្ម | បន្ត ឬ ផ្អាក |
|---|---|---|---|---|---|---|---|
| ១ | | | អនុប្រធានគម្រោង | | | | |
| ២ | | | ប្រធានក្រុមការងារ | | | | |
| ៣ | | | មន្ត្រីជំនាញជាន់ខ្ពស់ | | | | |
| ៤ | | | មន្ត្រីជំនាញ | | | | |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......

**ប្រធាន គ.ហ.ស. នៃអង្គភាព/អគ្គនាយកដ្ឋាន/មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**.......................

ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ ៩៨៨ សហវ.ប្រក.អគ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤ ស្តីពី
គោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត
ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អង្គភាព/អគ្គនាយកដ្ឋាន/មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ........**

**ការវាយតម្លៃសមិទ្ធកម្មមន្ត្រីរាជការ បុគ្គលិក**
**ដែលជាសមាសភាព គ.ហ.ស. ទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្រោមកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី......ឆ្នាំ......../ប្រចាំឆ្នាំ........**

គោត្តនាម-នាមមន្ត្រី៖.......................................
មុខងារគម្រោង៖...........................................
អ្នកគ្រប់គ្រងផ្ទាល់៖........................................

**១.សមិទ្ធកម្មតាមមុខងារនិងភារកិច្ច**

| *បំពេញដោយមន្ត្រីអនុវត្ត* | | | *វាយតម្លៃដោយអ្នកគ្រប់គ្រងផ្ទាល់* |
|---|---|---|---|
| **ល.រ** | **លទ្ធផលគន្លឹះក្នុងឆ្នាំ/សូចនាករសមិទ្ធកម្មគន្លឹះ** | **លទ្ធផលសម្រេចបាន** | **ពិន្ទុសមិទ្ធកម្ម** |
| ១ | | | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| | | | |
| | | | |
| | | | |

**២. សមត្ថភាពស្នូល**

| **ល.រ** | **ការអនុវត្ត** | **ពិន្ទុសមិទ្ធកម្ម** ( *វាយតម្លៃដោយអ្នកគ្រប់គ្រងផ្ទាល់* ) |
|---|---|---|
| ២ | **គុណភាពការងារ៖**<br>ការបំពេញការងារបានត្រឹមត្រូវ ប្រសិទ្ធភាព និងតាមកាលបរិច្ឆេទកំណត់ ដោយមានការតម្រង់ទិសបន្តិចបន្តួច | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ៣ | **វត្តមាន និងភាពទៀងទាត់៖** | ❑ *កម្រិតឧត្តមភាព* |

| | | |
|---|---|---|
| | មកបំពេញការងារបានទៀងទាត់ ផ្តល់ដំណឹងមុនក្នុងករណីស្នើសុំច្បាប់ | ❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ៤ | **ភាពជឿជាក់៖**<br>បំពេញសមិទ្ធកម្មបានក្នុងកម្រិតខ្ពស់។ គ្រប់គ្រងពេលវេលា និងបន្ទុកការងារប្រកបដោយប្រសិទ្ធភាព និងមានការទទួលខុសត្រូវ។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ៥ | **ជំនាញទំនាក់ទំនង៖**<br>ទំនាក់ទំនងផ្ទាល់មាត់ និងបែបសរសេរ មានលក្ខណៈច្បាស់លាស់ មានសណ្តាប់ធ្នាប់ និងមានប្រសិទ្ធភាព។ ស្តាប់ និងឈ្វេងយល់បានល្អ។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ៦ | **ការវិនិច្ឆ័យ និងការសម្រេចចិត្ត៖**<br>ធ្វើការសម្រេចចិត្តសមហេតុសមផល។ មានការវិនិច្ឆ័យល្អ មានភាពប៉ិនប្រសព្វ និងមានគំនិតច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហា។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ៧ | **គំនិតផ្តួចផ្តើម និងភាពទន់ភ្លន់៖**<br>បង្ហាញនូវគំនិតផ្តួចផ្តើម និងស្វែងរកនូវការងារដែលផ្តល់តម្លៃបន្ថែម។ កំណត់បាននូវបញ្ហា និងដំណោះស្រាយ។ ជំនះបញ្ហាប្រឈម និងសម្របទៅនឹងការផ្លាស់ប្តូរ។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ៨ | **ការបំពេញការងារជាក្រុម ក្រមសីលធម៌ និងកិច្ច-សហការ**<br>ផ្តល់នូវការគោរព ឱ្យតម្លៃចំពោះសហការី និងផ្តល់វិភាគទានដែលជាតម្លៃបន្ថែម ដើម្បីសម្រេចគោល-ដៅការងារក្នុងក្រុម។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |

## ៣. សមត្ថភាពការងារជាក់លាក់

| ល.រ | ការអនុវត្ត | ពិន្ទុសមិទ្ធកម្ម *(វាយតម្លៃដោយអ្នកគ្រប់គ្រងផ្ទាល់)* |
|---|---|---|
| ៩ | **ចំណេះដឹងពាក់ព័ន្ធមុខងារគម្រោង**<br>មានជំនាញ ចំណេះដឹង និងសមត្ថភាពចាំបាច់ក្នុង | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក* |

| | | |
|---|---|---|
| | ការបំពេញការងារ។ | ❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ១០ | **ការបណ្ដុះបណ្ដាល និងការអភិវឌ្ឍ៖**<br>បន្តស្វែងរកមធ្យោបាយក្នុងការពង្រឹងសមត្ថភាព និងពង្រឹងសមត្ថភាពពាក់ព័ន្ធការងារជាប្រចាំ តាមរយៈការសិក្សាឈ្វេងយល់ផ្ទាល់ខ្លួន និងការចូលរួមផ្សេងៗ។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |

*កំណត់សម្គាល់៖ កម្រិតឧត្តមភាព ១០ ពិន្ទុ, លើសពីការរំពឹងទុក ៨ ពិន្ទុ, ស្របតាមការរំពឹងទុក ៦ ពិន្ទុ, មិនទាន់ស្របពេញលេញតាមការរំពឹងទុក ៤ ពិន្ទុ, មានតម្រូវការកែលម្អ ២ ពិន្ទុ។*

**ពិន្ទុសរុប (សមិទ្ធកម្មតាមមុខងារនិងភារកិច្ច+សមត្ថភាពស្នូល +សមត្ថភាពការងារជាក់លាក់)៖**

**......................................**

**សម្រេច ÷ បន្ត** ☐ **ផ្អាក** ☐

**មតិយោបល់របស់មន្ត្រីអនុវត្ត៖**.......................................

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២...... រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២.....

**អ្នកគ្រប់គ្រងផ្ទាល់** **មន្ត្រី**

**បានឃើញ និងឯកភាព**

ថ្ងៃ ខែ ឆ្នាំ ........ស័ក ព.ស ២៥៦.....

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......

**ប្រធាន គ.ហ.ស. នៃអង្គភាព/អគ្គនាយកដ្ឋាន/មន្ទីរសេដ្ឋកិច្ច**
**និងហិរញ្ញវត្ថុរាជធានី-ខេត្ត**...........

ឧបសម្ព័ន្ធទី៥ នៃប្រកាសលេខ ៤៨៨ សហវ.ប្រក.គគល ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ**
**ដឹកនាំការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

## ការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំ ប្រចាំឆ្នាំ..................របស់អង្គភាព/អគ្គនាយកដ្ឋាន/មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ........
## សម្រាប់ទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ៤០% ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| គោលបំណង/ចង្កោមសកម្មភាពរបស់ CAP4 | លទ្ធផលគន្លឹះក្នុងឆ្នាំ (Output) | សូចនាករសមិទ្ធកម្មគន្លឹះ (KPI) | លក្ខខណ្ឌវាយតម្លៃ | ពណ៌/វឌ្ឍនភាព | សមមាត្រប្រាក់ឧបត្ថម្ភ វិភាជតាម Output | សមមាត្រប្រាក់ឧបត្ថម្ភ វិភាជតាម KPI | ពិន្ទុវាយតម្លៃតាម KPI | សមមាត្រវង់ការវាយតម្លៃតាម KPI | សមមាត្រប្រាក់ឧបត្ថម្ភត្រូវបើកផ្តល់តាម Output |
|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7=6/ចំនួន KPI | 8 | 9=7*8 | 7 = a+b+.. នៃ 9 |
| ១១. | Output1:... | ... | ■:... (១ ពិន្ទុ)<br>⬟:...(0,៧៥ ពិន្ទុ)<br>▲:... (0,៥ ពិន្ទុ)<br>●:... (0 ពិន្ទុ) | ... | ...% | ...% | ១ ពិន្ទុ, 0,៧៥ ពិន្ទុ 0,៥ ពិន្ទុ ឬ 0 ពិន្ទុ | a. ...% | ...% |
| | | ... | ■:... (១ ពិន្ទុ)<br>⬟:...(0,៧៥ ពិន្ទុ)<br>▲:... (0,៥ ពិន្ទុ)<br>●:... (0 ពិន្ទុ) | ... | | ...% | ១ ពិន្ទុ, 0,៧៥ ពិន្ទុ 0,៥ ពិន្ទុ ឬ 0 ពិន្ទុ | b. ...% | |
| ១២. | Output2:... | ... | ■:... (១ ពិន្ទុ)<br>⬟:...(0,៧៥ ពិន្ទុ) | ... | ...% | ...% | ១ ពិន្ទុ, 0,៧៥ ពិន្ទុ | a. ...% | ...% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | ▲:... (០,៥ ពិន្ទុ)<br>●:... (០ ពិន្ទុ) | | | | ០,៥ ពិន្ទុ ឬ<br>០ ពិន្ទុ | | |
| | | ... | ■:... (១ ពិន្ទុ)<br>⬟:...(០,៧៥ ពិន្ទុ)<br>▲:... (០,៥ ពិន្ទុ)<br>●:... (០ ពិន្ទុ) | ... | | ...% | ១ ពិន្ទុ,<br>០,៧៥ ពិន្ទុ<br>០,៥ ពិន្ទុ ឬ<br>០ ពិន្ទុ | b. ...% | |
| | | | | សរុប | =៤០% | =៤០% | - | =sum( ) | =sum( ) |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......

**អ្នកវាយតម្លៃ**

បានឃើញ ឯកភាព និងសូមគោរពជូន

ឯកឧត្តមអគ្គលេខាធិការ មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......

**អគ្គលេខាធិការរង នៃ អ.គ.ហ.**

បានឃើញ និងឯកភាព

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......

**អគ្គលេខាធិការ នៃ អ.គ.ហ.**

# ឧបសម្ព័ន្ធ៤៖

# ប្រកាសស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាន និងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩៨៧ សហវ.ប្រក.[illegible]

# ប្រកាស
## ស្តីពី
## គោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ ការលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈ-កម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញសារាចរាជរដ្ឋាភិបាលលេខ ១៤ សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងសមិទ្ធកម្មក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ ស្តីពីការបង្កើតមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញសេចក្តីសម្រេចលេខ ២៥ សសរ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ ស្តីពីការបង់ភាគទានរបស់ក្រសួង ស្ថាប័នចូលក្នុងមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងរញ្ញវត្ថុសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ដោយប្រើប្រាស់ថវិកាក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយសមធម៌ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្តល់ការលើកចិត្តជូន **ក.ហ.ស**. នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត។

## ជំពូកទី២

## គោលការណ៍លើកទឹកចិត្ត

**ប្រការ៣ .-**

ការលើកទឹកចិត្ត សំដៅដល់ការផ្តល់ប្រាក់ឧបត្ថម្ភជូនសមាសភាព **ក.ហ.ស**. នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ដែលបានបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនប្រកបដោយផលិតភាព គុណភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ៤ .-**

ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវផ្តល់ជូនសមាសភាព **ក.ហ.ស**. នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ក្នុងអត្រាដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ប្រធាន **គ.ហ.ស.** | ស្មើនឹង | ២ ០០០ ០០០ រៀល |
| ២. អនុប្រធាន **គ.ហ.ស.** | ស្មើនឹង | ១ ៥០០ ០០០ រៀល |
| ៣. មន្ត្រីបង្គោល | ស្មើនឹង | ១ ៣០០ ០០០ រៀល |
| ៤. សមាជិក | ស្មើនឹង | ១ ០០០ ០០០ រៀល |

សមាសភាពជាក់ស្តែង នៃ **គ.ហ.ស.** នៅតាមក្រសួង-ស្ថាប័ននីមួយៗ ដែលត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវកម្រិតត្រឹមចំនួន ១០ (ដប់) រូប ក្នុងមួយក្រសួង-ស្ថាប័ន ក្នុងនោះរួមមាន៖ ប្រធាន **គ.ហ.ស.** ១ (មួយ) រូប អនុប្រធាន **គ.ហ.ស.** ១ (មួយ) រូប មន្ត្រីបង្គោល ១ (មួយ) រូប និងសមាជិក ៧ (ប្រាំពីរ) រូប។

សមាសភាពជាក់ស្តែង នៃ **គ.ហ.ស.** នៅតាមរដ្ឋបាលរាជធានី-ខេត្តនីមួយៗ ដែលត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវកម្រិតត្រឹមចំនួនពី៣ (បី) ទៅ ៥ (ប្រាំ) រូប ក្នុងមួយរដ្ឋបាលរាជធានី-ខេត្ត ក្នុងនោះរួមមាន៖ ប្រធាន **គ.ហ.ស.** ១ (មួយ) រូប អនុប្រធាន **គ.ហ.ស.** ១ (មួយ) រូប មន្ត្រីបង្គោល ១ (មួយ) រូប និងក្នុងករណីមានសមាសភាព ៥ (ប្រាំ) រូប ត្រូវផ្តល់ជូនសមាជិក ២ (ពីរ) រូប។

សមាសភាពជាក់ស្តែង នៃ **គ.ហ.ស.** នៅតាមក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ដែលត្រូវទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត អាចតិចជាង ឬ លើសចំនួនកំណត់ខាងលើ ដោយផ្អែកលើលទ្ធផល នៃការវាយតម្លៃសមិទ្ធកម្មការងារ ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្តនីមួយៗ។

## ជំពូកទី៣
## យន្តការ

**ប្រការ៥ .-**

អនុលោមតាមពិតានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ដែលកំណត់ដោយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) **គ.ហ.ស.** នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ត្រូវរៀបចំផែនការលើកទឹកចិត្តប្រចាំឆ្នាំ និងសមាសភាពទទួលប្រាក់ឧបត្ថម្ភ ដោយបំពេញឧបសម្ព័ន្ធទី១ និងទី២ ហើយភ្ជាប់មកជាមួយនូវលទ្ធផលគន្លឹះក្នុងឆ្នាំ ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្ញើមកអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ត្រឹមសប្តាហ៍ទី១ ខែតុលា មុនឆ្នាំអនុវត្ត។

**ប្រការ៦ .-**

ក្នុងនាមជាសេនាធិការ នៃ **គ.ហ.ស.**, ក្រុមការងារវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ល.ហ.**) នៃ **អ.គ.ហ.** ត្រូវពិនិត្យ និងវាយតម្លៃផែនការលើកទឹកចិត្តប្រចាំឆ្នាំដូចមានចែងក្នុងប្រការ៥ យ៉ាងម៉ឺងម៉ាត់ ដោយផ្អែកលើលទ្ធផលគន្លឹះក្នុងឆ្នាំ និងលក្ខខណ្ឌយោងការងារ នៃឆ្នាំបន្ទាប់របស់ **គ.ហ.ស.** នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ដើម្បីដាក់ឆ្លងប្រធាន **គ.ហ.ស.** ពិនិត្យ និងឯកភាព ត្រឹមដំណាច់ខែធ្នូ មុនឆ្នាំអនុវត្ត។

**ប្រការ៧ ..**

សមាសភាព **ក.ហ.ស.** នៃគ្រប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ដែលត្រូវទទួលប្រាក់-ឧបត្ថម្ភលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.** តាមការស្នើសុំរបស់ **អ.គ.ហ.**។

**ប្រការ៨ ..**

**ក.ហ.ស.** នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត មានសិទ្ធិផ្លាស់ប្ដូរសមាសភាពទទួលបានប្រាក់ឧបត្ថម្ភប្រចាំអង្គភាព ឬ ស្ថាប័នរបស់ខ្លួន ក្នុងឆ្នាំអនុវត្ត តាមការចាំបាច់ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដោយភ្ជាប់មកជាមួយនូវលក្ខខណ្ឌយោងការងាររបស់សមាសភាពថ្មី មក **អ.គ.ហ.** យ៉ាងយូរត្រឹមសប្ដាហ៍ទី២ នៃខែទី១ នៃត្រីមាសបន្ទាប់ បន្ទាប់ពីការបើកផ្ដល់ប្រាក់ឧបត្ថម្ភសម្រាប់ត្រីមាសណាមួយ។

## ជំពូកទី៤
## ការតាមដាន និងវាយតម្លៃ និង នីតិវិធីនៃការបើកផ្ដល់

**ប្រការ៩ ..**

ប្រធាន **ក.ហ.ស.** ត្រូវកោះប្រជុំប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ឬ តាមការចាំបាច់ ដើម្បីតាមដាន និងវាយតម្លៃវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសមិទ្ធកម្មរបស់សមាសភាព **ក.ហ.ស.** របស់ខ្លួន ដែលទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត។ ក្នុងករណីអវត្តមាន ប្រធាន **ក.ហ.ស.** អាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួស។ ចំពោះការវាយតម្លៃសមិទ្ធកម្មសមាសភាព **ក.ហ.ស.** ក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ត្រូវប្រើប្រាស់ឧបសម្ព័ន្ធទី៤ ដើម្បីជាមូលដ្ឋានសម្រាប់កិច្ចពិភាក្សា និងជាកម្មវត្ថុ នៃការផ្អាក ឬបន្តផ្ដល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត។

**ប្រការ១០ ..**

**ក.ហ.ស.** នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ត្រូវរៀបចំរបាយការណ៍សមិទ្ធកម្ម នៃការអនុវត្តផែនការសកម្មភាពលម្អិតប្រចាំត្រីមាស និងប្រចាំឆ្នាំ ស្របតាមលិខិតគតិយុត្តជាធរមាន។ ចំពោះរបាយការណ៍បូកសរុបការវាយតម្លៃសមិទ្ធកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំ របស់សមាសភាព **ក.ហ.ស.** ត្រូវរៀបចំតាមឧបសម្ព័ន្ធទី៣ រួចផ្ញើមក **អ.គ.ហ.** ឱ្យបានទាន់ពេលវេលា ដែលជាលក្ខខណ្ឌតម្រូវសម្រាប់បើកផ្ដល់ប្រាក់-ឧបត្ថម្ភលើកទឹកចិត្ត សម្រាប់ ៣ (បី) ត្រីមាស។

**ប្រការ១១ ..**

ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវបើកផ្ដល់ផ្អែកលើលក្ខខណ្ឌ ដូចខាងក្រោម៖

**ក. លក្ខខណ្ឌទូទៅ**

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៦០ (ហុកសិប) ភាគរយ នៃប្រាក់ឧបត្ថម្ភប្រចាំឆ្នាំ ត្រូវបើកផ្ដល់ជូនសមាសភាព **ក.ហ.ស.** នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត សម្រាប់ ៣ (បី) ត្រីមាស ដោយក្នុង ១ (មួយ) ត្រីមាស ត្រូវបើកផ្ដល់ចំនួន ២០ (ម្ភៃ) ភាគរយ។ ការបើកផ្ដល់ អាចប្រព្រឹត្តទៅបាន បន្ទាប់ពី **អ.គ.ហ.** ទទួលបាននូវឯកសារ ដូចខាងក្រោម៖

- កិច្ចព្រមព្រៀងសមិទ្ធកម្ម ភ្ជាប់មកជាមួយនូវលទ្ធផលគន្លឹះក្នុងឆ្នាំ
- ផែនការលើកទឹកចិត្ត និងលក្ខខណ្ឌយោងការងាររបស់សមាសភាព **ក.ហ.ស**. នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ដែលទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ
- របាយការណ៍សមិទ្ធកម្ម នៃការអនុវត្តផែនការសកម្មភាពលម្អិតប្រចាំត្រីមាស និងប្រចាំឆ្នាំ N-1 ក្នុងនោះ របាយការណ៍ប្រចាំឆ្នាំ N-1 សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី១ របាយការណ៍ប្រចាំត្រីមាសទី១ សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី២ របាយការណ៍ប្រចាំត្រីមាសទី២ សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី៣ និង
- របាយការណ៍បូកសរុបការវាយតម្លៃសមិទ្ធកម្មមន្ត្រីសមាសភាពទទួលបានប្រាក់ឧបត្ថម្ភ ប្រចាំត្រីមាស និងប្រចាំឆ្នាំ N-1 តាមទម្រង់ឧបសម្ព័ន្ធទី៣ ក្នុងនោះរបាយការណ៍ប្រចាំឆ្នាំ N-1 សម្រាប់បើកផ្តល់ត្រីមាសទី១ របាយការណ៍ប្រចាំត្រីមាសទី១ សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី២ របាយការណ៍ត្រីមាសទី២ សម្រាប់បើកផ្តល់ប្រចាំត្រីមាសទី៣។

**ខ. លក្ខខណ្ឌសមិទ្ធកម្ម**

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៤០ (សែសិប) ភាគរយ ដែលនៅសេសសល់ក្នុងឆ្នាំ ត្រូវបើកផ្តល់ជូនសមាសភាព **ក.ហ.ស**. នៃក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ដែលទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត សម្រាប់ត្រីមាសទី៤ តាមលក្ខខណ្ឌ និងនីតិវិធី ដូចខាងក្រោម៖

- **គ.ល.ហ**. ត្រូវរៀបចំវិភាជសមាមាត្រប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៤០ (សែសិប) ភាគរយ ទៅតាមលទ្ធផលគន្លឹះក្នុងឆ្នាំនីមួយៗ ហើយចែកសមាមាត្រស្មើៗគ្នាទៅតាមសូចនាករសមិទ្ធកម្មគន្លឹះគាំទ្រនីមួយៗ
- សូចនាករសមិទ្ធកម្មគន្លឹះនីមួយៗគាំទ្រដល់លទ្ធផលគន្លឹះក្នុងឆ្នាំ ត្រូវបានដាក់ពិន្ទុ ១ សម្រាប់វឌ្ឍនភាពពណ៌បៃតងចាស់, ពិន្ទុ ០,៧៥ សម្រាប់វឌ្ឍនភាពពណ៌បៃតងខ្ចី, ពិន្ទុ ០,៥ សម្រាប់វឌ្ឍនភាពពណ៌លឿង និង ០ សម្រាប់វឌ្ឍនភាពពណ៌ក្រហម និង
- លទ្ធផលនៃការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំនីមួយៗ ដែលបូកយោងពីពិន្ទុវាយតម្លៃសូចនាករសមិទ្ធកម្មគន្លឹះនីមួយៗ នឹងត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការបើកផ្តល់ប្រាក់ឧត្ថម្ភលើកទឹកចិត្តសម្រាប់ត្រីមាសទី៤។

**គ.ល.ហ**. ត្រូវប្រើប្រាស់ទម្រង់ឧបសម្ព័ន្ធទី៥ សម្រាប់ជាមូលដ្ឋាននៃការវិភាជ ការវាយតម្លៃ និងការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៤០ (សែសិប) ភាគរយ។

ដើម្បីបើកផ្តល់ប្រាក់ឧបត្ថម្ភទាន់ពេលវេលាសម្រាប់លក្ខខណ្ឌសមិទ្ធកម្ម ក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ត្រូវផ្ញើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ ប្រចាំឆ្នាំ ដោយភ្ជាប់មកជាមួយឯកសារយោងឱ្យបានត្រឹមត្រូវ មក **អ.គ.ហ**. យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទី១ នៃខែទី១ នៃឆ្នាំបន្ទាប់។ **គ.ល.ហ**. ត្រូវបញ្ចប់ការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំនេះ ត្រឹមសប្តាហ៍ទី៤ នៃខែទី១ នៃឆ្នាំបន្ទាប់ និងបើកផ្តល់យ៉ាងយូរត្រឹមសប្តាហ៍ទី១ នៃខែទី២ នៃឆ្នាំបន្ទាប់។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ១២ .-**

ផែនការលើកទឹកចិត្តសម្រាប់ឆ្នាំ២០២៤ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបន្តអនុវត្ត អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន រហូតដល់ដំណាច់ខែធ្នូ ឆ្នាំ២០២៤។

**ប្រការ១៣ .-**

ការបើកផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំ អាចមានការប្រែប្រួលជាយថាហេតុ ផ្អែកតាមស្ថានភាព និង លទ្ធភាព នៃថវិកាក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៤ .-**

ប្រកាសលេខ ៣៥១ សហវ.ប្រក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ ស្តីពីវិធាននិងនីតិវិធីនៃការផ្តល់ការលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង-ស្ថាប័ន និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥ .-**

ប្រកាសនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។

**ប្រការ១៦ .-**

នាយកខុទ្ទកាល័យ អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **អ.គ.ហ.** និង **ក.ហ.ស.** ប្រចាំក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

នៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ៩៨៧សហវ.ប្រក.គសហ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០២៤ ស្ដីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង ស្ថាប័ន/រដ្ឋបាលរាជធានី ខេត្ត**.........

**ផែនការលើកទឹកចិត្តប្រចាំឆ្នាំ**.................
**សម្រាប់ ក.ហ.ស. នៃ ក្រសួង ស្ថាប័ន ឬ រដ្ឋបាលរាជធានី ខេត្ត ដែលទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្ត**
**ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

| ល.រ. | គោត្តនាម និងនាម | ភេទ | មុខងារក្នុងកម្មវិធីកែទម្រង់ | សន្ទស្សន៍ | ប្រាក់ឧបត្ថម្ភប្រចាំខែ | ប្រាក់ឧត្ថម្ភប្រចាំឆ្នាំ | ឈ្មោះធនាគារ | លេខគណនី |
|---|---|---|---|---|---|---|---|---|
| | | | ប្រធាន **ក.ហ.ស.** | | | | | |
| | | | អនុប្រធាន **ក.ហ.ស.** | | | | | |
| | | | មន្ត្រីបង្គោល | | | | | |
| | | | សមាជិក | | | | | |
| | | | ... | | | | | |

បានឃើញ និងឯកភាព
ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......
**ប្រធាន ក.ហ.ស. នៃក្រសួង ស្ថាប័ន**...............................
**ឬ រដ្ឋបាលរាជធានី ខេត្ត**.......................

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......
**អ្នករៀបចំតារាង**

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ៩៨៥ សហវ.ប្រក.អគហ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង ស្ថាប័ន/រដ្ឋបាលរាជធានី ខេត្ត**.........

**លក្ខខណ្ឌយោងការងារ**

**សម្រាប់ ក.ហ.ស. នៃ ក្រសួង ស្ថាប័ន ឬ រដ្ឋបាលរាជធានី ខេត្ត ដែលទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំឆ្នាំ**...................

| ល.រ. | គោត្តនាម និងនាម | ភេទ | មុខតំណែងក្នុងក្របខ័ណ្ឌមន្ត្រីរាជការ | មុខងារក្នុងកម្មវិធីកែទម្រង់ | សន្ទស្សន៍ | លទ្ធផលគន្លឹះក្នុងឆ្នាំ/សូចនាករសមិទ្ធកម្មគន្លឹះ |
|---|---|---|---|---|---|---|
| | | | | ប្រធាន **ក.ហ.ស.** | | - ទទួលបន្ទុក |
| | | | | អនុប្រធាន **ក.ហ.ស.** | | - ទទួលបន្ទុក |
| | | | | មន្ត្រីបង្គោល | | - ទទួលបន្ទុក |
| | | | | សមាជិក | | - ទទួលបន្ទុក |
| | | | | ... | | - ទទួលបន្ទុក |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......

**ប្រធាន ក.ហ.ស. នៃក្រសួង ស្ថាប័ន..........ឬ**

**រដ្ឋបាលរាជធានី ខេត្ត**.............

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ ៩៨៧ សហវ.ប្រក.អគហ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ស្ដីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្ដល់ការលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង ស្ថាប័ន/រដ្ឋបាលរាជធានី ខេត្ត.........**

**របាយការណ៍បូកសរុបការវាយតម្លៃសមិទ្ធកម្មសមាសភាព ក.ហ.ស. នៃ ក្រសួង ស្ថាប័ន ឬរដ្ឋបាលរាជធានី ខេត្ត ដែលទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាសទី........ឆ្នាំ......../ប្រចាំឆ្នាំ........**

| ល.រ. | គោត្តនាម និងនាម | ភេទ | មុខងារក្នុងកម្មវិធីកែទម្រង់ | លទ្ធផលគន្លឹះក្នុងឆ្នាំ/សូចនាករសមិទ្ធកម្មគន្លឹះ | លទ្ធផលសម្រេចបាន | ពិន្ទុសមិទ្ធកម្ម | បន្ត ឬ ផ្អាក |
|---|---|---|---|---|---|---|---|
| ១ | | | ប្រធាន **ក.ហ.ស.** | | | ០ ទៅ ១០០ | |
| ២ | | | អនុប្រធាន **ក.ហ.ស.** | | | | |
| ៣ | | | មន្ត្រីបង្គោល | | | | |
| ៤ | | | សមាជិក | | | | |
| ៥ | | | ... | | | | |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......
**ប្រធាន ក.ហ.ស. នៃក្រសួង ស្ថាប័ន.......................ឬ**
**រដ្ឋបាលរាជធានី ខេត្ត................**

ឧបសម្ព័ន្ធទី៤ នៃប្រកាសលេខ ៩៨៧សហវ.ប្រក.សគ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៤ ស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង ស្ថាប័ន/រដ្ឋបាលរាជធានី ខេត្ត.........**

**ការវាយតម្លៃសមិទ្ធកម្ម**
**សមាសភាព ក.ហ.ស. នៃ ក្រសួង ស្ថាប័ន ឬ រដ្ឋបាលរាជធានី ខេត្ត ដែលទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
**ប្រចាំត្រីមាសទី...... ឆ្នាំ......../ប្រចាំឆ្នាំ........**

គោត្តនាម-នាមមន្ត្រី៖.....................................
មុខងារក្នុងកម្មវិធីកែទម្រង់៖...........................................
អ្នកគ្រប់គ្រងផ្ទាល់៖.........................................

**១.សមិទ្ធកម្មតាមមុខងារនិងភារកិច្ច**

| *បំពេញដោយមន្ត្រីអនុវត្ត* | | | *វាយតម្លៃដោយអ្នកគ្រប់គ្រងផ្ទាល់* |
|---|---|---|---|
| **ល.រ** | **លទ្ធផលគន្លឹះក្នុងឆ្នាំ/សូចនាករសមិទ្ធកម្មគន្លឹះ** | **លទ្ធផលសម្រេចបាន** | **ពិន្ទុសមិទ្ធកម្ម** |
| ១ | | | ❑*កម្រិតឧត្តមភាព*<br>❑*លើសពីការរំពឹងទុក*<br>❑*ស្របតាមការរំពឹងទុក*<br>❑*មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑*មានតម្រូវការកែលម្អ* |
| | | | |
| | | | |
| | | | |

**២. សមត្ថភាពស្នូល**

| **ល.រ** | **ការអនុវត្ត** | **ពិន្ទុសមិទ្ធកម្ម** ( *វាយតម្លៃដោយអ្នកគ្រប់គ្រងផ្ទាល់* ) |
|---|---|---|
| ២ | **គុណភាពការងារ៖**<br>ការបំពេញការងារបានត្រឹមត្រូវ ប្រសិទ្ធភាព និងតាមកាលបរិច្ឆេទកំណត់ ដោយមានការតម្រង់ទិសបន្តិចបន្តួច | ❑*កម្រិតឧត្តមភាព*<br>❑*លើសពីការរំពឹងទុក*<br>❑*ស្របតាមការរំពឹងទុក*<br>❑*មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑*មានតម្រូវការកែលម្អ* |
| ៣ | **វត្តមាន និងភាពទៀងទាត់៖** | ❑*កម្រិតឧត្តមភាព* |

| | | |
|---|---|---|
| | មកបំពេញការងារបានទៀងទាត់ ផ្តល់ដំណឹងមុនក្នុងករណីស្នើសុំច្បាប់ | ❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ៤ | **ភាពជឿជាក់៖**<br>បំពេញសមិទ្ធកម្មបានក្នុងកម្រិតខ្ពស់។ គ្រប់គ្រងពេលវេលា និងបន្ទុកការងារប្រកបដោយប្រសិទ្ធភាព និងមានការទទួលខុសត្រូវ។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ៥ | **ជំនាញទំនាក់ទំនង៖**<br>ទំនាក់ទំនងផ្ទាល់មាត់ និងបែបសរសេរ មានលក្ខណៈច្បាស់លាស់ មានសណ្តាប់ធ្នាប់ និងមានប្រសិទ្ធភាព។ ស្តាប់ និងឈ្វេងយល់បានល្អ។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ៦ | **ការវិនិច្ឆ័យ និងការសម្រេចចិត្ត៖**<br>ធ្វើការសម្រេចចិត្តសមហេតុសមផល។ មានការវិនិច្ឆ័យល្អ មានភាពប៉ិនប្រសព្វ និងមានគំនិតច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហា។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ៧ | **គំនិតផ្តួចផ្តើម និងភាពទន់ភ្លន់៖**<br>បង្ហាញនូវគំនិតផ្តួចផ្តើម និងស្វែងរកនូវការងារដែលផ្តល់តម្លៃបន្ថែម។ កំណត់បាននូវបញ្ហា និងដំណោះស្រាយ។ ជំនះបញ្ហាប្រឈម និងសម្របទៅនឹងការផ្លាស់ប្តូរ។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ៨ | **ការបំពេញការងារជាក្រុម ក្រមសីលធម៌ និងកិច្ច-សហការ**<br>ផ្តល់នូវការគោរព ឱ្យតម្លៃចំពោះសហការី និងផ្តល់វិភាគទានដែលជាតម្លៃបន្ថែម ដើម្បីសម្រេចគោល-ដៅការងារក្នុងក្រុម។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |

### ៣. សមត្ថភាពការងារជាក់លាក់

| ល.រ | ការអនុវត្ត | ពិន្ទុសមិទ្ធកម្ម *(វាយតម្លៃដោយអ្នកគ្រប់គ្រងផ្ទាល់)* |
|---|---|---|
| ៩ | **ចំណេះដឹងពាក់ព័ន្ធ**<br>មានជំនាញ ចំណេះដឹង និងសមត្ថភាពចាំបាច់ក្នុងការបំពេញការងារ។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |
| ១០ | **ការបណ្ដុះបណ្ដាល និងការអភិវឌ្ឍ**<br>បន្តស្វែងរកមធ្យោបាយក្នុងការពង្រឹងសមត្ថភាព និងពង្រឹងសមត្ថភាពពាក់ព័ន្ធការងារជាប្រចាំតាមរយៈការសិក្សាឈ្វេងយល់ផ្ទាល់ខ្លួន និងការចូលរួមផ្សេងៗ។ | ❑ *កម្រិតឧត្តមភាព*<br>❑ *លើសពីការរំពឹងទុក*<br>❑ *ស្របតាមការរំពឹងទុក*<br>❑ *មិនទាន់ស្របពេញលេញតាមការរំពឹងទុក*<br>❑ *មានតម្រូវការកែលម្អ* |

*កំណត់សម្គាល់៖ កម្រិតឧត្តមភាព ១០ ពិន្ទុ, លើសពីការរំពឹងទុក ៨ ពិន្ទុ, ស្របតាមការរំពឹងទុក ៦ ពិន្ទុ, មិនទាន់ស្របពេញលេញតាមការរំពឹងទុក ៤ ពិន្ទុ, មានតម្រូវការកែលម្អ ២ ពិន្ទុ។*

**ពិន្ទុសរុប (សមិទ្ធកម្មតាមមុខងារនិងភារកិច្ច+សមត្ថភាពស្នូល +សមត្ថភាពការងារជាក់លាក់)៖**

.....................................

**សម្រេច ÷ បន្ត ☐ ផ្អាក ☐**

**មតិយោបល់របស់មន្ត្រីអនុវត្ត៖**.......................................

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......

**អ្នកគ្រប់គ្រងផ្ទាល់**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២.....

**មន្ត្រី ឬ សមាសភាពដែលត្រូវបានវាយតម្លៃ**

**បានឃើញ និងឯកភាព**

ថ្ងៃ ខែ ឆ្នាំ.......... .......ស័ក ព.ស ២៥........

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......

**ប្រធាន គ.ហ.ស. នៃ ក្រសួង ស្ថាប័ន.........ឬ**

**រដ្ឋបាលរាជធានី ខេត្ត.............**

ឧបសម្ព័ន្ធទី៥ នៃប្រកាសលេខ៩៨៧ សហវ.ប្រក.អគហ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៤ ស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ**
**ដឹកនាំការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

## ការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំ ប្រចាំឆ្នាំ..................របស់ក្រសួង ស្ថាប័ន..........ឬរដ្ឋបាលរាជធានី ខេត្ត..................
## សម្រាប់ទទួលប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ៤០% ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

| គោលបំណង/ចង្កោមសកម្មភាព របស់ CAP4 | លទ្ធផលគន្លឹះក្នុងឆ្នាំ (Output) | សូចនាករសមិទ្ធកម្មគន្លឹះ (KPI) | លក្ខខណ្ឌវាយតម្លៃ | ពណ៌/វឌ្ឍនភាព | សមមាត្រប្រាក់ឧបត្ថម្ភ វិភាជតាម Output | សមមាត្រប្រាក់ឧបត្ថម្ភ វិភាជតាម KPI | ពិន្ទុវាយតម្លៃតាម KPI | សមមាត្រវងការវាយតម្លៃតាម KPI | សមមាត្រប្រាក់ឧបត្ថម្ភត្រូវបើកផ្តល់តាម Output |
|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7=6/ចំនួន KPI | 8 | 9=7*8 | 7 = a+b+.. នៃ 9 |
| ១១. | Output1:... | ... | ■:... (១ ពិន្ទុ)<br>⬟:...(0,៧៥ ពិន្ទុ)<br>▲:... (0,៥ ពិន្ទុ)<br>●:... (0 ពិន្ទុ) | ... | ...% | ...% | ១ ពិន្ទុ,<br>0,៧៥ ពិន្ទុ<br>0,៥ ពិន្ទុ ឬ<br>0 ពិន្ទុ | a. ...% | ...% |
| | | ... | ■:... (១ ពិន្ទុ)<br>⬟:...(0,៧៥ ពិន្ទុ)<br>▲:... (0,៥ ពិន្ទុ)<br>●:... (0 ពិន្ទុ) | ... | | ...% | ១ ពិន្ទុ,<br>0,៧៥ ពិន្ទុ<br>0,៥ ពិន្ទុ ឬ<br>0 ពិន្ទុ | b. ...% | |
| ១២. | Output2:... | ... | ■:... (១ ពិន្ទុ) | ... | ...% | ...% | ១ ពិន្ទុ, | a. ...% | ...% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | ⬟:...(០,៧៥ ពិន្ទុ)<br>▲:... (០,៥ ពិន្ទុ)<br>●:... (០ ពិន្ទុ) | | | | ០,៧៥ ពិន្ទុ<br>០,៥ ពិន្ទុ ឬ<br>០ ពិន្ទុ | | |
| | | ... | ■:... (១ ពិន្ទុ)<br>⬟:...(០,៧៥ ពិន្ទុ)<br>▲:... (០,៥ ពិន្ទុ)<br>●:... (០ ពិន្ទុ) | ... | | ...% | ១ ពិន្ទុ,<br>០,៧៥ ពិន្ទុ<br>០,៥ ពិន្ទុ ឬ<br>០ ពិន្ទុ | b. ...% | |
| | | | | សរុប | =៤០% | =៤០% | - | =sum( ) | =sum( ) |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......
**អ្នកវាយតម្លៃ**

បានឃើញ ឯកភាព និងសូមគោរពជូន
ឯកឧត្តមអគ្គលេខាធិការ មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់
ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......
**អគ្គលេខាធិការរង នៃ អ.គ.ហ.**

បានឃើញ និងឯកភាព
ថ្ងៃ ខែ ឆ្នាំ ព.ស.២៥៦......
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២......
**អគ្គលេខាធិការ នៃ អ.គ.ហ.**

# ឧបសម្ព័ន្ធ៥៖

# ទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្ម

# កិច្ចព្រមព្រៀងសមិទ្ធកម្ម

# រវាង

# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ

# ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# និង

## (ឈ្មោះអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ឬ រដ្ឋបាលរាជធានី ខេត្ត)

## ឆ្នាំ.......................

# កិច្ចព្រមព្រៀងសមិទ្ធកម្ម
# រវាង
# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
# (ឈ្មោះអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ឬ រដ្ឋបាលរាជធានី ខេត្ត)

កិច្ចព្រមព្រៀងនេះ ធ្វើឡើងរវាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) និង (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) ដោយអនុលោមតាមសារាចរបស់រាជរដ្ឋាភិបាលលេខ............ចុះថ្ងៃទី.......ខែ..........ឆ្នាំ...........ស្តីពីការគ្រប់គ្រងសមិទ្ធកម្ម ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលបំណងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" និងក្នុងស្មារតីលើកកម្ពស់ប្រសិទ្ធភាព និងគណនេយ្យភាពលើការអនុវត្តផែនការសកម្មភាពក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**អ.គ.ហ.** និង (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) បានព្រមព្រៀងគ្នាក្នុងការអនុវត្ត ដូចមានចែងក្នុងប្រការខាងក្រោម៖

## ប្រការ ១-វិសាលភាព និងថវិកាគាំទ្ររបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

(ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) យល់ព្រមទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ ក្រោមការពិនិត្យនិងសម្រេចដោយ **អ.គ.ហ.** ដែលជាសេនាធិការនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) សម្រាប់អនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ (Output) ចំនួន........ ដែលមានតម្រូវការថវិកាលម្អិតដូចមានក្នុងផែនការថវិកា ឆ្នាំ២០២៤ របស់ (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ លទ្ធផលគន្លឹះក្នុងឆ្នាំទាំងនោះរួមមាន ដូចខាងក្រោម៖

១-...*[A2]*

២-...

៣-...

៤-...

៥-...

## ប្រការ ២-សូចនាករសមិទ្ធកម្មគន្លឹះ

ដើម្បីវាស់វែងសមិទ្ធកម្មនៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ ដូចក្នុងប្រការ១, (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) ព្រមព្រៀងរៀបចំសូចនាករសមិទ្ធកម្មគន្លឹះចំនួន.......ដោយរួមបញ្ចូលនូវគោលដៅប្រចាំត្រីមាស គោលដៅប្រចាំឆ្នាំ លក្ខខណ្ឌវាយតម្លៃ និងឯកសារភស្តុតាង ដូចបញ្ជាក់ក្នុងឧបសម្ព័ន្ធទី១ នៃកិច្ចព្រមព្រៀងនេះ។

## ប្រការ ៣-កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់

(ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) ត្រូវចាប់ផ្ដើមអនុវត្តការងារចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ............. និងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ............។

## ប្រការ ៤-ការគាំទ្រថវិកាពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**អ.គ.ហ.** ដែលជាសេនាធិការនៃ **គ.ហ.ស.** មានកាតព្វកិច្ចផ្តល់ធនធានហិរញ្ញវត្ថុជូន (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) តាមទំហំថវិកាដែលបានអនុម័តដោយប្រធាន **គ.ហ.ស.** ដើម្បីអនុវត្តឱ្យសម្រេចបានលទ្ធផលគន្លឹះក្នុងឆ្នាំដូចមានក្នុងប្រការ១ ខាងលើ ដោយអនុលោមទៅតាមនីតិវិធីហិរញ្ញវត្ថុដូចមានចែងក្នុងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ប្រការ ៥-របាយការណ៍សមិទ្ធកម្ម និងការផ្ដល់ការលើកទឹកចិត្ត

(ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) មានកាតព្វកិច្ចផ្តល់របាយការណ៍សមិទ្ធកម្មមក **អ.គ.ហ.** ស្របតាមសារាចររបស់រាជរដ្ឋាភិបាលលេខ................ចុះថ្ងៃទី..........ខែ............ឆ្នាំ........... ស្តីពីការគ្រប់គ្រងសមិទ្ធកម្ម ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ត្រូវបើកផ្តល់ជូន ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) នៃ (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) ផ្អែកលើលក្ខខណ្ឌដូចខាងក្រោមៈ

### ក. លក្ខខណ្ឌទូទៅ

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៦០% ត្រូវបើកផ្តល់ជូន **ក.ហ.ស.** នៃ (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាល រាជធានី ខេត្ត) សម្រាប់ ៣ ត្រីមាស ដោយក្នុងមួយត្រីមាសចំនួន ២០%។ ការបើកផ្តល់ គឺផ្អែកត្រឹមតែតម្រូវការឯកសារ មួយចំនួនដូចមានចែងក្នុងប្រកាសលេខ.................ចុះថ្ងៃទី...........ខែ.............ឆ្នាំ.............ស្តីពីគោលការណ៍ យន្តការ នីតិវិធី និងការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងក្របខ័ណ្ឌ..............។ **អ.គ.ហ.** ត្រូវរៀបចំបើកផ្តល់ប្រាក់ឧបត្ថម្ភជូន **ក.ហ.ស.** នៃ (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាល រាជធានី ខេត្ត) យ៉ាងយូរត្រឹមសប្តាហ៍ទី៤ នៃខែទី៣ នៃត្រីមាសណាមួយ។

### ខ. លក្ខខណ្ឌសមិទ្ធកម្ម

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៤០% ទៀត ត្រូវបើកផ្តល់ ដោយផ្អែកលើលទ្ធផល នៃការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំ...............។ វិធីសាស្ត្រនៃការវាយតម្លៃ ត្រូវអនុលោមតាមប្រកាសលេខ.............ចុះថ្ងៃទី...........ខែ.............ឆ្នាំ.............ស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខ័ណ្ឌ................។

ដើម្បីបើកផ្តល់ប្រាក់ឧបត្ថម្ភទាន់ពេលវេលាសម្រាប់លក្ខខណ្ឌសមិទ្ធកម្ម (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាល រាជធានី ខេត្ត) ត្រូវធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ.......... ដោយភ្ជាប់មកជាមួយឯកសារយោងឱ្យបានត្រឹមត្រូវ មក **អ.គ.ហ.** យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទីមួយ នៃខែទីមួយ នៃឆ្នាំបន្ទាប់។ **អ.គ.ហ.** ត្រូវបញ្ចប់ការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំនេះ ត្រឹមសប្តាហ៍ទីបួន នៃខែទីមួយ នៃឆ្នាំបន្ទាប់ និងបើកផ្តល់យ៉ាងយូរត្រឹមសប្តាហ៍ទីមួយ នៃខែទីពីរ នៃឆ្នាំបន្ទាប់។

ក្នុងករណី (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) សម្រេចបានសមិទ្ធកម្មបានពេញលេញ ឬ លើសផែនការ, **គ.ហ.ស.** នឹងពិចារណាលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ដោយបន្ថែមកញ្ចប់ថវិកា ឬ កញ្ចប់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំសម្រាប់ឆ្នាំ N+1 ដោយផ្អែកលើលទ្ធភាព នៃ ថវិកា ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងករណី (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) សម្រេចបានសមិទ្ធកម្ម ត្រឹមពាក់កណ្ដាល ឬ ក្រោមពាក់កណ្ដាល **គ.ហ.ស.** នឹងពិចារណាកាត់បន្ថយកញ្ចប់ថវិកា និងប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំសម្រាប់ឆ្នាំ N+1 ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ប្រការ ៦-ឯកសារឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀង

ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ រួមមានដូចខាងក្រោម៖

- **ឧបសម្ព័ន្ធទី១** ៖ លទ្ធផលគន្លឹះក្នុងឆ្នាំ............
- **ឧបសម្ព័ន្ធទី២** ៖ ផែនការថវិកាឆ្នាំ..............
- **ឧបសម្ព័ន្ធទី៣** ៖ ផែនការលើកទឹកចិត្តប្រចាំឆ្នាំ.................

## ប្រការ ៧-ឧិសានខាន

ប្រធាន **គ.ហ.ស.** នៃ (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) បានចុះហត្ថលេខា ដើម្បីបំពេញកាតព្វកិច្ចជានាគណនេយ្យភាពលើសមិទ្ធកម្មនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ចំណែកអគ្គលេខាធិការរងទទួលបន្ទុក តំណាងអគ្គលេខាធិការនៃ **អ.គ.ហ.** បានចុះហត្ថលេខាក្នុងនាមជាភាគីផ្ដល់ធនធានហិរញ្ញវត្ថុ។

ភាគីទាំងពីរមានភារកិច្ចអនុវត្តកិច្ចព្រមព្រៀងឱ្យបានម៉ឺងម៉ាត់។ កិច្ចព្រមព្រៀងនេះត្រូវធ្វើជាភាសាខ្មែរចំនួនពីរ (០២) ច្បាប់ដើម មានតម្លៃដូចគ្នា សម្រាប់រក្សាទុកនៅ **អ.គ.ហ.** និង (ឈ្មោះអង្គភាព ឬ មន្ទីរ ឬ រដ្ឋបាលរាជធានី ខេត្ត) និងមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

កិច្ចព្រមព្រៀងនេះ ធ្វើឡើងនៅរាជធានីភ្នំពេញ ថ្ងៃ.....................ខែ.........ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ត្រូវនឹងថ្ងៃទី.........ខែ...........ឆ្នាំ២០២៤

**អគ្គលេខាធិការ**
**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ**
**ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

..................................

**ប្រធានក្រុមការងារ**
**កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃ**
(ឈ្មោះក្រសួង ស្ថាប័ន)

..........................

បានឃើញ និងឯកភាព

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ**
**សាធារណៈ**

..........................

**រដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័ន**

..........................

# កិច្ចព្រមព្រៀងសមិទ្ធកម្ម

# រវាង

# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំ

# ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# និង

## (ឈ្មោះអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

## ឆ្នាំ.......................

# កិច្ចព្រមព្រៀងសមិទ្ធកម្ម
# រវាង
# អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
## (ឈ្មោះអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)

កិច្ចព្រមព្រៀងនេះ ធ្វើឡើងរវាងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) និង (ឈ្មោះអង្គភាព) ដោយអនុលោមតាមសារាចរបស់រាជរដ្ឋាភិបាលលេខ ១៤ សរ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងសមិទ្ធកម្ម ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលបំណងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**" និងក្នុងស្មារតីលើកកម្ពស់ប្រសិទ្ធភាព និងគណនេយ្យភាពលើការអនុវត្តផែនការសកម្មភាព ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**អ.គ.ហ.** និង (ឈ្មោះអង្គភាព) បានព្រមព្រៀងគ្នាក្នុងការអនុវត្ត ដូចមានចែងក្នុងប្រការខាងក្រោម៖

## ប្រការ ១-វិសាលភាព និងថវិកាគាំទ្ររបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

(ឈ្មោះអង្គភាព) យល់ព្រមទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ ក្រោមការពិនិត្យនិងឯកភាពដោយ **អ.គ.ហ.** ដែលជាសេនាធិការនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) សម្រាប់អនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ (Output) ចំនួន........ ដែលមានតម្រូវការថវិកាលម្អិតដូចមានក្នុងផែនការថវិកា ឆ្នាំ២០២..... របស់ (ឈ្មោះអង្គភាព) ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ លទ្ធផលគន្លឹះក្នុងឆ្នាំទាំងនោះរួមមាន ដូចខាងក្រោម៖

១-...[A2]

២-...

៣-...

៤-...

៥-...

## ប្រការ ២-សូចនាករសមិទ្ធកម្មគន្លឹះ

ដើម្បីវាស់វែងសមិទ្ធកម្មនៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ ដូចក្នុងប្រការ១, (ឈ្មោះអង្គភាព) ព្រមព្រៀងរៀបចំសូចនាករសមិទ្ធកម្មគន្លឹះចំនួន.......ដោយរួមបញ្ចូលនូវគោលដៅប្រចាំត្រីមាស គោលដៅប្រចាំឆ្នាំ លក្ខខណ្ឌវាយតម្លៃ និងឯកសារភស្តុតាង ដូចបញ្ជាក់ក្នុងឧបសម្ព័ន្ធទី១ នៃកិច្ចព្រមព្រៀងនេះ។

## ប្រការ ៣-កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់

(ឈ្មោះអង្គភាព) ត្រូវចាប់ផ្តើមអនុវត្តការងារចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ..............និងត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ.............។

## ប្រការ ៤-ការគាំទ្រថវិកាពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**អ.គ.ហ.** ដែលជាសេនាធិការនៃ **គ.ហ.ស.** មានកាតព្វកិច្ចផ្តល់ធនធានហិរញ្ញវត្ថុជូន (ឈ្មោះអង្គភាព) ក្នុងទំហំថវិកាចំនួន..................ដែលបានអនុម័តដោយប្រធាន **គ.ហ.ស.** ដើម្បីអនុវត្តឱ្យសម្រេចបានលទ្ធផលគន្លឹះ ក្នុងឆ្នាំដូចមានក្នុងប្រការ១ ខាងលើ ដោយអនុលោមទៅតាមនីតិវិធីហិរញ្ញវត្ថុដូចមានចែងក្នុងគោលការណ៍ណែនាំស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ប្រការ ៥-របាយការណ៍សមិទ្ធកម្ម និងការផ្តល់ការលើកទឹកចិត្ត

(ឈ្មោះអង្គភាព) មានកាតព្វកិច្ចផ្តល់របាយការណ៍សមិទ្ធកម្មមក **អ.គ.ហ.** ស្របតាមសារាចរបស់រាជរដ្ឋាភិបាលលេខ១៤ សរ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងសមិទ្ធកម្ម ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តទំហំ.......................ត្រូវបើកផ្តល់ជូន ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**)នៃ (ឈ្មោះអង្គភាព) ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

### ក. លក្ខខណ្ឌទូទៅ

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៦០% ត្រូវបើកផ្តល់ជូន **ក.ហ.ស.** នៃ (ឈ្មោះអង្គភាព) សម្រាប់ ៣ ត្រីមាស ដោយក្នុងមួយត្រីមាសចំនួន ២០%។ ការបើកផ្តល់ គឺផ្អែកត្រឹមតែតម្រូវការឯកសារមួយចំនួន ដូចមានចែងក្នុងប្រកាសលេខ៩៨៨ សហវ.ប្រក.អគហ. ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីគោលការណ៍ យន្តការ នីតិវិធី និង ការតាមដាននិងវាយតម្លៃ សម្រាប់ការផ្តល់ការលើកទឹកចិត្ត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ **អ.គ.ហ.** ត្រូវរៀបចំបើកផ្តល់ប្រាក់ឧបត្ថម្ភជូន **ក.ហ.ស.** នៃ (ឈ្មោះអង្គភាព) យ៉ាងយូរត្រឹមសប្តាហ៍ទី៤ នៃខែទី៣ នៃត្រីមាសណាមួយ បន្ទាប់ពី **អ.គ.ហ.** ទទួលបានឯកសារតម្រូវគ្រប់ចំនួន។

### ខ. លក្ខខណ្ឌសមិទ្ធកម្ម

ប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ៤០% ទៀត ត្រូវបើកផ្តល់ ដោយផ្អែកលើលទ្ធផល នៃការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំ................។ វិធីសាស្ត្រនៃការវាយតម្លៃ ត្រូវអនុលោមតាមប្រកាសលេខ៩៨៨ សហវ.ប្រក.អគហ. ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

ដើម្បីបើកផ្តល់ប្រាក់ឧបត្ថម្ភទាន់ពេលវេលាសម្រាប់លក្ខខណ្ឌសមិទ្ធកម្ម (ឈ្មោះអង្គភាព) ត្រូវធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តលទ្ធផលគន្លឹះក្នុងឆ្នាំ............... ដោយភ្ជាប់មកជាមួយឯកសារយោងឱ្យបានត្រឹមត្រូវ មក **អ.គ.ហ.** យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទីមួយ នៃខែទីមួយ នៃឆ្នាំបន្ទាប់។ **អ.គ.ហ.** ត្រូវបញ្ចប់ការវាយតម្លៃលទ្ធផលគន្លឹះក្នុងឆ្នាំនេះ ត្រឹមសប្តាហ៍ទីបួន នៃខែទីមួយ នៃឆ្នាំបន្ទាប់ និងបើកផ្តល់យ៉ាងយូរត្រឹមសប្តាហ៍ទីមួយ នៃខែទីពីរ នៃឆ្នាំបន្ទាប់។

ក្នុងករណី (ឈ្មោះអង្គភាព) សម្រេចបានសមិទ្ធកម្មបានពេញលេញ ឬ លើសផែនការ, **គ.ហ.ស.** នឹងពិចារណាលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ ដោយបន្ថែមកញ្ចប់ថវិកា ឬ កញ្ចប់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំសម្រាប់ឆ្នាំ N+1 ដោយផ្អែកលើលទ្ធភាព នៃ ថវិកាក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្នុងករណី (ឈ្មោះអង្គភាព) សម្រេចបានសមិទ្ធកម្ម ត្រឹមពាក់កណ្តាល ឬ ក្រោមពាក់កណ្តាល **គ.ហ.ស.** នឹងពិចារណាកាត់បន្ថយកញ្ចប់ថវិកា និងប្រាក់ឧបត្ថម្ភលើកទឹកចិត្តប្រចាំឆ្នាំសម្រាប់ឆ្នាំ N+1 ក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ប្រការ ៦-ឯកសារឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀង

ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ រួមមានដូចខាងក្រោម៖

- **ឧបសម្ព័ន្ធទី១** ៖ លទ្ធផលគន្លឹះក្នុងឆ្នាំ............
- **ឧបសម្ព័ន្ធទី២** ៖ ផែនការថវិកាឆ្នាំ..............
- **ឧបសម្ព័ន្ធទី៣** ៖ ផែនការលើកទឹកចិត្តប្រចាំឆ្នាំ.................

**ប្រការ ៧-ឧិសានទាន**

ប្រធាន **ក.ហ.ស.** នៃ (ឈ្មោះអង្គភាព) បានចុះហត្ថលេខា ដើម្បីបំពេញកាតព្វកិច្ចជានាគណនេយ្យភាពលើសមិទ្ធកម្មនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ចំណែកអគ្គលេខាធិការរងទទួលបន្ទុក តំណាងអគ្គលេខាធិការនៃ **អ.គ.ហ.** បានចុះហត្ថលេខាក្នុងនាមជាភាគីផ្តល់ធនធានហិរញ្ញវត្ថុ។

ភាគីទាំងពីរមានភារកិច្ចអនុវត្តកិច្ចព្រមព្រៀងឱ្យបានម៉ឺងម៉ាត់។ កិច្ចព្រមព្រៀងនេះត្រូវធ្វើជាភាសាខ្មែរចំនួនពីរ (០២) ច្បាប់ដើម មានតម្លៃដូចគ្នា សម្រាប់រក្សាទុកនៅ **អ.គ.ហ.** និង (ឈ្មោះអង្គភាព) និងមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

កិច្ចព្រមព្រៀងនេះ ធ្វើឡើងនៅរាជធានីភ្នំពេញ ថ្ងៃ....................ខែ.........ឆ្នាំ................ ព.ស. ២៥៦.....

ត្រូវនឹងថ្ងៃទី.........ខែ...........គ.ស. ២០២.....

**ប្រធានក្រុមការងារ**
**កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃ**
(ឈ្មោះអង្គភាព)

..........................

**អគ្គលេខាធិការរង**
**អគ្គលេខាធិការដ្ឋានគណៈកម្មាធិការ**
**ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

..................................

បានឃើញ និងឯកភាព

ថ្ងៃ.....................ខែ ............. ឆ្នាំ.....................ព.ស. ២៥៦....

រាជធានីភ្នំពេញ ថ្ងៃទី ខែ គ.ស. ២០២....

**រដ្ឋលេខាធិការ**
**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

(+៨៥៥) ៨៥ ៧៧៧ ៩២០

www.pfm.gov.kh